**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS


## សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ក. អូ ស្រីពៅ**

**ក. រឹម រ៉ាណែត**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គីមឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦(អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

៙៙៙📖៚៚៚

យើងខ្ញុំទាំងពីររូបមានឈ្មោះ **អូ ស្រីពៅ** និង **រីម រ៉ាំណែត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២៦ ផ្នែកនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចនៅក្នុងឆ្នាំសិក្សា២០២០និង ២០២១។ យើងខ្ញុំទាំងពីរនាក់បានសរសេរសារណាបញ្ចប់ការសិក្សា ដោយជ្រើសរើសប្រធានបទស្តីអំពី "**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**" ។

**យើងខ្ញុំសូមគោរពលំអោនកាយវាចាចិត្តសម្តែងនូវគារវកិច្ច និងព្រមទាំងមហាកត្តញ្ញូ ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ**

**លោកឪពុក វ៉ាន់ អូ** និង **អ្នកម្តាយ រ៉ុង លីម លោកឪពុក តី សំណាក់** និង **អ្នកម្តាយ ស៊ុយ ម៉ារ៉ាឌី** ព្រមទាំង **លោកយាយ ស៊ុយ សុភាព**។ កូនទាំងពីរសុំការអនុញ្ញាតិសម្តែងនូវការដឹងគុណចំពោះគុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបាន របស់លោកឪពុកអ្នកម្តាយទាំងទ្វេ ដែលបានផ្តល់កំណើតកូន ចិញ្ចឹមបីបាច់ថែរក្សាទំនុកបំរុងដល់កូនៗ ផ្តល់ទីជម្រក អាហារ សម្លៀកបំពាក់ សម្ភារៈចាំបាច់ផ្សេងៗ ដល់កូនៗទាំងពីរតាំងពីពេលនៅក្នុងពោះ រហូតដល់កូនបានធំដឹងក្តីពេញរូបពេញរាង។ រយៈពេលជាង ២០ឆ្នាំ ដែលកូនៗបានរស់នៅជាគ្រួសារតែមួយជាមួយលោកឪពុកអ្នកម្តាយ លោកទាំងទ្វេតែងតែយកចិត្តទុកដាក់អត់ធ្មត់នៅក្នុងការទូន្មានប្រៀនប្រដៅផ្តល់ដំបូន្មានល្អៗ ជំរុញនិងលើកទឹកចិត្តថ្នាក់ថ្នមមើលថៃ ថៃរក្សាការពារកូនៗ អស់ពីកម្លាំងកាយកម្លាំងចិត្ត ដើម្បីឲ្យកូនក្លាយទៅជាមនុស្សប្រកប ដោយគុណធម៌ សីលធម៌ កិត្តិគុណដ៏ល្អប្រពៃថ្លៃថ្លាបំផុត។ មិនតែប៉ុណ្ណោះអ្នកមានគុណទាំងពីរបានខិតខំប្រឹងប្រែងតស៊ូពុះពារគ្រប់ការលំបាកគ្រប់ឧបសគ្គទាំងអស់ មិនថាយប់មិនថាថ្ងៃឡើយ ដោយកម្លាំងញើសឈាម ដើម្បីជាផ្លូវ ជាស្ពានសម្រាប់ឲ្យកូនៗអាចឆ្លងទៅខាងមុខ និងសម្រាប់ផ្គត់ផ្គង់បំពេញរាល់តម្រូវការខ្វះខាតរបស់កូនៗទាំងគ្រឿងបរិភោគ និងសម្ភារៈប្រើប្រាស់សព្វបែបយ៉ាងព្រោះតែចង់ឲ្យកូនរស់នៅបានសុខស្រួល មិនលំបាក និងមានអ្វីៗដូចគេ។ តំណក់ញើសដែលលោកឪពុកអ្នកម្តាយបានតស៊ូយ៉ាងស្រោក់ស្រាំដោយមិនរអ៊ូ មិនត្អូញត្អែមួយម៉ាត់នេះបាននាំឲ្យកូនរៀនរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ហើយកូនៗពិតជាមិនអាចបំភ្លេចបាននូវគុណតម្លៃដ៏មហាធំធេង មហាថ្លៃថ្លារបស់លោកទាំងពីរដែលបានតក់ជាប់ក្នុងបេះដូងរបស់យើងខ្ញុំជារៀងរហូតលុះដល់ក្ស័យសង្ខារ ។ ដូចនេះកូនទាំងពីរសូមលើកហត្ថាទាំងទ្វេលំអោនកាយក្រាបសំពះដល់បាតជើង ដើម្បីសម្តែងនូវកត្តញ្ញូចំពោះគុណូបការៈដ៏ធំធេងមួយនេះដែលមិនអាចកាត់ថ្លៃបានឡើយ ព្រមទាំងបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកសូមជួយតាមថៃរក្សាលោកទាំងទ្វេឲ្យប្រកបតែសេចក្តីសុខ សេចក្តីចម្រើន ភាពសុខដុមរមនាសុខភាពមាំមួន និងភាពថ្កុំថ្កើងរុងរឿងជារៀងដរាបតទៅ។

រាជរដ្ឋាភិបាលនៃកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** រួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានដឹកនាំ និងជាចង្កូតសម្រាប់សង្គម ព្រមទាំងបង្កឲ្យមានកាលានុវត្តភាពដ៏ល្អគាប់ប្រសើរ និងជម្រុញឲ្យសង្គមជាតិមានការអភិវឌ្ឍន៍ ជឿនលឿនលូតលាស់លើគ្រប់វិស័យទាំងអស់ និយាយជារួម និងសម្រាប់វិស័យអប់រំ និងការសិក្សាស្រាវជ្រាវនិយាយដោយឡែក។ តាមរយៈការដឹកនាំដ៏ពូកែឈ្លាសវៃនិងខិតខំប្តូរផ្តាច់ បង្រួបបង្រួមជាតិរបស់សម្តេចបានធ្វើឲ្យប្រទេសកម្ពុជាសព្វថ្ងៃនេះទទួលបានសុខសន្តិភាពស្ថេរភាព ហើយធ្វើឲ្យនិស្សិតគ្រប់រូបបានសិក្សារៀនសូត្រ សិក្សាស្វែងយល់ស្រាវជ្រាវ និងក្រេបជញ្ជក់ចំណេះដឹងរហូតទទួលបានការអប់រំខ្ពង់ខ្ពស់គ្រប់ៗគ្នា ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍សង្គមកម្ពុជាឲ្យមានភាពទាន់សម័យ លូតលាស់ ជឿនលឿននិងប្រកបដោយវឌ្ឍនភាពថែមទៀត។

**ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ព្រមទាំងកម្លាំងកាយ កម្លាំងចិត្ត ចំណាយពេលវេលាដ៏មានត ម្លៃនៅក្នុងការដឹកនាំ និងណែនាំនូវផ្លូវល្អៗ ជ្រោមជ្រែង ត្រួសត្រាយផ្លូវសម្រាប់និស្សិតទាំងអស់ ព្រមទាំងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធភាពការងារខ្ពស់ ជាពិសេសលើកទឹកចិត្តជាមួយនិងការជម្រុញរួមទាំងជួយតម្រង់ទិសយើងខ្ញុំដើម្បីឲ្យទទួលបានពុទ្ធិច្បាស់លាស់ដើម្បីក្លាយជាសសរទ្រូងរបស់ជាតិ អាចបម្រើនិងសងគុណចំពោះសង្គមជាតិបានផងដែរ។

**លោកសាស្ត្រាចារ្យ ហ៊ីង គីមឡេង** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ព្រោះថាប្រសិនបើគ្មានការចំណាយពេលវេលាដ៏មានតម្លៃ ការយកចិត្តទុកដាក់ និងកម្លាំងកាយចិត្តក្នុងការជួយជ្រោមជ្រែង ផ្តល់យោបល់ជាគំនិតល្អៗ ត្រួសត្រាយ និងផ្តល់ជាវិធីសាស្ត្រល្អៗដល់យើងខ្ញុំទេនោះសមិទ្ធផលនេះមិនអាចកើតមានឡើយ ព្រោះថាគ្មានសមិទ្ធផលណាកើតឡើងដោយឯកឯងនោះទេ។ ការជួយណែនាំ ការនាំផ្លូវ ការបំភ្លឺផ្លូវ និងបានផ្តល់ជាបទពិសោធន៍ដ៏មានគុណតម្លៃរបស់លោកគ្រូអ្នកគ្រូកន្លងមក បានបង្រៀនឲ្យយើងខ្ញុំយល់ច្បាស់ពីប្រធានបទមួយនេះនិងស្គាល់ពីសង្គមនេះបានច្រើនជាងមុន ទើបធ្វើឲ្យយើងខ្ញុំសម្រេចបាននូវការតាក់តែងសារណាបញ្ចប់ការសិក្សាប្រកបដោយគុណភាព។

**និស្សិតរៀមច្បង និង មិត្តនិស្សិតដទៃទៀត** ដែលបានលើកទឹកចិត្តគាំទ្រ ផ្តល់ជាអនុសាសន៍ផ្តល់ជាបទពិសោធន៍គំនិតយោបល់ល្អៗ ដែលបានជម្រុញឲ្យយើងខ្ញុំកាន់តែមានទឹកចិត្តក្នុងការសម្រេចនូវសារណានេះដោយមិនរាថយ ដើម្បីទុកជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ក៏ដូចជាទុកសម្រាប់មិត្តនិស្សិតនិងប្អូនៗជំនាន់ក្រោយៗបានសិក្សាបន្ថែមឲ្យកាន់តែស៊ីជម្រៅលើប្រធានបទនេះ។

មុននឹងធ្វើការបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមការអនុញ្ញាតដើម្បីបានគោរពបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង និងលំអោនកាយវាចាចិត្តថ្លែងអំណរអរគុណ និងសម្តែងនូវសេចក្តីដឹងគុណដល់អ្នកទាំងអស់គ្នាដែលបានរៀបរាប់នូវខាងលើឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីសុខចម្រើន សុខភាពមាំមួន សុវត្ថិភាពមិនថាទីជិតមិនថាទីឆ្ងាយ ភាពសុខដុមរមនា មានសុខភាពល្អពេញបរិបូរណ៍ព្រមទាំងប្រកបការងារអ្វីៗឲ្យបានជោគជ័យប្រកបដោយឧត្តមភាពនិងភាពថ្កុំថ្កើងជានិរន្តរ៍។

# អារម្ភកថា

៙៙៙📖៚៚៚

បន្ទាប់ពីយើងខ្ញុំបាននឹងកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់បានក្រេបជញ្ជក់នូវចំណេះដឹងដ៏មានតម្លៃជាច្រើន និងទទួលបាននូវពុទ្ធិ បទពិសោធន៍ជាច្រើន ដែលបានបង្កប់នូវសារសំខាន់ទាំងឡាយទាក់ទងនឹងវិស័យច្បាប់ ព្រមទាំងចំណេះដឹងទូទៅផ្សេងៗមួយចំនួនផងដែរ។ ទន្ទឹមនឹងនេះ យើងខ្ញុំបានចាត់ទុកសាលាជាភូមិកំណើតបង្កើតគំនិត ព្រោះដោយសារតែសាលាមិនត្រឹមតែផ្តល់នូវចំណេះដឹងដល់យើងខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់នូវគុណធម៌ និងសីលធម៌ដល់រូបយើងខ្ញុំឲ្យស្គាល់អ្វីល្អ អ្វីអាក្រក់ អ្វីគួរធ្វើ អ្វីមិនគួរធ្វើ និងបានបង្ហាញផ្លូវល្អដល់កូនសិស្សទាំងឡាយ ទើបធ្វើឲ្យយើងខ្ញុំប្រកាន់ខ្ជាប់នូវវិន័យជាប់ប្រាណជានិច្ច។

នាពេលបច្ចុប្បន្នយើងនេះមានមនុស្សជាច្រើនបានពេញវ័យ ពេញរូបពេញរាង មិនថាប្រុសមិនថាស្រីឡើយ តែងតែមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនពេញចិត្តរៀងៗខ្លួន។ អ្នកខ្លះបានរៀបអាពាហ៍ពិពាហ៍សមតាមបំណង ដោយបង្កើតទៅជាគ្រួសារដែលសំបូរទៅដោយសុភមង្គល ប៉ុន្តែមានមនុស្សចំនួនខ្លះជីវិតអាពាហ៍ពិពាហ៍របស់ពួកគេមិនសមតាមបំណងនោះឡើយ។ ដោយសារតែយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រ ស្របពេលដែលប្រជាជនខ្មែរមួយចំនួនមានផលវិបាក ផលប៉ះពាល់ដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ពួកគេនៅពេលដែលជីវិតអាពាហ៍ពិពាហ៍របស់ពួកគេមានបញ្ហា ថាទ្រព្យសម្បត្តិពួកគេត្រូវបែងចែកបែបណាទៅ ពេលដែលពួកគេរំលាយចំណងអាពាហ៍ពិពាហ៍របស់ពួកគេ ជាហេតុធ្វើឲ្យយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិនេះ ដើម្បីឲ្យពួកគេទាំងពីរមានយុត្តិធម៌រវាងគ្នា និងបានទទួលទ្រព្យសម្បត្តិតាមភាពត្រឹមត្រូវតាមច្បាប់ ដោយគ្មានការកេងប្រវ័ញ្ច ឬបន្លំកើតឡើយទោះបីជាអ្នកទាំងពីរលែងលះគ្នាក៏ពិតមែន តែការបែងចែកត្រឹមត្រូវធ្វើឲ្យការបញ្ចប់មិនមានបញ្ហាជម្លោះកើតឡើងឬអាចឈានដល់តុលាការនោះឡើយ។ ហេតុនេះហើយទើបយើងខ្ញុំសម្រេចចិត្តយកប្រធានបទសារណាស្តីពី “**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**”។

ម្យ៉ាងវិញទៀត មូលហេតុដែលយើងខ្ញុំជ្រើសរើសយកប្រធានបទនេះទៀតសោត ដោយសារតែនៅក្នុងសង្គមបច្ចុប្បន្ននេះបញ្ហាចម្រូងចម្រាស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ទាក់ទងនឹងការបែងចែក ការកំណត់ទ្រព្យសម្បត្តិគឺមានភាពស្មុគស្មាញជាច្រើនដែលពិបាក និងរកភាពត្រឹមត្រូវជូនភាគីទាំងពីរ។ ពេលបញ្ហាវិវាទក្នុងគ្រួសារបានកើតឡើង ជីវិតអាពាហ៍ពិពាហ៍តែងតែជួបបញ្ហារង្គោះរង្គើរ នឹងអាចឈានដល់ការរំលាយនូវចំណងអាពាហ៍ពិពាហ៍នោះ ពេលដែលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ភាគីបានធ្វើសកម្មភាពក្នុងការបែងចែកទ្រព្យទៅតាមតែបំណង និងគំនិតរបស់ខ្លួន ដោយគ្មានការសាកសួរ ឬព្រមព្រៀងអីនោះទេ ជា

បញ្ហានោះនៅពេលដែលភាគីណាម្ខាងមិនភាពសុខចិត្តបានប្ដឹងទៅតុលាការនៅក្នុងការបែងចែកឲ្យត្រឹមត្រូវ និងយុត្តិធម៌។ ដំណាក់កាលនេះនីតិវិធីពិតជាមាននូវការស្មុគស្មាញផងដែរ។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ប្រទេសកម្ពុជាយើងធ្លាប់បានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ដែលជាហេតុធ្វើឲ្យវិស័យគតិយុត្តពោល គឺប្រព័ន្ធច្បាប់របស់កម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនឹងជាកត្តាបណ្ដាលឲ្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានគេយកមកប្រើប្រាស់ដើម្បីដោះស្រាយវិវាទនឹងបង្កឲ្យមានភាពខ្វះខាត ដែលតម្រូវឲ្យមានការបង្កើតបន្ថែមរាល់នូវបទដ្ឋានគតិយុត្តនានាដើម្បីពង្រឹងយន្តការដោះស្រាយជម្លោះដែលកើតឡើងនេះប្រកបដោយប្រសិទ្ធភាព។ ជាក់ស្ដែងនៅក្នុងរឿងក្ដីរដ្ឋប្បវេណី ជាពិសេសក្នុងរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ បញ្ហា ឬវិវាទភាគច្រើនរមែងតែងតែមានការជាប់ទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិនេះ។ ដូច្នេះយើងសង្កេតឃើញថាជម្លោះទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ជានិច្ចកាលតែងតែកើតមានឡើងនៅក្នុងបាតុភូតសង្គម ជាក់ស្ដែងទើបធ្វើឲ្យប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធមានការវិវត្តទៅមុខឥតឈប់ឈរ ហើយនៅក្នុងនោះទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ក៏ត្រូវបានបង្កើតឡើង។ ប្រព័ន្ធគេធ្វើឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឲ្យមានការកែប្រែផ្លូវច្បាប់ និងស្ថានភាពជាក់ស្ដែង ព្រមទាំងកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដី ប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្ដី ប្រពន្ធក្នុងតម្រូវការគ្រួសារ និងបង្ការនៅភាពស្មុគស្មាញក្នុងការធ្វើបំណែងចែកទ្រព្យសម្បត្តិ នៅពេលដែលសហព័ទ្ធបញ្ចប់ចំណងអាពាហ៍ពាពិពាហ៍ផងដែរ។ កត្តាទាំងនេះហើយ ទើបធ្វើឲ្យយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសយកប្រធានបទនេះ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងគោលបំណងសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅ និងដើម្បីឲ្យមិត្តនិស្សិតផ្សេងទៀត បានយល់កាន់តែច្បាស់ពីបញ្ហានៃទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ក្នុងការបែងចែកនៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយក៏ដូចជាផ្ដល់ចំណេះដឹងផ្នែករដ្ឋប្បវេណីមួយកម្រិតទៀតផងដែរ។

យើងខ្ញុំទាំងពីររូបមានសេចក្ដីសោមនស្សឥតគណនា ដែលទទួលបាននូវការណែនាំជាមួយនឹងការដឹកនាំពីសំណាក់លោកសាស្ត្រាចារ្យ **ហ៊ីង គីមឡេង** ក្នុងការស្រាវជ្រាវសារណាលើប្រធានបទដ៏មានសារៈសំខាន់មួយនេះ។ ដើម្បីឆ្លើយតបនឹងសមានចិត្តដ៏ល្អប្រពៃពីសំណាក់លោកគ្រូអ្នកគ្រូ យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណ ដល់លោកគ្រូអ្នកគ្រូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃបំផុតព្រមទាំងកម្លាំងកាយកម្លាំងចិត្តមិនខ្លាចនឿយហត់ ក្នុងការចែករំលែកចំណេះដឹង គួបផ្សំនឹងបទពិសោធន៍ដែលយើងខ្ញុំមិនធ្លាប់បានជួបប្រទះមក និងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងក្នុងការបណ្ដុះបណ្ដាល សម្របសម្រួល ជាហេតុធ្វើឲ្យយើងខ្ញុំទទួលបាននូវសមិទ្ធផលដ៏វិសេសវិសាលបំផុតមួយនេះ។

ទោះជាយ៉ាងណាក៏ដោយ ថ្វីបើការសិក្សាស្រាវជ្រាវនេះកើតចេញពីការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ពួកយើងខ្ញុំក៏ពិតមែន ប៉ុន្តែយើងខ្ញុំជឿថាការស្រាវជ្រាវនេះនៅមិនទាន់គ្រប់គ្រាន់ឥតខ្ចោះនៅឡើយទេ ដោយសារតែកើតមាននូវផលវិបាកមួយចំនួនក្នុងការស្វែងរកឯកសារមកបំពេញអត្ថន័យខ្លឹមសារបន្ថែម។ អាស្រ័យហេតុនេះហើយសូមលោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិតដទៃទៀតនិងមិត្តអ្នកអានទាំងឡាយមេត្តាខន្តី អភ័យទោស នូវរាល់កំហុស ខុសឆ្គងដោយអចេតនា ហើយយើងខ្ញុំរងចាំស្វាគមន៍ជានិច្ចចំពោះការចូលរួមវាយតម្លៃ ការរិះគន់ក្នុងន័យស្ថាបនាទៅលើប្រធានបទមួយនេះ។

ក្នុងនាមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅមួយក្បាលដែលកំពុងកាន់នេះ និងក្លាយជាឯកសារដ៏មានតម្លៃមួយ ក្នុងការផ្តល់ចំណេះដឹងដល់មិត្តអ្នកអានទាំងអស់គ្នា និងជួយលើកតម្កើងវិស័យអប់រំឆ្ពោះទៅរកភាពរីកចម្រើន លូតលាស់ និងវឌ្ឍនភាពផងដែរ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១

**អូ ស្រីពៅ** **រឹម រ៉ាំណែត**

## មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់**

**ផ្នែកទី១៖ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ៦

១.១. ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ........ ៧

១.១.១. ទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនអាពាហ៍ពិពាហ៍ ........ ៨

១.១.២. ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានពី ប្រទានកម្ម សន្តតិកម្ម ឬ អច្ច័យទានក្នុងអំឡុងអាពាហ៍ពិពាហ៍ ........ ៨

១.១.៣. ទ្រព្យទទួលបានពីការចាត់ចែងទ្រព្យដោយឡែករបស់សហព័ទ្ធ ........ ១០

១.១.៤. ការប្រើប្រាស់ទ្រព្យដោយឡែក ........ ១០

១.២. ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ........ ១២

១.២.១. កាតព្វកិច្ចរួមប្តីប្រពន្ធ ........ ១៣

១.២.២. ការគ្រប់គ្រង និងចាត់ចែងទ្រព្យរួម ........ ១៦

១.២.៣. ការប្រែក្លាយទ្រព្យដោយឡែកទៅជាទ្រព្យរួម ........ ១៨

**ផ្នែកទី២៖ ការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់** ........ ១៩

២.១. មូលហេតុនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ១៩

២.១.១. មរណភាពនៃសហព័ទ្ធម្ខាង ........ ១៩

២.១.២. ការបាត់ខ្លួននៃសហព័ទ្ធម្ខាង ........ ២០

២.១.៣. ការលែងលះ ........ ២០

២.២. អានុភាពនៃការលាយបាត់នូវរបបទ្រព្យសម្បត្តិសហព័ទ្ធ ........ ២០

២.៣. យន្តការនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២១

២.៣.១. ការបែងចែកទ្រព្យសម្បត្តិ ........ ២១

២.៣.២. ការទូទាត់សងគ្នាទៅវិញទៅមក ........ ២៣

## ជំពូកទី២

## ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមកិច្ចសន្យា


**ផ្នែកទី១៖ ប្រព័ន្ធទ្រព្យសម្បត្តិជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ....................២៧

១.១. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ....................២៨

១.២. ប្រព័ន្ធទ្រព្យសម្បត្តិរួម ....................២៩

១.២.១. គុណសម្បត្តិ ....................២៩

១.២.២. គុណវិបត្តិ ....................៣២

១.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល ....................៣៣

១.៤. អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ....................៣៤

១.៤.១.អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ....................៣៤

**ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ....................៣៥

២.១. លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាប្តីប្រពន្ធ ....................៣៨

២.១.១. ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ....................៣៨

២.១.២. ការព្រមព្រៀងក្នុងការបង្ហាញឆន្ទៈ ....................៣៩

២.១.៣. សមត្ថភាពភាគី( សហព័ទ្ធ ) ....................៣៩

២.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាប្តីប្រពន្ធ ....................៤០

២.២.១. ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ....................៤១

២.២.២. នីតិវិធីនៃការចេញលិខិតបញ្ជាក់ ....................៤៧

២.៣. ការបញ្ចប់របបគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ....................៤៨

២.៤. ផលប្រយោជន៍ និងផលវិបាកនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ....................៤៨

២.៤.១.ផលប្រយោជន៍ ....................៤៨

២.៤.២.ផលវិបាក ....................៥០

**សេចក្តីសន្និដ្ឋាន** ....................៥១

**អនុសាសន៍** ....................៥៤

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជាទូទៅនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គម ការប្រាស្រ័យទាក់ទងគ្នាគឺជាកត្តាចាំបាច់ បំផុតដែលជៀសមិនផុតឡើយអំពីទំនាក់ទំនងនេះ។ ម្យ៉ាងវិញទៀតនៅក្នុងការប្រាស្រ័យទាក់ទងគ្នានេះផងដែរ មនុស្សរមែងតែងតែប្រព្រឹត្តនៅកំហុសដែលជាមូលហេតុចម្បងដែលធ្វើឲ្យមានជម្លោះកើតឡើង។ បើយើងសង្កេតមើលទៅលើការដោះស្រាយបញ្ហាជម្លោះ ឬវិវាទរបស់មនុស្សវិញក្រៅពីការចរចារ សម្រុះសម្រួលគ្នា បទដ្ឋានគតិយុត្តនិងបទបញ្ញត្តិផ្សេងៗទៀតត្រូវបានបង្កើតឡើងជាបន្តបន្ទាប់វាអាស្រ័យទៅលើតម្រូវការ និងបរិបទនៃសង្គមដើម្បី ស្វែងរកនូវដំណោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាពណាមួយ។

ជាធម្មតានៅពេលដែលមាននូវការរៀបអាពាហ៍ពិពាហ៍ តើវានឹងធ្វើឲ្យឥទ្ធិពលបែបណាដល់ទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ?

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាប្រព័ន្ធទ្រព្យសម្បត្តិមួយដែលបានកំណត់អំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធនីមួយៗដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ជាទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធរកបាន ទទួលបានរៀងខ្លួនៗ និងទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងពីរទទួលបានដោយសហការគ្នា។តាមរយៈប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ គេសង្កេតឃើញមានមូលដ្ឋានពីររួមមានៈប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក (ផ្ទាល់ខ្លួន) និង ប្រព័ន្ធទ្រព្យសម្បត្តិរួម (ប្តីប្រពន្ធ)។ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ជាប្រព័ន្ធដែលមិនធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនោះទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។រីឯប្រព័ន្ធទ្រព្យសម្បត្តិរួមវិញ ជាប្រព័ន្ធដែលនឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនៅក្រោយអាពាហ៍ពិពាហ៍ ហើយទ្រព្យទាំងនោះនឹងក្លាយជាទ្រព្យរួម។

នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ជាគោលការណ៍ប្តីប្រពន្ធមានកម្មសិទ្ធិ និងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួន។ នៅក្នុងប្រទេសអង់គ្លេស និងរដ្ឋភាគច្រើននៅសហរដ្ឋអាមេរិកប្រើប្រាស់ប្រព័ន្ធនេះ ព្រមទាំងប្រទេសជប៉ុនក៏ឃើញប្រើនូវប្រព័ន្ធទ្រព្យដោយឡែកនេះផងដែរ។ គេបាននិយាយថាប្រព័ន្ធទ្រព្យដោយឡែកបានធានានូវភាពឯករាជ្យនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ហើយធ្វើឲ្យទំនាក់ទំនងគតិយុត្តិនៃទ្រព្យសម្បត្តិមានភាពច្បាស់លាស់ ហើយធ្វើឲ្យមានសុវត្ថិភាពលើកិច្ចការជំនួញផ្សេងៗ។ ប៉ុន្តែក៏មាននូវការរិះគន់ដែរថា ប្រព័ន្ធនេះមិនអាចឆ្លុះបញ្ចាំងឲ្យឃើញនូវទំនាក់ទំនង នៃការសហការគ្នាខាងផ្នែកសេដ្ឋកិច្ច របស់ប្តីប្រពន្ធ និងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធខ្លាំងពេក ហើយមិនអាចវាយតម្លៃបានអំពីការងារដែលប្រពន្ធត្រូវជួយគាំទ្រប្តី។

ចំណែកឯប្រព័ន្ធទ្រព្យសម្បត្តិរួម ជាប្រព័ន្ធដែលទទួលស្គាល់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ តាមរយៈអាពាហ៍ពិពាហ៍ក្នុងទំហំមួយដែលបានកំណត់ ហើយនៅពេលដែលអាពាហ៍ពិពាហ៍នោះរលាយ នឹងត្រូវយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមកធ្វើការបែងចែក។ ប្រព័ន្ធបែបនេះ ត្រូវបានឃើញមានប្រើនៅក្នុងប្រទេសបារាំង និងប្រទេសនានាដែលបានទទួលឥទ្ធិពលនៃប្រព័ន្ធនេះ រួមទាំងប្រទេសកម្ពុជាផងដែរ។ ភាគច្រើននៅក្នុងប្រព័ន្ធនេះ ត្រូវបានគេយកប្រាក់ចំណូលប្តីប្រពន្ធដែលរកបានមកធ្វើជាទ្រព្យរួម។ បើទ្រព្យសម្បត្តិដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍តាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ព្រមទាំងទ្រព្យដែលជាតម្លៃតបនៃទ្រព្យសម្បត្តិដោយឡែក ត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែក។ ករណីភាគច្រើនទ្រព្យរួម ជាទ្រព្យដែលកើតមាន និងទទួលបាននៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍។

ស្របពេលជាមួយគ្នានេះ នៅពេលប្រព័ន្ធទាំងពីរត្រូវបានបង្កើតឡើង បញ្ហាមួយចំនួនទៀតត្រូវបានបង្កើតឡើងដូចគ្នា ទាក់ទងនឹងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ នៅពេលដែលចំណងអាពាហ៍ពិពាហ៍របស់ពួកគេត្រូវបានរលាយ ។ នៅពេលដែលចំណងអាពាហ៍ពិពាហ៍មិនអាចបន្តទៀតបាន សហព័ទ្ធបានព្រមព្រៀងលែងលះគ្នា តែបញ្ហាក្រោយការលែងលះ ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិគ្នារវាងភាគីទាំងសងខាង ក្នុងការបែងចែកឲ្យបានស្មើគ្នា។ ដូចនេះហើយគេបានកំណត់ពីការបែងចែកទ្រព្យសម្បត្តិនោះឲ្យមានភាពយុត្តិធម៌ និងត្រឹមត្រូវដោយក្រមរដ្ឋប្បវេណីកម្ពុជាបានផ្តល់នូវប្រព័ន្ធដែលកំណត់ដោយច្បាប់យុត្តិធម៌មួយ សម្រាប់ទ្រព្យសម្បត្តិប្តីប្រពន្ធ។នៅក្នុងករណីដែលប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាព្រមព្រៀងមុនពេលរៀបអាពាហ៍ពិពាហ៍គ្នានោះទេ ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវបានកំណត់ចាត់ចែងទៅដោយប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ទៅតាមច្បាប់។

បច្ចុប្បន្នយើងនេះការមានវិវាទទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរវាងប្តីប្រពន្ធកាន់តែកើតមានឡើងជាបន្តបន្ទាប់ ដោយប្តីប្រពន្ធខ្លះមិនបានយល់ដឹងពីបែបបទ និងនីតិវិធីច្បាប់នោះឡើយ ទើបបង្កជាវិវាទ ចម្រូងចម្រាស់រវាងភាគីទាំងសងខាង។ ទន្ទឹមនឹងនេះ ដើម្បីទប់ស្កាត់កុំឲ្យមានបញ្ហាក្នុងការកំណត់ចាត់ចែងទ្រព្យសម្បត្តិ ទើបអ្នកច្បាប់បានបង្កើតនូវគតិយុត្តិផ្សេងៗដែលមានកំណត់ពីប្រព័ន្ធទាំងនោះកើតឡើង ជាហេតុបង្កឲ្យមានភាពងាយស្រួលក្នុងការបែងចែក។ ដោយសារតែប្រធានបទនេះមានសារសំខាន់សម្រាប់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន ដែលអាចឲ្យប្រជាពលរដ្ឋបានយល់ច្បាស់អំពី អ្វីជាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនោះមានការបែងចែកជាប៉ុន្មានប្រភេទ ? តើការបែងចែកទ្រព្យសម្បត្តិវិញ មានការបែងចែកយ៉ាងដូចម្តេចទៅ។ ទាំងនេះហើយ ជាមូលហេតុធ្វើឲ្យដែលធ្វើឲ្យយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ "**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**" នេះឡើង យកមកធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងស្វែងយល់ពីការបង្កើត ការកំណត់ពី

ប្រព័ន្ធទ្រព្យសម្បត្តិនេះឲ្យកាន់តែច្បាស់ថែមទៀត និងបន្សល់ទុកឯកសារនេះសម្រាប់ចែករំលែកដល់មិត្តអ្នកអានទាំងឡាយដែលមានបំណងចង់ស្វែងយល់បន្ថែមពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះថែមទៀតផង។

លើសពីនេះទៅទៀត ដើម្បីឲ្យមានភាពងាយស្រួលក្នុងការសិក្សាប្រធានបទមួយនេះឲ្យកាន់តែច្បាស់ និងស៊ីជម្រៅ យើងខ្ញុំសូមលើកយកតែពីប្រភេទនិងខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ យន្តការនៃការជម្រះបញ្ជីនៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ និងបែបបទនីតិវិធីនៃការកំណត់បែងចែកទ្រព្យសម្បត្តិពេលលែងលះប៉ុណ្ណោះ មកលើការស្រាវជ្រាវលើប្រធានបទមួយនេះ បានធ្វើឲ្យយើងខ្ញុំយល់កាន់តែច្បាស់ពីការកំណត់នូវប្រព័ន្ធទ្រព្យសម្បត្តិរវាងសហព័ទ្ធទាំងពីរ។

ចំណែកឯប្រភពឯកសារជំនួយស្មារតីរបស់ពួកយើងខ្ញុំក្នុងការចងក្រងប្រធានបទមួយនេះ គឺយើងខ្ញុំស្រាវជ្រាវបានមកពីច្បាប់ និងលិខិតបទដ្ឋានផ្សេងៗនៃក្រសួងយុត្តិធម៌ ក្រមរដ្ឋប្បវេណី២០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី២០១១ និងកម្រងមេរៀនពីលោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងតាមបណ្ណាបណ្ណាល័យផ្សេងៗជាច្រើនទៀត។ ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើ ឯកសារមួយចំនួន យើងខ្ញុំបានស្រាវជ្រាវចេញពីប្រព័ន្ធអីនធឺណេតផងដែរ។

បន្ទាប់ពីយើងខ្ញុំទទួលបានឯកសារគ្រប់គ្រាន់ហើយ យើងខ្ញុំបានសិក្សាស្វែងយល់ទៅលើឯកសារទាំងនោះ ហើយបានបែងចែកចំណាត់ថ្នាក់នៃឯកសារនីមួយៗ ដាក់ទៅជាបណ្តុំ ទើបបង្កើតបានជាប្លង់សារណា និងដាក់ជូនលោកសាស្ត្រាចារ្យធ្វើការពិនិត្យ និងកែសម្រួល។ ក្រោយពេលឆ្លងកាត់នូវការត្រួតពិនិត្យចប់សព្វគ្រប់ យើងខ្ញុំទទួលបាននូវប្លង់ស្ថាពរមួយ ដែលនៅក្នុងនោះបានបែងចែកជា ពីរជំពូក ដូចខាងក្រោមនេះ៖

**ជំពូកទី១ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់**

**ផ្នែកទី១៖ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**

១.១. ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ

១.២. ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ

**ផ្នែកទី២៖ ការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់**

២.១. មូលហេតុនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

២.២. អានុភាពនៃការលាយបាត់នូវរបបទ្រព្យសម្បត្តិសហព័ទ្ធ

២.៣. យន្តការនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

**ជំពូកទី២ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមកិច្ចសន្យា**

**ផ្នែកទី១៖ ប្រព័ន្ធទ្រព្យសម្បត្តិជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១.១. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

១.២. ប្រព័ន្ធទ្រព្យសម្បត្តិរួម

១.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល

១.៤. អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**ផ្នែកទី២៖ ល័ក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

២.១. ល័ក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាប្តីប្រពន្ធ

២.២. ល័ក្ខខណ្ឌទម្រង់នៃកិច្ចសន្យាប្តីប្រពន្ធ

២.៣. ការបញ្ចប់របបគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា

២.៤. ផលប្រយោជន៍ និងផលវិបាកនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

# ជំពូកទី១

# ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់តាមច្បាប់

# ជំពូកទី១

## ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ គឺកើតចេញពីទំនៀមទម្លាប់នៅក្នុងគ្រួសារដែលមានតាំងពីរយូរយារណាស់មកហើយ មុនពេលដែលវិធានវិជ្ជមានចូលអន្តរាគមន៍ម្ល៉េះ។ តាមរយៈបវេណីខ្មែរ ស្ត្រីជាអ្នកគ្រប់គ្រងកិច្ចការនៅក្នុងផ្ទះ ដែលជាមូលហេតុនាំឲ្យប្រភពចំណូលនៅក្នុងគ្រួសារទទួលបានមកពីស្វាមីធ្វើការក្រៅផ្ទះ។

ឆ្លងតាមក្រមទោសភរិយា ក្រមបំណុលក៏ដូចជាក្រមរដ្ឋប្បវេណី១៩២០ បានបង្ហាញឲ្យយើងឃើញថាស្ត្រីគឺជាអសមត្ថជននៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងគ្រួសារ ដែលជាមូលហេតុនាំឲ្យរបបនីត្យានុកូលសហគមន៍ទ្រព្យរួមពុំមាននៅកម្ពុជានៅឡើយទេ។ នៅក្នុងក្រមទោសភរិយាបានបញ្ជាក់ថាស្ត្រីដែលមានបំណងចង់ធ្វើការលែងលះដោយសារតែមូលហេតុថា ស្វាមីបានចាកចេញពីលំនៅដ្ឋានដើម្បីធ្វើជំនួញដែលរយៈពេលត្រូវត្រឡប់មកវិញនោះពុំឃើញស្វាមីត្រឡប់មកវិញស្ត្រីត្រូវធ្វើការប្រគល់ជំនូនជូនបណ្ណាការដែលទទួលបានទៅញាតិខាងស្វាមី ដើម្បីអាចធ្វើការលែងលះបាន។ ចំណែកឯក្រមរដ្ឋប្បវេណីចាស់វិញឆ្នាំ ១៩២០ ក៏បានបញ្ជាក់ពី អសមត្ថភាពរបស់ស្ត្រីមានដូចជា ការធ្វើការខាងក្រៅផ្ទះត្រូវមានការអនុញ្ញាតជាមុនពីស្វាមី រួមទាំងកាតព្វកិច្ចគោរពស្វាមីជាដើម។ របបនីត្យានុកូលសហគមន៍ ដែលអាចហៅម៉្យាងទៀតថាការគ្រប់គ្រងទ្រព្យតាមច្បាប់ ជារបបមួយដែលចាប់មាននៅព្រះរាជាណាចក្រកម្ពុជាចាប់ពីឆ្នាំ១៩៨៩ តាមរយៈច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ។ របបនេះនិងកើតឡើងជាស្វ័យប្រវត្តិ ក្នុងករណីសហព័ទ្ធទាំងឡាយណាពុំបានជ្រើសរើសការគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា។ ច្បាប់នេះមានលក្ខណៈពិសេស គឺត្រង់ថាភាពមិនស្មើគ្នានៅក្នុងគ្រួសារត្រូវបានលុបចោល ដោយសារតែមានការទទួលស្គាល់ការងារគេហកិច្ចស្មើគ្នាទៅនឹងការងារខាងក្រៅមានសេរីភាពជ្រើសរើសវិជ្ជាជីវៈរួមទាំងការដាក់ទ្រព្យសម្បត្តិចូលនៅក្នុងសហគមន៍។ នៅក្នុងរបបនេះច្បាប់គឺជាអ្នកកំណត់ប្រភេទទ្រព្យសម្បត្តិ ដូចជាចំណាត់ថ្នាក់ទ្រព្យសម្បត្តិកំណត់អំពីសិទ្ធិនិងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបញ្ចប់នៃរបបនេះ។ នៅក្នុងរបបនៃការគ្រប់គ្រងទ្រព្យតាមច្បាប់ទ្រព្យសម្បត្តិរបស់សហព័ទ្ធ គឺមានការលាយឡំគ្នា រវាងទ្រព្យសម្បត្តិទាំងឡាយណា ដែលភាគីម្ខាងៗជាកម្មសិទ្ធករនៃទ្រព្យសម្បត្តិនោះ។ ហេតុនេះហើយទើបមានការបែងចែកទ្រព្យរបស់សហព័ទ្ធជាពីរ គឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។ ទំនាក់ទំនងរវាងទ្រព្យសម្បត្តិប្តីប្រពន្ធគឺជាវិធានមួយដែលកំណត់ដោយច្បាប់ ហើយក៏មានលក្ខណៈខុសគ្នាទៅតាមវប្បធម៌របស់ប្រទេសនីមួយៗផងដែរ។ ក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងដោយយកគម្រូតាមក្រមរដ្ឋប្បវេណីប្រទេសជប៉ុនប៉ុន្តែមិនមែនចម្លងយកទាំងស្រុងនោះទេ គឺបានកែប្រែ

ដើម្បីឲ្យស្របទៅតាមវប្បធម៌និងសង្គមរបស់ប្រទេសកម្ពុជា។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់នេះ ធ្វើឲ្យស្របទៅតាមវប្បធម៌ និងសង្គមរបស់ប្រទេសកម្ពុជា នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនឆ្នាំ២០០៧ ក៏បានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីចាប់ពី មាត្រា៩៧១ ដល់ មាត្រា៩៧៧។[1] បើផ្អែកតាមមាត្រាត្រឹមតែ ៧មាត្រានេះ គឺពុំទាន់គ្រប់គ្រាន់ទេសម្រាប់ការអនុវត្ត ពីព្រោះមាត្រាទាំង ៧នេះ មិនបានបង្ហាញពីបរិបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់ឡើយ ចំពោះបរិបទនីតិវិធី និងទម្រង់នៃការចុះបញ្ជីគឺត្រូវតែអនុវត្តតាមបញ្ញត្តិរបស់ប្រកាសរបស់ក្រសួងយុត្តិធម៌ នោះគឺប្រកាសស្តីពីនីតិវិធី នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។[2]

ក្រោមការចង្អុលបង្ហាញនៃមាត្រា២៧នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ក៏បានបញ្ជាក់និងប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌មានសមត្ថកិច្ចទៅលើការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ។ តួយ៉ាងនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ដើម្បីជ្រើសរើសនូវវិធីនេះបានទាល់តែត្រូវធ្វើការស្វែងយល់ឲ្យបានច្បាស់នូវការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកំណត់ដោយច្បាប់តាមផ្នែកនីមួយៗដូចជា៖

- (ផ្នែកទី១) ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ និង
- (ផ្នែកទី២) ការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដែលច្បាប់កំណត់ដោយច្បាប់ ជាមុនសិន។

## ផ្នែកទី១៖ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ពោលជាទំនាក់ទំនងទ្រព្យសម្បត្តិដែលមានមុន ឬនៅក្រោយរៀបអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែកដែលទទួលពីប្រទានកម្ម សន្តតិកម្ម និងទ្រព្យសម្បត្តិជាតម្លៃតបនៃទ្រព្យ ដែលចាំបាច់ក្នុងការវាយតម្លៃអំពីភាពស្មើគ្នា និងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធដែលកើតមានក្នុងទំហំមួយដែលបានកំណត់ ពីព្រោះប្រទេសកម្ពុជាក៏ទទួលរងឥទ្ធិពលពីក្រមរដ្ឋប្បវេណីប្រទេសបារាំងនៅក្នុងសម័យអាណានិគម ហើយនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩។[3] បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច បើសហព័ទ្ធទាំងសងខាងមិនបានសម្តែងឆន្ទៈថានឹងជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិមួយណានោះទេ នោះគេសន្មតថាពួកគេរើសយកប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដោយស្វ័យប្រវត្តិ។ ក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នេះបាន បែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរគឺ៖ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

[1] លោកហ៊ីង គឹមឡេង និងឆឹង ស៊ីនៀង(សិក្ខាសាលាថ្ងៃទី០៤ ខែវិច្ឆកា ឆ្នាំ២០១៦ សហសាលB,RULE(Rule-JICA seminar 6))។

[2] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/00៧,៣១ ឧសភា ២០១១,មាត្រា ២៧។

[3] Professor of Law, Waseda University(Masayki Tanamura)

ម៉្យាងវិញទៀតនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គន្ថីទី៧ ផ្នែកទី៣ កថាខណ្ឌទី២ ដែល បញ្ញត្តិអំពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ពោលគឺ①ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។② សហព័ទ្ធ មានសិទ្ធប្រើប្រាស់ទ្រព្យសម្បត្តិរួមនៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នោះក្នុងជីវភាព។③សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀតឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។ ④បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឲ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិ។[4]

## ១.១. ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ជាទ្រព្យដែលទទួលតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលជាតម្លៃតបដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត[5]។

ជាការពិតណាស់ នៅពេលដែលរៀបអាពាហ៍ពិពាហ៍និងរួមរស់នៅជាមួយគ្នាយូរទៅ បញ្ហានៅក្នុងការរួមរស់នៅជាមួយគ្នានោះ ក៏មានបង្កើតឲ្យមាននូវបញ្ហាចម្រូងចម្រាស់គ្នា ហើយវាបានជះឥទ្ធិពលចំពោះទំនាក់ទំនងទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ដែលបង្កក្លាយទៅជាការបែងចែកទ្រព្យសម្បត្តិយ៉ាងច្បាស់លាស់រវាងប្តីប្រពន្ធ នៅពេលដែលមានការរំលាយនូវចំណងអាពាហ៍ពិពាហ៍ ជាដំណោះស្រាយភាគីទាំងពីរគប្បីចុះបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ នឹងតម្រូវឲ្យបញ្ជាក់យ៉ាងច្បាស់អំពីទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម ដើម្បីងាយស្រួលក្នុងការបែងចែក។ ចំពោះទ្រព្យសម្បត្តិដោយឡែកជាកម្មវត្ថុនៃការគ្រប់គ្រងរបស់សហព័ទ្ធម្ខាងដែលជាម្ចាស់កម្មសិទ្ធិតែមួយ រីឯទ្រព្យសម្បត្តិរួមវិញទើបជាកម្មវត្ថុនៃការគ្រប់គ្រងរួម។ហេតុដូចនេះបើក្រោយពេលរៀបអាពាហ៍ពិពាហ៍សហព័ទ្ធទាំងពីររស់នៅមិនចុះសម្រុងនឹងគ្នានោះទេ សហព័ទ្ធទាំងពីរអាចលុបចោលអាពាហ៍ពិពាហ៍បានដោយការលែងលះ ចំណែកឯទ្រព្យសម្បត្តិដោយឡែកវិញ ភាគីម្ខាងទៀតពុំអាចប្តឹងទាមទារបែងចែកទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតបានឡើយ។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៤។

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧២។

**១.១.១. ទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនអាពាហ៍ពិពាហ៍**

ទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍ សំដៅទៅលើទ្រព្យដែលសហព័ទ្ធម្ខាងបានបង្កើតឡើងតាមរយៈការប្រកបរបរការងារ ឬទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងទទួលបានតាមរយៈអច្ច័យទាន ប្រទានកម្ម សន្តតិកម្មជាអាទិ៍នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដែលទ្រព្យសម្បត្តិទាំងអស់នេះ សុទ្ធសឹងតែជាទ្រព្យដោយឡែករបស់សហព័ទ្ធតែម្ខាងដែលទទួលបាននោះ។ ទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ មិនគួរឲ្យក្លាយជាទ្រព្យសម្បត្តិរួមរវាងប្ដីប្រពន្ធនោះទេ ព្រោះថាសហព័ទ្ធម្ខាងទៀតមិនបានចូលរួមក្នុងការរកឡើយមិនថាជាកម្លាំងកាយ ឬកម្លាំងបញ្ញា ក្នុងការបង្កើតទ្រព្យនោះ។ ហេតុដូចនេះបើយើងយកទ្រព្យដែលសហព័ទ្ធមានមុនអាពាហ៍ពិពាហ៍ មកធ្វើជាទ្រព្យរួមនោះវាហាក់បីដូចជាអយុត្តិធម៌សម្រាប់សហព័ទ្ធម្ខាងទៀតដែលជាម្ចាស់ទ្រព្យ។

ឧទាហរណ៍៖ នៅមុនពេលមានពិធីរៀបអាពាហ៍ពិពាហ៍រវាង វិសាល និងណាណាកើតឡើង វិសាលមានផ្ទះវីឡាមួយ ហើយគាត់ក៏បានទិញឡានស៊េរីទំនើបមួយគ្រឿងទៀត។ ឯណាណាវិញ ក៏មានដីចម្ការ ២ កន្លែង និងផ្ទះមួយល្វែង។ បន្ទាប់មកបានប៉ុន្មានខែអ្នកទាំងពីរក៏បានរៀបអាពាហ៍ពិពាហ៍និងគ្នា។ដូចនេះបើសង្កេតតាមឧទាហរណ៍ខាងលើ ផ្ទះវីឡា និងឡានស៊េរីទំនើបមួយគ្រឿងដែលបានរៀបរាប់ខាងលើនេះ គឺជាទ្រព្យ សម្បត្តិដោយឡែករបស់ វិសាល។រីឯដីចម្ការ២កន្លែង និងផ្ទះមួយល្វែងនោះ ជាទ្រព្យសម្បត្តិដោយឡែករបស់ណាណា។

**១.១.២. ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានពី ប្រទានកម្ម សន្តតិកម្ម ឬ អច្ច័យទាន ក្នុងអំឡុងអាពាហ៍ពិពាហ៍**

នៅក្នុងអំឡុងពេលនៃការរួមរស់នៅប្ដីប្រពន្ធ ប្រសិនបើមានសហព័ទ្ធណាម្ខាងទទួលបានទ្រព្យសម្បត្តិដោយតាមរយៈប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ទ្រព្យនោះឯងជាទ្រព្យផ្ទាល់ខ្លួនរបស់សហព័ទ្ធ។ នៅពេលខ្លះប្រសិនបើយើងយកទ្រព្យសម្បត្តិដែលជាប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន ធ្វើជាទ្រព្យរួមនោះវានឹងអាចនាំឲ្យផ្ទុយនឹងឆន្ទៈរបស់អនុប្បទាយី ដែលជាអ្នកប្រទាន ឬមានបំណងប្រគល់ឲ្យ។

**ក. ប្រទានកម្ម**

ជាកិច្ចសន្យា ដែលភាគីម្ខាងបង្ហាញឆន្ទៈផ្ដល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃហើយភាគីម្ខាងទៀតយល់ព្រមទទួល។[6]

ឧទាហរណ៍៖ ក្រោយពីពេលរៀបអាពាហ៍ពិពាហ៍រវាងលោកសុវណ្ណារ៉ាជាមួយនិងលោកស្រីហួរបានប្រហែលជាងមួយខែជីដូន(ហៅថា ទាយក) របស់លោកសុវណ្ណារ៉ាបានធ្វើការប្រគល់ដីមួយប្លង់ឲ្យទៅ លោកសុវណ្ណារ៉ា (ហៅថា បដិគ្គាហក)។ ក្នុងករណីបែបនេះ ទោះបីជាប្រទានកម្មបានធ្វើអំឡុងពេលដែល លោក

---

[6] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧ ,លេខរៀង ៩៩។

សុវណ្ណារ៉ាមានចំណងអាពាហ៍ពិពាហ៍ជាមួយនិងលោកស្រីហួរក៏ដោយ ក៏ដីមួយប្លង់នោះនៅតែត្រូវបានចាត់ទុកជាទ្រព្យដោយឡែកដដែរ។

ទាំងនេះហើយ ជាទ្រព្យសម្បត្តិ ដែលទទួលបានពីប្រទានកម្មរបស់ទាយក (អ្នកផ្តល់ ឬប្រគល់ជូនឲ្យ) គឺដីដូន យ៉ាងណាមិញប្រសិនបើទាយកប្រទានកម្មទៅឲ្យសហព័ទ្ធទាំងពីរ ត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិរួម។ គួរតែកត់សម្គាល់ថាទាយកមិនបានបង្ហាញឆន្ទៈ ប្រទានកម្មឲ្យទាំងពីរនោះទេ គឺឲ្យតែសហព័ទ្ធតែម្ខាងប៉ុណ្ណោះ នោះទ្រព្យនោះជាទ្រព្យសម្បត្តិដោយឡែក។

**ខ. សន្តតិកម្ម**

ជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មរតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់។[7]

<u>ឧទាហរណ៍៖</u> លោកសុវណ្ណារ៉ា ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រីហួរ បានប្រហែលជាបីខែ ឪពុក (មតកជន) របស់លោកសុវណ្ណារ៉ា បានស្លាប់បាត់បង់ជីវិត។ ដោយឪពុករបស់លោកបានបន្សល់នូវផ្ទះមួយកន្លែង ឡាន ប្លង់ដីស្រែនិងចម្ការ២កន្លែង។ ក្នុងករណីបែបនេះគឺមានតែលោកសុវណ្ណារ៉ាប៉ុណ្ណោះដែលជាសន្តតិជន (អ្នកមានសិទ្ធិទទួលសន្តតិកម្ម ឬមរតក) ចំណែកឯលោកស្រីហួរវិញ មិនមែនជាសន្តតិជនទេ តាមច្បាប់ស្តីពីសន្តតិកម្ម។ក្នុងនាមជាសន្តតិជនលោក សុវណ្ណារ៉ា ទទួលបានមរតកពីឪពុកនូវផ្ទះមួយកន្លែង ឡាន ប្លង់ដីស្រែនិងចម្ការ២កន្លែង ទ្រព្យទាំងនេះជាទ្រព្យសម្បត្តិដោយឡែករបស់លោកសុវណ្ណារ៉ា ទោះបីជាគាត់ទទួលបាន នៅក្នុងពេលដែលគាត់មានចំណងអាពាហ៍ពិពាហ៍ជាមួយនិងលោកស្រី ហួរ ក៏ដោយ។

**គ. អច្ច័យទាន**

ជាប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគនោះ (អច្ច័យទានសកល) ឬក៏ជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅមនុស្សម្នាក់ ឬច្រើននាក់(អច្ច័យទានមានកំណត់)។[8]

<u>ឧទាហរណ៍៖</u> បន្ទាប់ពីសុវណ្ណារ៉ាបានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី ហួរ បានបួនឆ្នាំកន្លងទៅ ម្តាយមីងរបស់លោកសុវណ្ណារ៉ា បានស្លាប់បាត់បង់ជីវិត ហើយគាត់បានបន្សល់ទុកនូវបណ្តាំ (មតកសាសន៍) មួយច្បាប់ដែលមានខ្លឹមសារថាប្រគល់ភោជនីយដ្ឋានមួយកន្លែង ទៅឲ្យលោក សុវណ្ណារ៉ា។ ក្នុងករណីនេះ ភោជនីយដ្ឋាន នេះជាអច្ច័យទានមានកំណត់ដែល ម្តាយមីង (ម្ចាស់បណ្តាំ) បានប្រគល់

[7] សទ្ធានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧ ,លេខរៀង ១៤៣។

[8] សទ្ធានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧ ,លេខរៀង ១៧៧។

ឲ្យលោក សុវណ្ណារ៉ា (ហៅថា អច្ច័យលាភី)។ ទោះបីជាលោក សុវណ្ណារ៉ា ទទួលបានភោជនីយដ្ឋាននៅក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ជាមួយនិងលោកស្រី ហួរ ក៏ដោយ ក៏ភោជនីយដ្ឋាននោះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែកដែរ។

### ១.១.៣. ទ្រព្យទទួលបានពីការចាត់ចែងទ្រព្យដោយឡែករបស់សហព័ទ្ធ

ទ្រព្យសម្បត្តិដែលជាតម្លៃតប ជាទ្រព្យសម្បត្តិដែលអ្នកគ្រប់គ្រងផ្ទាល់ ឬម្ចាស់ទ្រព្យមានបំណងចង់ចាត់ចែងដោយពុំចាំបាច់មានការព្រមព្រៀងពីសហព័ទ្ធណាម្ខាងទៀតឡើយ លើកលែងតែទ្រព្យសម្បត្តិរួមត្រូវមានការព្រមព្រៀងពីប្តីប្រពន្ធទាំងសងខាង។

ឧទាហរណ៍៖ មុនរៀបអាពាហ៍ពិពាហ៍លោក ដារ៉ា មានដីមួយកន្លែងនៅខេត្តព្រះសីហនុ ដីនោះគឺជាទ្រព្យផ្ទាល់ខ្លួនរបស់គាត់។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយនិងលោកស្រីធីតា រួចហើយ លោក ដារ៉ា បានលក់ដីនោះក្នុងតម្លៃ៤០ម៉ឺនដុល្លាសហរដ្ឋអាមេរិក ដែលតម្លៃនេះហើយជាតម្លៃតបនៃទ្រព្យសម្បត្តិដោយឡែករបស់លោកដារ៉ា។ ដូចនេះប្រាក់ ៤០ ម៉ឺនដុល្លាសហរដ្ឋអាមេរិកដែលបានមកពីការលក់ដី គឺជាទ្រព្យសម្បត្តិដោយឡែករបស់លោក ដារ៉ា។

ជាក់ស្តែងយើងសង្កេតឃើញថា កាលណាទ្រព្យសម្បត្តិដោយឡែកជាវត្ថុគឺពុំមានភាពច្របូកច្របល់ជាមួយនិងទ្រព្យសម្បត្តិរួមឡើយ នៅពេលដែលទ្រព្យសម្បត្តិដោយឡែកជាវត្ថុ ហើយសហព័ទ្ធម្ខាងបានយកវត្ថុនោះទៅចាត់ចែងហើយបានជាតម្លៃតបមកវិញជាប្រាក់ ក៏ជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀតដែរ ប៉ុន្តែពេលខ្លះការយកតម្លៃតបនោះទៅប្រើប្រាស់ឬចាត់ចែងក្នុងគ្រួសារ ឬយកទៅចាត់ចែងលើអ្វីផ្សេងទៀតដែលជាហេតុនាំឲ្យសហព័ទ្ធខ្លះមានការភាន់ច្រឡំ នឹងចាត់ទុកថាជាទ្រព្យសម្បត្តិរួម។

### ១.១.៤. ការប្រើប្រាស់ទ្រព្យដោយឡែក

ជាទូទៅ សហព័ទ្ធទាំងពីរអាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនបានដោយសេរីដោយពុំចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតឡើយ។ សហព័ទ្ធនីមួយៗមានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបានដោយឯករាជ្យ។[9] ហើយប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត និងអាចត្រូវប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបានផងដែរ។ រីឯករណីដែលប្តីប្រពន្ធណាម្ខាង បានឬកំពុងតែអាស្រ័យនៅ អចលនវត្ថុនោះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏សហព័ទ្ធដែលកំពុងអាស្រ័យនៅនោះអាចបន្តអាស្រ័យនៅលើអចលនវត្ថុនោះបានដែរ។ [10] មួយវិញទៀតបើសហព័ទ្ធណាម្ខាងយកផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែក

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៤។

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៧។

របស់ខ្លួនមកប្រើប្រាស់ធ្វើជាលំនៅដ្ឋាន នោះក៏អាចប្រើប្រាស់បានផងដែរ។ លើសពីនេះទៅទៀតបើក្នុងករណីដែលសហព័ទ្ធជាកម្មសិទ្ធិករ បានលក់អចលនវត្ថុនោះទៅឲ្យ តតិយជន សហព័ទ្ធម្ខាងទៀតនៅតែអាចអាស្រ័យនៅលើអចលនវត្ថុនោះបានដដែលហើយតតិយជនដែលធ្វើលទ្ធកម្មលើអចលនវត្ថុ មិនអាចបណ្តេញសហព័ទ្ធដែលបានស្នាក់អាស្រ័យចេញបានទេ នេះក៏ជាការការពារសហព័ទ្ធម្ខាងទៀតជាពិសេស ចំពោះករណីលំនៅដ្ឋានគ្រួសារ។

ឧទាហរណ៍៖ ម៉ាលីនជាប្រពន្ធ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ នាងក៏បានមករួមរស់នៅជាមួយនិងប្តីរបស់នាង គឺលោកសុខម៉េង។ នាងបានរស់នៅលើផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ប្តីនាង។ ក្នុងករណីនេះមានន័យថា ផ្ទះខាងលើត្រូវបានប្រើប្រាស់ជាលំនៅដ្ឋានគ្រួសារដើម្បីជាការអាស្រ័យនៅរបស់គ្រួសារ ។ បន្ទាប់មកទៀតអស់រយៈពេល ៣ឆ្នាំ ដែលបានរួមរស់នៅជាមួយគ្នា អ្នកទាំងពីរក៏មានកូន ៥នាក់ផងដែរ។ លុះរួមរស់នៅជាមួយគ្នាយូរៗទៅអ្នកទាំងពីរក៏មានបញ្ហាករកំរកូស និងបញ្ហាទំនាស់ជាមួយគ្នាកើតឡើង។ នៅពេលជាមួយគ្នានោះសុខម៉េង ក៏កើតមានបញ្ហាហិរញ្ញវត្ថុ ហើយបានសម្រេចលក់ផ្ទះនោះឲ្យទៅ គាមុី ក្នុងតម្លៃសមស្របគួរសម។ ចំពោះការលក់ដូរផ្ទះ គឺធ្វើទៅត្រឹមត្រូវតាមច្បាប់គ្រប់លក្ខខណ្ឌពីព្រោះដោយសារតែផ្ទះនោះជាទ្រព្យដោយឡែករបស់ សុខម៉េង។ ក្នុងបញ្ហានេះ ទោះបីជាអ្នកទាំងពីរមានទំនាស់នឹងគ្នាក៏ពិតមែនហើយជាទ្រព្យដោយឡែករបស់ប្តីទៀត ក៏ម៉ាលីន នៅតែមានសិទ្ធិអាស្រ័យនៅផ្ទះនោះបានដដែល គឺស្របទៅតាមមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី។ សិទ្ធិរបស់ ម៉ាលីន នៅតែអាចអះអាងចំពោះ គាមុី បាន។ ចំណែកឯ គាមុីដែលបានទិញផ្ទះពី សុខម៉េងរួចហើយក៏មិនអាចបណ្តេញម៉ាលីន និងកូនរបស់នាងឲ្យចេញពីផ្ទះដោយសំអាងថានាងមានកម្មសិទ្ធិលើផ្ទះនោះបានឡើយ ពីព្រោះថាបទប្បញ្ញត្តិនៃមាត្រា ៩៧៧ បានផ្តល់សិទ្ធិអាស្រ័យនៅឲ្យ ម៉ាលីន និងកូនៗរបស់នាង ទោះបីជា សុខម៉េង បានលក់ផ្ទះទៅឲ្យហើយក៏ដោយ ។ ចំពោះបញ្ហាទាំងនេះសិទ្ធិរបស់ ម៉ាលីន និងត្រូវរលត់នៅពេលដែល ម៉ាលីនលែងជាសហព័ទ្ធរបស់ សុខម៉េង។

ឧទាហរណ៍ខាងលើបានបង្ហាញឲ្យឃើញថា ការអាស្រ័យនៅសម្រាប់សហព័ទ្ធនៅលើអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀត កាលបើអចលនវត្ថុនោះត្រូវបានប្រើសម្រាប់អាស្រ័យនៅរបស់គ្រួសារ នោះសិទ្ធិរបស់សហព័ទ្ធម្ខាងទៀតអាចត្រូវបានការពារ និងអាចអះអាងចំពោះគ្រប់បុគ្គលបាន ទោះបីមានការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុទៅឱ្យតតិយជនក៏ដោយ។

បើយោងតាមសេចក្តីកំណត់ក្រុម ភាគទី៥ គន្លឹទី៧ បានបកស្រាយថាសិទ្ធិអាស្រ័យនៅ នៅត្រង់នេះគឺជាសិទ្ធិអាទិភាពដែលអាចអះអាងអំពីការបន្តនូវការស្នាក់អាស្រ័យអចលនវត្ថុតទៅទៀតចំពោះតតិយជនបាន។[11] តាមការសង្កេតឃើញថាគោលបំណងរបស់មាត្រានេះ ការពារដល់សហព័ទ្ធម្ខាងទៀតដែលមិនមែនជាម្ចាស់

[11] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី និងសេចក្តីពន្យល់, ភាគទី៥ គន្លឹទី៧, ២០១០, ៣៨។

របស់ទ្រព្យ ដែលបានស្នាក់អាស្រ័យនៅលើទ្រព្យរបស់សហព័ទ្ធណាម្ខាង ដែលជាទីជម្រកទាំងមូលរបស់គ្រួសារ និងការពាររហូតទាល់តែសហព័ទ្ធទាំងពីរបានលែងលះគ្នា។ ចំណែងមាត្រា ២៧៤ ក៏មានចែងពីសិទ្ធិប្រើប្រាស់និងអាស្រ័យនៅផងដែរ ក៏ប៉ុន្តែមាត្រា ៩៧៧ មានលក្ខណៈពិសេសជាងត្រង់ថា សំដៅទៅលើសិទ្ធិរបស់សហព័ទ្ធតែម្តង។ ចំពោះមាត្រា២៧៤ វិញគឺ ខុសពីមាត្រា ៩៧៧ ព្រោះវាបានត្រឹមតែអាស្រ័យផលនិងកាន់កាប់ចំណែកមួយនៃអាគារទៅតាមសេចក្តីត្រូវការសម្រាប់ការរស់នៅរបស់ក្រុមគ្រួសារតែប៉ុណ្ណោះ ចំណែកមាត្រា ៩៧៧ វិសាលភាពរបស់មាត្រានេះ គឺការពារសហព័ទ្ធម្ខាងតែម្តង ដែលសហព័ទ្ធម្ខាងទៀតនោះមានសិទ្ធិក្នុងការអះអាងជាមួយតតិយជន មិនឲ្យធ្វើការរឹបអូសយកអចលនវត្ថុដែលខ្លួនកំពុងអាស្រ័យនៅនោះបានឡើយ លើកលែងទាល់តែសហព័ទ្ធម្ខាងទៀតនោះបានផ្លាស់ទីលំនៅ និងលែងលះជាមួយសហព័ទ្ធម្ខាងទៀត។

ករណីខាងលើបានឲ្យយើងដឹងថា វាមានភាពប្រហាក់ប្រហែលគ្នាក៏ពិតមែន ប៉ុន្តែគោលគំនិតរបស់ច្បាប់ដើម្បីការពារនូវផលប្រយោជន៍របស់បុគ្គលផ្សេងៗ ដែលយើងជាអ្នកច្បាប់គប្បីបែងចែកឲ្យច្បាស់ក្នុង កាលៈទេសៈណាគួរលើកយកបញ្ញត្តិណាមួយមកការពារបុគ្គលនិងតួនាទីផ្សេងៗរបស់បុគ្គលនោះ។

## ១.២. ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ

ដោយផ្អែកទៅលើមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ចែងថាទ្រព្យសម្បត្តិរួមជាទ្រព្យ ឬក៏ជាអ្វីៗដែលសហព័ទ្ធទាំងពីរនាក់រកបានជាមួយគ្នា ឬ សហព័ទ្ធណាម្នាក់រកបាន នៅក្នុងអំឡុងពេលដែលមានចំណងអាពាហ៍ពិពាហ៍កើតឡើង។ ជាគោលការណ៍គេចាត់ទុកប្រាក់បៀវត្សដែលរកបានដោយសហព័ទ្ធម្នាក់ៗចូលជាទ្រព្យសម្បត្តិរួម មានន័យថារាល់ទ្រព្យសម្បត្តិទាំងឡាយ ដែលទទួលបានមកពីផលឧស្សាហកម្មផ្ទាល់ខ្លួន (ដូចជាប្រាក់បៀវត្ស)។ ដូចគ្នាដែរទ្រព្យដែលទិញដោយប្រាក់បៀវត្សរបស់សហព័ទ្ធម្នាក់ៗ ក៏ចាត់ចូលជាទ្រព្យរួមផងដែរព្រមទាំងទ្រព្យដែលបានមកពីផលចំណេញផ្ទាល់ខ្លួន ឬក៏ទ្រព្យដែលទិញជាមួយប្រាក់ដែលបានមកពីផលចំណេញ នោះក៏ត្រូវបានចាត់ទុកជាទ្រព្យរួមផងដែរ។ ដោយហេតុថាផលចំណេញទាំងនោះមានលក្ខណៈជាទ្រព្យផ្ទាល់ខ្លួនរបស់សហព័ទ្ធនៅពេលដែលគាត់ទទួលបានក៏ពិតមែនក៏ប៉ុន្តែវាក្លាយទៅជាទ្រព្យរួមនៅពេលដែលសហព័ទ្ធយកប្រាក់ទាំងនោះទៅសន្សំសំចៃដើម្បីផ្គត់ផ្គង់គ្រួសារ។

<u>ឧទាហរណ៍៖</u> ប្តីធ្វើការជាមន្ត្រីរាជការ នឹងទទួលបានប្រាក់បៀវត្សចំនួន១លានរៀលក្នុងមួយខែក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់បៀវត្សរបស់ប្តី ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្តី និងប្រពន្ធ។ ក្នុងករណីប្រាក់ចំណូលដែលប្តីរកបានតែម្ខាង ហើយប្រពន្ធត្រឹមតែជាស្ត្រីមេផ្ទះ ធ្វើតែការងារគេហកិច្ច(ការងារក្នុងផ្ទះ) តើប្រាក់ចំណូលដែលប្តីរកបានតែម្ខាងត្រូវចាត់ទុកថាវាជាទ្រព្យរួម ឬទ្រព្យដោយឡែក? ជាគោលការណ៍ច្បាប់ការងារគេហកិច្ច(ការងារនៅក្នុងផ្ទះ) ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើនៅក្រៅផ្ទះដែរ មានន័យថា ប្តីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរកបានពីការងារក្រៅផ្ទះថាមិនមែនជាទ្រព្យរួម ឬបន្ថយសិទ្ធិរបស់

ប្រពន្ធលើចំណូលរបស់ខ្លួន ដោយសំអាងថាប្រពន្ធរបស់ខ្លួនធ្វើតែការងារផ្ទះ មើលថែទាំកូន ដាំស្ល បោកគក់... ។ល។ ដោយមិនបានប្រឡូកនឹងការងារខាងក្រៅ ដែលនឿយហត់ដូចការងាររបស់ខ្លួនឡើយ។ ចំពោះប្រាក់ឈ្នួលដែលបានមកពីការជួលផ្ទះ ដែលជាទ្រព្យរបស់ប្តី ឬ ប្រពន្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ តើយើងអាចចាត់ទុកថាជាទ្រព្យរួម ឬ ជាទ្រព្យដោយឡែក? ដូចនឹងឧទាហរណ៍ខាងលើដែលប្តីធ្វើការជាមន្ត្រីរាជការ និងទទួលបានប្រាក់បៀវត្ស ១លានរៀល ក្នុងមួយខែ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់បៀវត្សរបស់ប្តី ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្តីនិងប្រពន្ធ។ ស្របពេលគ្នានោះដែរប្តីក៏មានផ្ទះមួយល្វែងដែលជាទ្រព្យដោយឡែករបស់ខ្លួន ហើយប្តីបានដាក់ផ្ទះនោះជួលដើម្បីបាន ថ្លៃឈ្នួលប្រចាំខែ។ ដូច្នេះថ្លៃឈ្នួលប្រចាំខែ ដែលបានមកពីការជួលផ្ទះនោះ គេចាត់ទុកថាជាទ្រព្យរួមរបស់ប្តី និងប្រពន្ធ។

មូលហេតុនៃការទទួលស្គាល់នេះ ដោយផ្អែកទៅលើមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី ដែលមាត្រានេះចង់សំដៅថា ទ្រព្យទាំងឡាយដែលទទួលបាន ឬរកបានដោយសហព័ទ្ធដើម្បីផ្គត់ផ្គង់គ្រួសារ ចំណាយក្នុងការអប់រំ និងបណ្តុះបណ្តាលកូនត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរួម។ នៅក្នុងបញ្ញត្តិនៅក្នុងច្បាប់ខ្មែរយើង គឺមានលក្ខណៈមិនច្បាស់លាស់អំពីអត្ថសញ្ញាណនៃទ្រព្យរួមនេះ ដោយគ្មានមាត្រាណាមួយបញ្ជាក់ឲ្យបានច្បាស់តែម្តងអំពីប្រភេទនៃទ្រព្យរួមនេះឡើយ។ ការប្រើប្រាស់សិទ្ធិរបស់សហព័ទ្ធនីមួយៗអាចមានលក្ខណៈផ្តាច់មុខ ឬសហប្រតិបត្តិការណ៍គ្នា អាស្រ័យទៅលើការប្រតិបត្តិរបស់សហព័ទ្ធ។

### ១.២.១. ភាគព្វកិច្ចរួមប្តីប្រពន្ធ

នៅពេលដែលមានចំណងអាពាហ៍ពិពាហ៍កើតឡើងនោះ សហព័ទ្ធទាំងពីរត្រូវតែមានកាតព្វកិច្ចរួមគ្នា ហើយប្តីប្រពន្ធត្រូវតែរួមរស់ជីវភាពជាមួយគ្នា សហការគ្នា ជួយសង្គ្រោះគ្នាទៅវិញទៅមក [12] នៅក្នុងការផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ ការទទួលខុសត្រូវចំណូលចំណាយក្នុងគ្រួសារផងដែរ។ ចំណូលចំណាយក្នុងន័យនេះមានទាំង បន្ទុកគ្រួសារ និងបំណុលគ្រួសារ។

#### ក. បន្ទុកគ្រួសារ

##### ក.១. សញ្ញាណនៃបន្ទុកគ្រួសារ

បន្ទុកគ្រួសារ សំដៅទៅដល់សេចក្តីត្រូវការនៃការចំណាយទាំងឡាយដែលចាំបាច់សម្រាប់ចិញ្ចឹមជីវភាពរបស់សហព័ទ្ធទាំងពីរ ឬ/និង របស់កូនៗរបស់ពួកគេ ឬសមាជិកគ្រួសារផ្សេងទៀតដែលរស់នៅជាមួយពួកគេ។ បន្ទុកទាំងនេះ រមែងពាក់ព័ន្ធនឹងចំណាយលើការផ្គត់ផ្គង់ចំណីអាហារ (ដូចជាថ្លៃអង្ករ, ម្ហូប...) ការស្នាក់នៅ (ថ្លៃឈ្នួលផ្ទះ , ថ្លៃទឹក-ភ្លើង...) ការស្លៀកពាក់ មធ្យោបាយដឹកជញ្ជូន និងចំណាយ

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៦៦។

ទៅលើការសិក្សារបស់កូនៗជាដើម។ លក្ខខណ្ឌអត្ថិភាពនៃបន្ទុកគ្រួសារ គឺចំណងអាពាហ៍ពិពាហ៍ហើយត្រូវបញ្ចប់នៅពេលរំលាយចំណងអាពាហ៍ពិពាហ៍។

ចំពោះបន្ទុកនៃអាហារកាតព្វកិច្ចក៏ជាផ្នែកមួយនៃបន្ទុកគ្រួសារដែរដែលអាហារកាតព្វកិច្ចគឺជាជំនួយផ្នែកហិរញ្ញវត្ថុឲ្យដល់បុគ្គល( ជាទូទៅស្ថិតនៅក្នុងចំណោមញាតិ ) ដែលមិនអាចទ្រទង់ជីវភាពដោយសមត្ថភាពរបស់ខ្លួនឯងបាន។ ប៉ុន្តែដោយសារតែជំនួយនេះ ត្រូវបានកំណត់តម្រូវដោយច្បាប់ ដូចនេះវាក្លាយជាសិទ្ធិនិងករណីយកិច្ចតាមផ្លូវច្បាប់។

**ក.២. ភាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធចំពោះបន្ទុកគ្រួសារ**

នៅក្រោយពេលដែលរៀបអាពាហ៍ពិពាហ៍សហព័ទ្ធត្រូវបានដាក់ឲ្យស្ថិតនៅក្រោមរបបនៃកាតព្វកិច្ចដោយសាមគ្គីភាពចំពោះបន្ទុកនៃគ្រួសារ ដែលកើតមានចំពោះសហព័ទ្ធទាំងពីរ។ រាល់កាតព្វកិច្ចទាំងនោះ គឺតម្រូវឲ្យអ្នកទាំងពីរទទួលខុសត្រូវដោយសាមគ្គីភាពនូវរាល់ការចំណាយទៅលើការផ្គត់ផ្គង់ជីវភាព របស់អ្នកទាំងពីរ និងចំណាយក្នុងការថែទាំ អប់រំ ព្យាបាលកូនផងដែរ។[13] មួយវិញទៀតចំពោះការចំណាយនៃបន្ទុកដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរក៏ជាអ្នកមានកាតព្វកិច្ចសាមគ្គីឆ្លើយតបទៅនឹងបន្ទុកនេះដែរ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។

**ខ. បំណុលគ្រួសារ**

**ខ.១. សញ្ញាណនៃបំណុលគ្រួសារ**

បំណុលគ្រួសារ សំដៅដល់បំណុលទាំងឡាយណាដែលសហព័ទ្ធទាំងពីរបានបង្កើតឡើងក្នុងគោលបំណងដើម្បីជីវភាពក្នុងគ្រួសារ និងការសិក្សាអប់រំកូនចៅរបស់ពួកគេ។ តែចំពោះបំណុលដែលបង្កើតឡើងដោយសហព័ទ្ធតែម្ខាង នៅក្នុងគោលបំណងនៃផលប្រយោជន៍គ្រួសារ ក៏នឹងបង្កើតជាបំណុលគ្រួសារផងដែរ (ប៉ុន្តែត្រូវកម្រិតត្រឹមបំណុលដើម្បីជីវភាពគ្រួសារ មិនមែនបំណុលដើម្បីការវិនិយោគបង្កើនធនធានគ្រួសារឡើយ)។ មិនចាត់ទុកជាបំណុលគ្រួសារឡើយ ចំពោះ ៖

- បំណុលដែលកើតឡើងដោយការវិនិយោគរបស់សហព័ទ្ធណាម្នាក់ (លើកលែងតែមានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀត)

  ឧទាហរណ៍៖ ការចំណាយទិញអចលនវត្ថុដាច់ដោយឡែកពីលំនៅដ្ឋានគ្រួសារ
- បំណុលដែលកើតពីការចំណាយហួសហេតុ ឬលើសលុបរបស់សហព័ទ្ធម្ខាង

ឧទាហរណ៍៖ ការចំណាយទិញពេជ្រ ឬសម្ភារៈថ្លៃកប់ពពក ជាដើម។ មានលក្ខណៈវិនិច្ឆ័យមួយចំនួនដែលអាចឲ្យកំណត់បានថាជាការចំណាយនោះលើសលុបឬក៏ហួសហេតុពីសេចក្តីត្រូវការគ្រួសារគឺគេមើល

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៥។

ទៅលើប្រភពធនធានដែលសហព័ទ្ធម្នាក់ៗរកបាន (ចាយខ្ពស់ជាងចំណូល) និងមើលពីចរិតលក្ខណៈចាំបាច់ ឬមិនចាំបាច់នៅក្នុងការចំណាយ។ ដូចគ្នាដែរការសុំខ្ចីប្រាក់អាចចាត់ចូលជាបំណុលគ្រួសារបើវាមានចំនួនសមល្មមហើយធ្វើឡើងដើម្បីត្រូវការនៃជីវភាពគ្រួសារ។ ដូចនេះការចំណាយលើការវិនិយោគ និងការចំណាយលើសលុបរបស់សហព័ទ្ធ មិនស្ថិតនៅក្នុងបំណុលគ្រួសារទេ ហើយសហព័ទ្ធណាម្ខាងដែលបង្កើតចំណាយនេះត្រូវទទួលខុសត្រូវដោយទ្រព្យដោយឡែករបស់ខ្លួន។

**ខ.២. កាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធចំពោះបំណុលគ្រួសារ**

កាតព្វកិច្ចដោយសាមគ្គីភាពមានអត្ថន័យថានៅក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចដោយសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ឬឲ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគដោយព្រមគ្នា ឬដោយបន្តបន្ទាប់។ និងនៅក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចទាំងអស់ ឬកូនបំណុលណាម្នាក់ត្រូវបានប្រកាសក្ស័យធន ម្ចាស់បំណុលអាចចូលរួម ក្នុងការចែកចំណែកនៅក្នុងនីតិវិធីក្ស័យធនរបស់កូនបំណុលនីមួយៗចំពោះចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន។[14]

ដូចនេះកាតព្វកិច្ច ដែលសហព័ទ្ធត្រូវតែធ្វើដោយសាមគ្គីភាព គឺត្រូវតែជាការចំណាយដែលចាំបាច់ដើម្បីរក្សាជីវភាពគ្រួសារ (បន្ទុកគ្រួសារ) និង កាតព្វកិច្ចដែលសហព័ទ្ធទាំងពីរ ឬសហព័ទ្ធណាម្ខាងដែលត្រូវទទួលបន្ទុកនូវការចំណាយបានព្រមព្រៀងជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

ចំណាំ៖ បន្ទុកគ្រួសារ និងបំណុលគ្រួសារ មានភាពលាយឡំគ្នាដែលធ្វើឲ្យពិបាកបែងចែកឲ្យដាច់ពីគ្នាដោយហេតុថាក្រមរដ្ឋប្បវេណីពុំបានកាត់ផ្តាច់ឲ្យបានច្បាស់លាស់ឡើយ។ ចំពោះបន្ទុកគ្រួសារអាចជាការចំណាយចាំបាច់ប្រចាំថ្ងៃដើម្បីទ្រទ្រង់ជីវភាពសហព័ទ្ធ និងគ្រួសារទាំងមូល ចំណែកបំណុលគ្រួសារ គឺកើតចេញពីឆន្ទៈច្បាស់រវាងសហព័ទ្ធទាំងពីរនៅក្នុងការបង្កើត។

ជារួមមកសហព័ទ្ធឬប្តីប្រពន្ធត្រូវមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដែលកាតព្វកិច្ចនោះមាន៖

- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំឬព្យាបាលកូន
- សោហ៊ុយក្នុងការគ្រប់គ្រងទ្រព្យរួម
- កាតព្វកិច្ច និងករណីផ្សេងៗទៀត ដែលប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នាជាលិខិតលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩២១។

- កាតព្វកិច្ច និងករណីផ្សេងៗទៀត ដែលប្តី ឬប្រពន្ធណាម្នាក់បានទទួលបន្ទុកសោហ៊ុយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរពីប្តី ឬ ប្រពន្ធម្ខាងទៀតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[15]

### ១.២.២. ការគ្រប់គ្រង និងចាត់ចែងទ្រព្យរួម

នៅពេលខ្លះសហព័ទ្ធពុំដែលចាប់អារម្មណ៍ពីបញ្ហានៃការគ្រប់គ្រងទ្រព្យសម្បត្តិដែលពួកគាត់មានឡើយដែលអាចជាបញ្ហានៅពេលដែលមានវិវាទកើតឡើង។ សកម្មភាពមួយចំនួន គឺបានកើតឡើងដោយស្វ័យប្រវត្តិ ពុំបានចាប់អារម្មណ៍ឡើយថាទ្រព្យសម្បត្តិទាំងនោះ គាត់មានសិទ្ធិសម្រេចដោយខ្លួនឯងឬក៏ពិភាក្សាគ្នា។ នៅពេលខ្លះវាអាចមានវិវាទកើតឡើង ដែលជាវិបត្តិនៅក្នុងគ្រួសារ ជាពិសេសគឺជីវិតនៃអាពាហ៍ពិពាហ៍នៅពេលដែលសហព័ទ្ធណាម្ខាងបានបំពារបំពានសិទ្ធិរបស់ខ្លួននៅក្នុងការប្រើប្រាស់ គ្រប់គ្រង ឬក៏មានការចាត់ចែងទ្រព្យសម្បត្តិនោះដោយឯកតោភាគី។ ដោយសារតែមាននូវបញ្ហានេះហើយ ជាដំណោះស្រាយទើបមានលេចឡើងនូវច្បាប់ដើម្បីមកការពារ ចាប់តាំងពីច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសាររហូតមកដល់ក្រមរដ្ឋប្បវេណី។ ក្រមរដ្ឋប្បវេណីមិនត្រឹមតែជាច្បាប់ដែលមានចែងពីប្រភេទឬចំណាត់ថ្នាក់នៃទ្រព្យសម្បត្តិនោះទេ តែក៏មានចែងពីរបៀបនៃការ ប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធដែរ ដោយទ្រព្យមួយចំនួនមានការគ្រប់គ្រងដោយឯករាជ្យ ហើយទ្រព្យសម្បត្តិមួយចំនួនទៀតបានធ្វើការគ្រប់គ្រងដោយសហការណ៍គ្នា រួមទាំងសិទ្ធិនៅក្នុងការចាត់ចែងទ្រព្យសម្បត្តិផងដែរ។

#### ក. ការប្រើប្រាស់ទ្រព្យសម្បត្តិដោយឯករាជ្យ

ត្រង់ចំណុចនេះសហព័ទ្ធទាំងពីរមានសិទ្ធិស្មើគ្នានៅក្នុងការប្រើប្រាស់ អាស្រ័យផលទ្រព្យនោះដោយឯករាជ្យ បានសេចក្តីថាសហព័ទ្ធទាំងពីរមានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលរកបានមកជាមួយគ្នា ឬភាគីណាមួយរកបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ ការប្រើប្រាស់ដោយឯករាជ្យនូវទ្រព្យសម្បត្តិត្រង់ចំណុចនេះត្រូវតែក្នុងគោលបំណងដើម្បីផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារនិងកូន ដែលជាកាតព្វកិច្ចរួមរបស់សហព័ទ្ធដែលបានបកស្រាយនូវខាងលើរួចមកហើយ។

លើសពីនេះសហព័ទ្ធម្នាក់ៗ អាចប្រើប្រាស់សម្ភារៈដែលជាទ្រព្យសម្បត្តិរួមតាមតម្រូវការនៃសម្ភារៈនោះបាន ព្រោះថាសហព័ទ្ធទាំងពីរត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមនោះជាមួយគ្នា។ ការទាមទារឲ្យសហព័ទ្ធម្នាក់ទៀតយល់ព្រមលើវិធានការចាំបាច់ ដើម្បីថែទាំទ្រព្យសម្បត្តិរួម រក្សាទុកតម្លៃរបស់ទ្រព្យសម្បត្តិទាំងនោះ ជាសិទ្ធិរបស់សហព័ទ្ធ ដោយឈរលើគោលការណ៍នៃការព្រមព្រៀងគ្នា។[16] គោលការណ៍នៃការគ្រប់គ្រង

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៥។
[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៦។

ទ្រព្យសម្បត្តិដែលមានលក្ខណៈផ្តាច់មុខ ជាសិទ្ធិរបស់សហព័ទ្ធក្នុងការផ្ទេរសិទ្ធិរបស់ខ្លួនទៅឲ្យសហព័ទ្ធម្នាក់ទៀត។

**ខ. ការប្រើប្រាស់សិទ្ធិដោយសហការណ៍**

គោលការណ៍នៃការគ្រប់គ្រងដោយសហការណ៍គ្នា[17] គឺជាគោលការណ៍ដែលសហព័ទ្ធទាំងពីរត្រូវធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរួមនោះជាមួយគ្នា មិនមែនគ្រប់គ្រងតែម្នាក់ឯង ហើយម្នាក់ទៀតគ្មានសិទ្ធិនៅក្នុងការគ្រប់គ្រងនោះទេ។ ក្នុងករណីមានវិវាទទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរួម ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ អាចមានសិទ្ធិធ្វើការស្នើសុំទៅតុលាការ ដើម្បីធ្វើការចាត់ចែងចំពោះការគ្រប់គ្រងនិងប្រើប្រាស់ទ្រព្យរួមទាំងនោះ។

សិទ្ធិចាត់ចែង ជាគោលការណ៍ ត្រូវមានការយល់ព្រមរវាងសហព័ទ្ធដើម្បីធ្វើការចាត់ចែងនូវទ្រព្យរួមនោះ។ តែការចាត់ចែងក៏អាចធ្វើទៅបានបើទោះបីជាពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតក៏ដោយដោយសហព័ទ្ធអាចធ្វើការចាត់ចែងបានផងដែរ លុះត្រាតែបំពេញលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណី ដែលលក្ខខណ្ឌទាំងនោះមាន ៖

-ស្ថិតនៅក្នុងស្ថានភាពចាំបាច់មិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងចំណងអាពាហ៍ពិពាហ៍និងដើម្បីរក្សាជីវភាពរស់នៅ

-និងត្រូវមានការស្នើសុំការអនុញ្ញាតពីតុលាការទៅលើការចាត់ចែងទ្រព្យរួមនោះ។

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធទាំងពីរ ដូចនេះជាគោលការណ៍ ប្តី ឬប្រពន្ធតែម្ខាងមិនអាចយកទ្រព្យសម្បត្តិរួមនោះទៅលក់ ឬចាត់ចែងផ្សេងទៀតបានឡើយ ប្រសិនបើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាង។ ការកំណត់បែបនេះ ដើម្បីធានានូវស្ថេរភាពនៃទ្រព្យសម្បត្តិគ្រួសារផងដែរ។

<u>ឧទាហរណ៍</u>៖ លោក កុសល និងនាង ធីតា បានរៀបអាពាហ៍ពិពាហ៍ក្លាយជាប្តីប្រពន្ធនិងគ្នា។ នៅថ្ងៃមួយជាអកុសលនាង ធីតាបានធ្លាក់ខ្លួនឈឺជាទម្ងន់ ត្រូវធ្វើការសង្គ្រោះជាបន្ទាន់ ហើយត្រូវការចំណាយលុយជាច្រើនក្នុងការព្យាបាល ទាំងថ្លៃពេទ្យ ថ្លៃថ្នាំ ថ្លៃព្យាបាល ថ្លៃសម្រាកក៏ដូចជាម្ហូបអាហារ។ អ្នកទាំងពីរមានដីមួយកន្លែងដែលជាទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ។ លោកកុសល ដែលជាប្តីក៏បានធ្វើការចាត់ចែងក្នុងការលក់ដីមួយកន្លែងនោះ ដោយគ្មានការយល់ព្រមពីនាងធីតាដែលជាប្រពន្ធឡើយ ព្រោះហេតុថាក្នុងករណីនេះ នាងធីតា កំពុងតែសម្រាកព្យាបាលជម្ងឺ និងមិនមានលទ្ធភាពក្នុងការបង្ហាញឆន្ទៈក្នុងការព្រមលក់នោះឡើយ លោកកុសលក៏បានធ្វើការលក់ដីនោះដោយឆន្ទៈតែម្ខាង។ ត្រង់ចំណុចនេះ គេអាចទទួលស្គាល់បានថា ករណីខាងលើគឺស្ថិតនៅក្នុងស្ថានភាពមិនអាចជៀសវាងបានដើម្បីជីវភាពរួមក្នុងអាពាហ៍ពិពាហ៍។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៤។

ម្យ៉ាងវិញទៀតប្រសិនបើសហព័ទ្ធណាម្ខាងបានធ្វើការលក់ ឬចាត់ចែងទ្រព្យរួមនោះ ដោយមិនបានគោរពលក្ខខណ្ឌខាងលើទេ និងគ្មានការអនុញ្ញាតពីតុលាការទេនោះ សហព័ទ្ធដែលមិនបានធ្វើការយល់ព្រមមានសិទ្ធិប្តឹងទៅតុលាការដើម្បីធ្វើការលុបចោលការចាត់ចែងនោះ ក្នុងអំឡុងពេលដូចខាងក្រោម ៖

-រយៈពេល ២ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ ប្រសិនបើទ្រព្យជាអចលនវត្ថុសម្រាប់អាស្រ័យនៅរបស់គ្រួសារ

-រយៈពេល ១ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ ប្រសិនបើទ្រព្យសម្បត្តិផ្សេងទៀត ។

### ១.២.៣. ការប្រែក្លាយទ្រព្យដោយឡែកទៅជាទ្រព្យរួម

មានគេនិយាយថាជីវិតអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធនៅពេលដំបូង ផ្អែមដូចស្ករបេះមិនរបូតពីគ្នានោះទេ ប៉ុន្តែនៅពេលដែលជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ កាន់តែយូរទៅអ្នកខ្លះក៏នូវល្អដូចដើម អ្នកខ្លះទៀតក៏លែងចុះសម្រុងនិងគ្នា ហើយអាចឈានដល់ការបញ្ចប់ក៏មានដែរ។ កាលណាជីវិតអាពាហ៍ពិពាហ៍កាន់តែយូរភាពច្របល់ចូលគ្នានៃទ្រព្យសម្បត្តិដោយឡែក (ទ្រព្យសម្បត្តិផ្ទាល់ខ្លួន) និងទ្រព្យសម្បត្តិរួមក៏កាន់តែស្មុគស្មាញ។ នៅក្នុងក្រម ឬនៅក្នុងច្បាប់ផ្សេងទៀត មិនមានចែងពីបញ្ហានេះឡើយ។ ប៉ុន្តែមានអ្នកច្បាប់ជាច្រើនបានព្យាយាមបកស្រាយដោយប្រដូចទៅនឹងទំនាក់ទំនងគតិយុត្តិផ្សេងៗ ដើម្បីប្រែក្លាយទ្រព្យដោយឡែកទៅជាទ្រព្យរួមមានដូចជា ការព្រមព្រៀងរបស់សហព័ទ្ធ កម្មសិទ្ធិអវិភាគ ។

#### ក. ការព្រមព្រៀងរបស់សហព័ទ្ធ

ជាទូទៅនៅក្នុងក្រមរដ្ឋប្បវេណី តែងតែគោរពនូវស្វ័យភាពនៃបុគ្គលឯកជន[18] ។ ហេតុនេះបើទោះជាទ្រព្យនោះជាទ្រព្យដោយឡែករបស់សហព័ទ្ធក៏ដោយ ក៏អាចប្រែក្លាយទៅជាទ្រព្យរួមបានដែរ។

<u>ឧទាហរណ៍៖</u> បុរស ក និង នារី ខ ជាប្តីប្រពន្ធនិងគ្នា។ មុនពេលរៀបអាពាហ៍ពិពាហ៍នាង ខ ដែលជាប្រពន្ធមានដីពីរកន្លែងដែលជាទ្រព្យដោយឡែករបស់នាង។ ដោយឃើញស្វាមីរបស់នាងពិតជាស្រឡាញ់នាងដោយស្មោះត្រង់ ខិតខំធ្វើការ នាងក៏បានធ្វើការសម្រេចចិត្តដាក់ដីពីរកន្លែងនោះដែលជាទ្រព្យដោយឡែកទៅជាទ្រព្យសម្បត្តិរួម។ ក្នុងករណីនេះគ្មានច្បាប់ណាមួយចែងមិនឲ្យមានការផ្ទេរទ្រព្យដោយឡែកទៅទ្រព្យរួមឡើយ ព្រោះវាជាការបង្ហាញឆន្ទៈរបស់នាង ខ ក្នុងការសម្រេចចិត្តដោយខ្លួនឯង គ្មានអ្នកណាបង្ខំនាងឡើយ។

#### ខ. កម្មសិទ្ធិអវិភាគ

ទ្រព្យសម្បត្តិជាទ្រព្យដោយឡែក ប៉ុន្តែមានការប្រើប្រាស់ ឬមានការលាយចូលគ្នា នូវទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀត ឬទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធ ក្នុងការថែរក្សា ជួសជុល នោះវាក៏អាចជាកត្តាមួយដែលប្រែក្លាយទ្រព្យដោយឡែកទៅជាទ្រព្យរួមផងដែរ។

---

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៣។

ឧទាហរណ៍៖ បុរស ក និង នារី ខ ជាប្តីប្រពន្ធនិងគ្នាដដែល។ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ បុរស ក មានផ្ទះចាស់មួយខ្នងដែលទទួលបានពីឪពុកម្តាយ ហើយនារី ខ មានលុយចំនួន។ នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ផ្ទះរបស់បុរស ក នោះក៏បានខូចខាតធ្ងន់ធ្ងរគួរសមដែរ ហើយត្រូវការជួសជុល ដោយនារី ខ បានឃើញហើយមិនចង់បាត់បង់ផ្ទះនោះដែរជាមរតកដែលឪពុកម្តាយបន្សល់ទុកឲ្យប្តីរបស់ខ្លួន នាងក៏បានយកលុយដែលនាងមានមុនពេលរៀបអាពាហ៍ពិពាហ៍នោះយកទៅជួសជុលផ្ទះដែលខូចខាតនោះ។ ក្នុងករណីនេះផ្ទះមួយខ្នងរបស់លោក ក ក៏អាចប្រែក្លាយទៅជាកម្មសិទ្ធិអវិភា [19] ជាមួយប្រពន្ធគឺនារី ខ។ ដូចនេះផ្ទះមួយខ្នងនោះប្រែក្លាយទៅជាទ្រព្យរួមរវាង បុរស ក និងនាង ខ ទោះបីជាទ្រព្យនោះជាទ្រព្យដោយឡែករបស់ប្តី ប៉ុន្តែនាងបានយកទ្រព្យរបស់នាងទៅជួយជួសជុល និងថែរក្សាផ្ទះមួយនោះ។

## ផ្នែកទី២៖ ការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់ដោយច្បាប់

ការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់ គឺជាការបិទបញ្ចប់នូវរបបនីត្យានុកូលសហគមន៍រវាងសហព័ទ្ធទាំងពីរ វាមានមូលហេតុជាច្រើនដែលធ្វើឲ្យរបបនេះត្រូវបានបញ្ចប់។ ការដែលបញ្ចប់នូវរបបនេះមិនត្រឹមតែមានអានុភាពចំពោះសហព័ទ្ធប៉ុណ្ណោះទេ គឺវាមានអានុភាពដល់តតិយជនផងដែរ។ ពេលដែលរបបនីត្យានុកូលសហគមន៍នេះត្រូវបានបញ្ចប់ សហព័ទ្ធត្រូវតែធ្វើការជម្រះបញ្ជីសារពើព័ន្ធនៃទ្រព្យទាំងឡាយដែលកើតមាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ មូលហេតុដែលនាំឲ្យមាននូវការជម្រះបញ្ជីនោះមានដូចខាងក្រោម។

### ២.១. មូលហេតុនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

មូលហេតុទាំងនោះរួមមាន៖

#### ២.១.១. មរណភាពនៃសហព័ទ្ធម្ខាង

នៅពេលដែលមរណភាពត្រូវបានចុះកំណត់ហេតុដោយមន្ត្រីអត្រានុកូលដ្ឋានវាបណ្តាលឲ្យរំលាយនៃរបបនីត្យានុកូលសហគមន៍ ដោយស្វ័យប្រវត្តិ។ មរណភាពនេះបានផ្តល់នូវអត្ថប្រយោជន៍មួយចំនួនចំពោះសហព័ទ្ធដែលនៅរស់ ដូចជានៅមាត្រា ៩៥០ និងបន្តបន្ទាប់នៃក្រមរដ្ឋប្បវេណី នៅករណីពិសេសចំពោះការមិនហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍ រវាងសាខាញាតិ ទោះសាខាញាតិ ឬញាតិពន្ធក្តីរហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ផង។ ក្នុងករណីដែលសហព័ទ្ធណាម្ខាង បានទទួលមរណភាពសហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ ជាមួយសាខាញាតិពន្ធនៅក្នុងថ្នាក់ទី៣បាន។ [20] ម្យ៉ាងទៀតសហព័ទ្ធ

---

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ២០២។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៥២។

ដែលនៅរស់ គឺអាចទទួលបាននូវផលប្រយោជន៍តាមរយៈរបបសន្តតិកម្ម ដែលគាត់ចូលប្រកួតប្រជែងជាមួយសន្តតិជន ក្នុងនាមជាសន្តតិជនជានិច្ចនៃមតកជនទៀតផង។

### ២.១.២. ការបាត់ខ្លួននៃសហព័ទ្ធម្ខាង

យោងតាមមាត្រា ៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានបាត់ខ្លួនលើសពីប្រាំឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមកដោយគ្មានដំណឹងអ្វីសោះ ហើយក៏គ្មាននរណាដឹងថាជននោះស្លាប់ឬរស់ សហព័ទ្ធម្ខាងទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន។ ជនណាក៏ដោយមិនអាចប្តឹងសុំបដិសេធអាពាហ៍ពិពាហ៍ថ្មីនោះបានឡើយ ទោះបីសហព័ទ្ធដែលបានបាត់ខ្លួននោះត្រឡប់មកវិញក៏ដោយ ។[21] នេះបានបញ្ជាក់ឲ្យឃើញថា ក្នុងករណីដែលសហព័ទ្ធនោះ បានត្រលប់មកវិញក្រោយថ្ងៃដែលតុលាការប្រកាសសាលក្រមបាត់ខ្លួន អាពាហ៍ពិពាហ៍មុន ត្រូវបានរលាយបាត់។ ចំណែកឯសមត្ថកិច្ចរបស់តុលាការក្នុងការប្តឹងនូវការបាត់ខ្លួននេះ ជាសមត្ថកិច្ចរបស់តុលាការនៃលំនៅដ្ឋានចុងក្រោយបង្អស់របស់សហព័ទ្ធដែលបានបាត់ខ្លួននោះ។

### ២.១.៣. ការលែងលះ

ដោយផ្អែកទៅលើមាត្រា ៣៨ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ បានឲ្យនិយមន័យយ៉ាងច្បាស់អំពីការលែងលះ ដោយថាការលែងលះ ជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងពេលរស់នៅជាមួយគ្នា។ ចំណែកនៅក្នុងក្រមរដ្ឋប្បវេណីវិញពុំបានឲ្យនិយមន័យនៃការលែងលះនោះទេ។ សហព័ទ្ធទាំងពីរដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែរស់នៅមិនសមប្រកបអាចសម្រេចចិត្ត លែងលះគ្នាដោយការព្រមព្រៀង [22] ឬដោយលើកមូលហេតុនៃការលែងលះបានដូចមានចែងនូវមាត្រា ៩៧៨ នៃ ក្រមរដ្ឋប្បវេណី។

សរុបមកក្រៅពីមូលហេតុធំៗទាំងបីនេះហើយ តាមច្បាប់បាននិយាយថា មោឃភាព ឬការលុបចោលអាពាហ៍ពិពាហ៍ ក៏អាចជាមូលហេតុនៃការរលាយចំណងអាពាហ៍ពិពាហ៍ផងដែរ នៅរាល់ពេលដែលអាពាហ៍ពិពាហ៍ទាំងឡាយណា ច្បាប់បានហាមឃាត់ ឬមិនបានបំពេញលក្ខខណ្ឌគ្រឹះ ឬទម្រង់ណាមួយដែលបណ្តាលឲ្យអាពាហ៍ពិពាហ៍ត្រូវបានមោឃភាព ឬលុបចោល។

## ២.២. អានុភាពនៃការរលាយបាត់នូវរបបទ្រព្យសម្បត្តិសហព័ទ្ធ

ទ្រព្យសម្បត្តិប្តីប្រពន្ធនឹងត្រូវធ្វើការជម្រះបញ្ជី នៅពេលដែលចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធត្រូវបានរលាយ ដោយលើកមូលហេតុសហព័ទ្ធណាម្ខាងមរណភាព ឬដោយការលែងលះ ឬមោឃភាព

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៥៤។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៧៩។

អាពាហ៍ពិពាហ៍សហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន តែចំពោះស្ត្រីត្រូវស្ថិតនៅក្នុងវិធិនភាព ១២០ថ្ងៃគិតចាប់ពីពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ អានុភាពមួយទៀតគឺចំពោះទំនាក់ទំនងញាតិពន្ធក្នុងករណីលែងលះត្រូវបានបញ្ចប់ ប៉ុន្តែក្នុងករណីនៃការមរណភាព ឬការបាត់ខ្លួនវិញ ទំនាក់ទំនងញាតិពន្ធមិនត្រូវបានបញ្ចប់នោះទេ លើកលែងតែសហព័ទ្ធដែលនៅរស់នោះបានបង្ហាញឆន្ទៈចង់បញ្ចប់ទំនាក់ទំនងនោះខ្លួនឯង ឬការរៀបអាពាហ៍ពិពាហ៍ថ្មីធ្វើឲ្យអាពាហ៍ពិពាហ៍មុនត្រូវបញ្ចប់។ ឈ្មោះរបស់សហព័ទ្ធអាចនៅបន្តដោយតណ្ហីភាពក្នុងករណីសហព័ទ្ធទាំងពីរលែងលះគ្នា។[23]

ម៉្យាងទៀតអានុភាពនៃការលែងលះ នាំឲ្យអានុភាពនៃចំណងអាពាហ៍ពិពាហ៍ត្រូវបានរលាយចាប់តាំងពីថ្ងៃដែលសាលក្រមនៃការលែងលះនោះចូលជាស្ថាពរ។ ជាពិសេសអានុភាពដ៏សំខាន់នៃការរលាយនូវរបបសហគមន៍គឺវាបានផ្តល់កំណើតដល់សមាសភាពអវិភាគនៃទ្រព្យសម្បត្តិ មិនថាទ្រព្យនោះជាទ្រព្យដោយឡែក ឬទ្រព្យរួម បានន័យថាការជម្រះបញ្ជីទ្រព្យសម្បត្តិ ត្រូវបានបិទក្នុងការធ្វើសម្រង់ ឬកត់ចំនួនទ្រព្យសម្បត្តិ ដោយសហព័ទ្ធទាំងពីរ មិនអាចប៉ះពាល់អ្វីទាំងអស់លើទ្រព្យផ្ទាល់ខ្លួន និងទ្រព្យរួមរហូតដល់មានសាលក្រមលែងលះរបស់តុលាការដែលសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិទាំងនោះ។

## ២.៣. យន្តការនៃការជម្រះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

ការជម្រះបញ្ជី គឺគ្រាន់តែជាអានុភាពនៃការបិទបញ្ចប់ទៅនៃទំនាក់ទំនងប្តីប្រពន្ធ ឬអាចថាជាការរំលាយ(បំបែក) គ្រួសាររបស់សហព័ទ្ធទាំងពីរ។ដំណើរការជម្រះបញ្ជីទ្រព្យសម្បត្តិទាំងនេះ អាចធ្វើការបែងចែកជាពីរ ជំហាន ដោយជំហានទី១ ការបែងចែកទ្រព្យសម្បត្តិ និងជំហានទី២ ការទូទាត់សងគ្នាទៅវិញទៅមក។

### ២.៣.១. ការបែងចែកទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិគ្នារវាងសហព័ទ្ធទាំងពីរ គឺជាការបែងចែកទ្រព្យសម្បត្តិរវាងប្តី និងប្រពន្ធពោលគឺជាការបែងចែកនូវទ្រព្យសកម្ម និងទ្រព្យអកម្ម។

#### ក. ទ្រព្យសកម្ម

ការបែងចែកទ្រព្យនៅក្នុងករណីមោឃភាព ឬការលុបចោលគឺផ្អែកទៅលើគោលការណ៍នៃការបែងចែកទ្រព្យដែលមានចែងនៅក្នុងការលែងលះ។ ជាបឋមការបែងចែកទ្រព្យសម្បត្តិ ត្រូវឈរទៅលើគោលការណ៍នៃការព្រមព្រៀងភាគីទាំងសងខាង តែបើគ្មានការព្រមព្រៀង សហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យដោយឡែកដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមរតកក្តី ជាអំណោយក្តី ឬជាអច្ច័យទានក្តីក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ មិនតែប៉ុណ្ណោះសហព័ទ្ធម្នាក់ៗមានសិទ្ធត្រូវបានទ្រព្យរួមម្នាក់ពាក់កណ្តាល។ ប៉ុន្តែបើតាមករណីពិសេស និងសំណើររបស់សហព័ទ្ធណាមួយចៅក្រមអាចសម្រេចសេចក្តី

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៨១។

ចែកទ្រព្យសម្បត្តិរួមនោះផ្សេងបានពីករណីខាងលើ ដោយគិតទៅលើផលប្រយោជន៍របស់កុមារ ស្ថានភាពផ្លូវចិត្តស្ថានភាពសេដ្ឋកិច្ចរបស់សហព័ទ្ធនីមួយៗ រួមទាំងស្ថានភាពផ្សេងទៀតអាចជា អាយុ មុខរបរ ព្រមទាំងគោលការណ៍ធម្មនុញ្ញភាព ដែលការងារគេហកិច្ចមានតម្លៃស្មើនឹងការងារផលិតកម្ម ដើម្បីផ្តល់ផលប្រយោជន៍ដល់សហព័ទ្ធដែលត្រូវទទួលបន្ទុកលើការងារគេហកិច្ចនេះ។

**ខ. ទ្រព្យអកម្ម ឬបំណុល**

ដូចគ្នាដែរទ្រព្យសកម្ម ឬទ្រព្យសម្បត្តិក្នុងគ្រួសារ ត្រូវបានចាត់ទុកថាជាបំណុលរួម ហើយបន្ទុកត្រូវធ្លាក់ទៅលើទ្រព្យសម្បត្តិរួម ចំពោះបំណុល ឬកាតព្វកិច្ចទាំងឡាយណា ដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬសហព័ទ្ធណាម្នាក់បានសម្រេចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ ក្នុងករណីនេះ មុននឹងអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមបានសហព័ទ្ធទាំងពីរត្រូវតែជម្រះបញ្ជីឲ្យអស់ និងសងបំណុលទាំងអស់ដែលមានការទាមទារពីម្ចាស់បំណុល។ ជាទូទៅនៅមុនពេលដែលតុលាការសម្រេចអំពីការលែងលះ ឬការបែងចែកទ្រព្យសម្បត្តិរួមតុលាការត្រូវតែគិតមើលអំពីបំណុលដែលសហព័ទ្ធទាំងពីរ ឬសហព័ទ្ធណាម្ខាងបានបង្កើតឡើងក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ដើម្បីអាចធ្វើការទូទាត់សងជូនទៅម្ចាស់បំណុលដែលបានទាមទារនូវបំណុលរបស់ខ្លួន។ តែប្រសិន បើតុលាការ បានសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក៏ដោយ ក៏ម្ចាស់បំណុលនៅតែមានសិទ្ធិប្តឹងទាមទារសហព័ទ្ធណាម្នាក់សងបំណុលរបស់ខ្លួន ហើយសហព័ទ្ធដែលបានយកទ្រព្យរបស់ខ្លួនទៅសងនោះ អាចប្តឹងទៅសហព័ទ្ធម្ខាងទៀតធ្វើការទូទាត់សងមកខ្លួនវិញ។

គោលការណ៍នៃការជម្រះបញ្ជីទ្រព្យអកម្ម គឺដូចការអនុវត្តការជម្រះបញ្ជីនៃទ្រព្យសកម្មដែរ ដោយទ្រព្យសម្បត្តិរួមត្រូវបានបែងចែកទៅតាមការព្រមព្រៀងគ្នារវាងសហព័ទ្ធទាំងពីរ ហើយសហព័ទ្ធម្នាក់ៗត្រូវបានទ្រព្យសម្បត្តិរួមនោះម្នាក់ពាក់កណ្តាល។ ប៉ុន្តែបើមានករណីពិសេស ឬមានការស្នើសុំរបស់សហព័ទ្ធណាមួយ តុលាការអាចនឹងធ្វើការបែងចែកទ្រព្យនោះតាមគោលការណ៍ផ្សេងបាន ដោយត្រូវតែគិតពីផលប្រយោជន៍កូន និងផលិតកម្ម រួមទាំងស្ថានភាពពិសេសដែលក្រមរដ្ឋប្បវេណីបានចែងដូចជាអាយុការងារបញ្ហាសុខភាពជាដើម។ ចំណែកឯបំណុលរួមវិញ សហព័ទ្ធនីមួយៗត្រូវចូលរួមក្នុងការសងបំណុលនោះតាមចំណែកម្នាក់ពាក់កណ្តាលស្មើៗគ្នា លើកលែងតែមានការព្រមព្រៀងផ្សេងដូចជា ករណីមានការយល់ព្រមគ្នារវាងសហព័ទ្ធទាំងពីរចំពោះការធ្វើការបែងចែកមិនស្មើគ្នា ឬការសម្រេចពីការសងបំណុលរួមនោះដោយសហព័ទ្ធតែម្ខាង។ ចំពោះបំណុលដែលបានកើតមានឡើងដោយសហព័ទ្ធណាម្ខាង មានលក្ខណៈផ្ទាល់ខ្លួននោះ ក្រោយពីសម្រេចនៃការលែងលះ ឬរំលាយចំណងអាពាហ៍ពិពាហ៍សហព័ទ្ធទាំងពីរមានសិទ្ធិអាចសងបំណុលនោះត្រឹមតែទ្រព្យដោយឡែករបស់ខ្លួនតែប៉ុណ្ណោះ ដោយគ្មានការជាប់ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្នាក់

ទៀតទេ។ បើក្នុងករណីដែលបំណុលនោះត្រូវបានសងដោយទ្រព្យរួម ឬទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀត សហព័ទ្ធនោះត្រូវតែធ្វើការទូទាត់សងអំពីបំណុលនោះ លើកលែងតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតនោះ។

### ២.៣.២. ការទូទាត់សងគ្នាទៅវិញទៅមក

#### ក. និយមន័យនៃការទូទាត់សង

ការទូទាត់សង ជាការទូទាត់ចំពោះសិទ្ធិ និងបំណុលដែលអាចកើតមានឡើងរវាងសហគមន៍ និងសហព័ទ្ធម្នាក់ៗ ក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ កាលបើមានប្រតិបត្តិការណាមួយ (ឧទាហរណ៍៖ ការចំណាយ ឬការចាត់ចែងទ្រព្យណាមួយ) ដែលនាំឲ្យចំណេញ ឬខាតបង់នូវទ្រព្យសហគមន៍ ពីការប្រើប្រាស់ទ្រព្យដោយឡែករបស់សហព័ទ្ធណាម្នាក់ ឬផ្ទុយមកវិញ។ បញ្ហាសំខាន់ដែលចោទឡើងជាញឹកញាប់ចំពោះការទូទាត់សងនោះ គឺបញ្ហាទាក់ទងនឹងសិទ្ធិដែលទទួលបានក្នុងការទូទាត់សង និងការអនុវត្តនូវការទូទាត់សង។

#### ខ. សិទ្ធិក្នុងការទទួលបាននូវការទូទាត់

នៅក្នុងពេលដែលមានការជម្រះបញ្ជីលើទ្រព្យសម្បត្តិ មូលហេតុនៃការទូទាត់សង ដែលនាំឲ្យមានការទូទាត់សង អាចលេចឡើងក្នុងករណីពីរគឺ ករណីដែលសហព័ទ្ធម្នាក់យកទ្រព្យសម្បត្តិរួម ទៅចំណាយផ្ទាល់ខ្លួនដែលក្នុងនោះខ្លួនត្រូវធ្វើការទូទាត់សងការចំណាយរបស់ខ្លួនទៅឲ្យសហគមន៍វិញ និងករណីមួយទៀតដោយសហគមន៍ យកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហព័ទ្ធណាម្ខាងទៅចំណាយដើម្បីផលប្រយោជន៍របស់សហគមន៍សហព័ទ្ធនោះអាចទាមទារឲ្យសហគមន៍ ធ្វើការទូទាត់សងនូវការចំណាយរបស់ខ្លួនបាន។ និងករណីចុងក្រោយគឺសហព័ទ្ធម្ខាងបានយកទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀតទៅចាយវាយ។

#### គ. ការអនុវត្តនូវការទូទាត់សង

ការអនុវត្តនូវការទូទាត់នេះមានបីករណី៖

##### គ.១. ការទូទាត់សងដោយសហព័ទ្ធទៅឲ្យសហគមន៍

ការសងបំណុលផ្ទាល់ខ្លួន និងការចំណាយទៅលើទ្រព្យផ្ទាល់ខ្លួនដោយប្រើប្រាស់ទ្រព្យរួមគឺក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធម្នាក់ៗអាចបង្កើតឡើងនូវបំណុលរបស់ខ្លួនជាមួយនិងតតិយជន។ ក្នុងករណីនេះបើសិនជាសហព័ទ្ធនោះបានយកទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីសងបំណុលនៅពេលមានការជម្រះបញ្ជីទ្រព្យសម្បត្តិសហព័ទ្ធនោះ ត្រូវធ្វើការទូទាត់សងបំណុលរបស់ខ្លួនទៅសហគមន៍។ ម៉្យាងវិញទៀតបើសហព័ទ្ធម្នាក់ៗ បានយកទ្រព្យសម្បត្តិរបស់សហគមន៍ ដើម្បីចំណាយទៅលើទ្រព្យសម្បត្តិដោយឡែកនោះ ដូចជាយកប្រាក់រួមដើម្បីទិញផ្ទះ ឬដី ក្នុងគោលបំណងធ្វើអាជីវកម្មផ្ទាល់ខ្លួន នៅពេលដែលជម្រះបញ្ជី ត្រូវធ្វើការទូទាត់សងចំណែករបស់ខ្លួនឲ្យទៅសហគមន៍។ ផ្អែកទៅតាមមាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណីបានចែងថា ទ្រព្យសម្បត្តិរួមអាចលក់ ឬធ្វើអំណោយបាន លុះត្រាតែមានការព្រមព្រៀងគ្នារវាងសហព័ទ្ធ

ទាំងពីរ។ ដូចនេះបើសហព័ទ្ធណាម្ខាងបានធ្វើការចាត់ចែង ដោយមិនមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតសហព័ទ្ធនោះត្រូវធ្វើការទូទាត់សងទ្រព្យសម្បត្តិរបស់សហគមន៍នៅពេលមានការជម្រះបញ្ជី។

**គ.២. ការទូទាត់សងដោយសហគមន៍ទៅឲ្យសហព័ទ្ធ**

ការចំណាយទ្រព្យផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍សហគមន៍គឺ សហគមន៍អាចធ្វើការទូទាត់សងទៅសហព័ទ្ធ ក្នុងករណីដែលការចំណាយត្រូវបានធ្វើឡើងដោយទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្ខាង។ យោងទៅលើការអនុវត្តតាមគោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិរវាងទ្រព្យរួមនិងទ្រព្យដោយឡែករបស់សហព័ទ្ធម្នាក់ៗ វាមានការងាយស្រួលក្នុងការធ្វើបំណែងចែកខុសគ្នាតាមប្រភេទទ្រព្យក្នុងការទូទាត់សងនៅពេលមានការជម្រះបញ្ជីទ្រព្យសម្បត្តិ ក្នុងករណីដែលទ្រព្យនោះត្រូវបានទទួលតាមបញ្ញត្តិច្បាប់។

**គ.៣. ការទូទាត់សងដោយសហព័ទ្ធម្ខាងទៅឲ្យសហព័ទ្ធម្ខាងទៀត**

វាដូចជាករណីទាំងពីរខាងលើដែរ ប្រសិនបើសហព័ទ្ធណាម្ខាងបានយកទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀត ដើម្បីចំណាយលើផលប្រយោជន៍ផ្ទាល់ខ្លួន សហព័ទ្ធដែលជាម្ចាស់ទ្រព្យអាចមានលទ្ធភាពច្រើនក្នុងការប្តឹងទាមទារសងមកវិញ និងអាចប្តឹងសុំមោឃៈភាពកិច្ចសន្យា ឬប្តឹងទាមទារឲ្យសហព័ទ្ធម្ខាងទៀតសងនៅពេលដែលមានការជម្រះបញ្ជីទ្រព្យសម្បត្តិ។ ប៉ុន្តែបើសហព័ទ្ធដែលជាម្ចាស់ទ្រព្យនោះបានផ្តល់ការយល់ព្រមលើចំណាយនោះ ឬក៏ការចំណាយនោះ ត្រូវបានធ្វើឡើងមិនមែនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន តែដើម្បីផលប្រយោជន៍សហព័ទ្ធ នោះ ឬដើម្បីផលប្រយោជន៍សហគមន៍។

**ឃ. បែបបទក្នុងការទូទាត់សង**

នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៩៨០ មានចែងពីវិធីនៃការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគឺទីមួយវាអាស្រ័យទៅតាមការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរ ប៉ុន្តែបើគ្មានការព្រមព្រៀងរវាងសហព័ទ្ធទាំងពីរនោះទេនោះសេចក្តីសម្រេចត្រូវស្ថិតនៅលើតុលាការដែលមានអំណាចឆន្ទានុសិទ្ធិ។ជាទូទៅក្នុងករណីដែលការទូទាត់សងនោះ អាចត្រូវបានធ្វើឡើងដោយវត្ថុធាតុដើម ដែលគ្មានបាត់បង់នូវធម្មជាតិរបស់វាតុលាការនឹងបង្គាប់ឲ្យសងវត្ថុដើមតែម្តង។ តែបើការទូទាត់សងវត្ថុនោះ មិនអាចធ្វើទៅបានបើសិនជាគ្មានការព្រមព្រៀងរវាងភាគីទាំងពីរតុលាការអាចសម្រេចឲ្យសងជាប្រាក់បានដែលជាទូទៅការសងជាប្រាក់នេះមានតម្លៃតិចជាងតម្លៃវត្ថុ។

# ជំពូកទី២
# ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់តាមកិច្ចសន្យា

# ជំពូកទី២

# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានឹងបង្ហាញអំពីប្រវត្តិដើម ក៏ដូចជាការវិវត្តនៃប្រព័ន្ធទ្រព្យសម្បត្តិ តាមកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លុះបញ្ចាំងអំពីគោលគំនិតដែលបង្កប់នៅក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ។ ការព្រមព្រៀងរវាងសហព័ទ្ធទាំងសងខាងចំពោះការកំណត់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនេះគឺ មានតាំងពីមុនការបង្កើតនូវប្រព័ន្ធទ្រព្យសម្បត្តិ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទៅទៀត។ គេសង្កេតឃើញថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធច្រើនធ្វើឡើងនៅក្នុងកាលៈទេសៈនៃការលែងលះគ្នារវាងសហព័ទ្ធ ដោយធ្វើការព្រមព្រៀងគ្នារវាងសហព័ទ្ធនៅក្នុងការបែងចែកទ្រព្យសម្បត្តិ តាមរយៈនៃការចុះកិច្ចសន្យាអំពីសិទ្ធិទៅលើទ្រព្យរវាងសហព័ទ្ធ។

ដើមឡើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ត្រូវបានគេកត់សម្គាល់ថា ស្តែងឡើងតាមរយៈការលែងលះ ដែលមានការព្រមព្រៀងគ្នានៅក្នុងការបែងចែងទ្រព្យសម្បត្តិនៅចំពោះមុខតុលាការ។ ក្រោយមកមានបណ្តាប្រទេសជាច្រើនបានយល់ឃើញថា ចំណងអាពាហ៍ពិពាហ៍ មិនអាចជាមូលហេតុដាច់ខាតធ្វើឲ្យទ្រព្យក្រោយអាពាហ៍ពិពាហ៍ស្ថិតនៅក្នុងចំណងនៃទ្រព្យរួមទាំងស្រុងនោះទេ។ ដូច្នេះវាត្រូវបានបង្ហាញនូវសេរីភាព និងឯករាជ្យភាពរបស់សហព័ទ្ធ ដោយអាពាហ៍ពិពាហ៍មានឥទ្ធិពលតែទៅលើទំនាក់ទំនងឋានៈបុគ្គលតែប៉ុណ្ណោះ។ រីឯទ្រព្យសម្បត្តិវិញគឺស្ថិតទៅតាមការសម្រេច និងគោលបំណងរបស់សហព័ទ្ធទាំងសងខាង។ ហេតុនេះហើយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការវិវត្តន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា មានដំណាក់កាលពីរ ដែលយើងអាចស្វែងយល់ពីការបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងទៅនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ។ ជាដំបូងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៥ និងក្រោយមកទៀត ទើបមានការបង្កើតសញ្ញាណនៃប្រព័ន្ធទ្រព្យតាមកិច្ចសន្យា នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងក្រោយមកទើបមាននូវការបែងចែកពីភាពស៊ីជម្រៅនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះតាមរយៈច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ និងជាចុងក្រោយបង្អស់នេះក្រសួងយុត្តិធម៌បានចេញនូវប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយចង្អុលបង្ហាញពីនីតិវិធី និងទម្រង់បែបបទនៃការចុះបញ្ជី។

ទំនាក់ទំនងរវាងទ្រព្យសម្បត្តិប្តីប្រពន្ធ ជាវិធានដែលកំណត់ដោយច្បាប់ ហើយក៏មានលក្ខណៈខុសទៅតាមវប្បធម៌របស់ប្រទេសនីមួយៗផងដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមកិច្ចសន្យានេះផងដែរទើបមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ហើយក៏បានកំណត់ឲ្យស្របទៅតាមវប្បធម៌ និងសង្គមរបស់ប្រទេសកម្ពុជាចំពោះបរិបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីគឺត្រូវអនុវត្តតាមបញ្ញត្តិរបស់ប្រកាសរបស់ក្រសួងយុត្តិធម៌ នោះគឺប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នាថ្ងៃទី០៩ ខែសីហា

ឆ្នាំ២០១៣។[24]ម៉្យាងទៀតទ្រព្យសម្បត្តិទាំងឡាយណាដែលតម្រូវឲ្យសហព័ទ្ធធ្វើកិច្ចសន្យាប្ដីប្រពន្ធនៃទំនាក់ទំនងមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ រីឯការយល់ព្រមទាំងនោះគឺផ្អែកទៅលើឆន្ទៈរបស់សហព័ទ្ធទាំងពីរផងដែរ។ រីឯគោលបំណងរបស់ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់តាមកិច្ចសន្យានេះកើតមានឡើងដើម្បីអាចឲ្យសហព័ទ្ធទាំងពីរ យល់ដឹងឲ្យបានច្បាស់ នូវអ្វីដែលជាទំនាក់ទំនងទ្រព្យសម្បត្តិជាមួយសិទ្ធិនិងករណីយកិច្ចនៃទំហំជាក់លាក់ណាមួយដែលច្បាប់ពុំបានកម្រិតទុក [25] ។ប៉ុន្តែកិច្ចសន្យាប្រភេទនេះអាចធ្វើទៅបានដោយមិនត្រូវផ្ទុយទៅនឹងបទបញ្ញត្តិស្ដីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ។ តាមការសង្កេតបានឲ្យឃើញច្បាស់ថា ចំពោះមាត្រាពាក់ព័ន្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមានបញ្ញត្តិចាប់ពីមាត្រា៩៦៩ និងមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ តាក់តែងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (ដែលសព្វថ្ងៃហៅថា JICA)។

ជាការពិតណាស់បន្ថែមពីនេះនាងខ្ញុំសូមរួមបញ្ចូលជាមួយនឹង **ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌** បានថ្លែងសុន្ទរកថា ថានៅក្នុងទំនាក់ទំនងរវាងបុគ្គល និងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ព្រមទាំងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយមានធនធានទ្រព្យសម្បត្តិគប្បីមានការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសិទ្ធិលើទ្រព្យសម្បត្តិនោះ ថាតើទ្រព្យ សម្បត្តិណាជាទ្រព្យសម្បត្តិរួម ? ទ្រព្យសម្បត្តិណាជាទ្រព្យសម្បត្តិដោយឡែក ឬទ្រព្យសម្បត្តិផ្ដាច់មុខ ? របស់ ភាគីណាមួយ។[26]

## ផ្នែកទី១៖ ប្រព័ន្ធទ្រព្យសម្បត្តិជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

គឺជាប្រព័ន្ធទ្រព្យសម្បត្តិមួយដែលច្បាប់បានផ្ដល់សិទ្ធិឲ្យប្ដីប្រពន្ធអាចធ្វើការកំណត់និងធ្វើការបែងចែកអំពីទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានកំណត់ដោយច្បាប់ នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិនោះបាន។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ចង់សំដៅទៅលើទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែលរួមមាន ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក និងប្រព័ន្ធទ្រព្យសម្បត្តិរួម ព្រមទាំងគុណសម្បត្តិនិងគុណវិបត្តិ នៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធផងដែរ។ និងលើសពីនេះ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យានេះក៏អាចមាននូវប្រព័ន្ធទ្រព្យសម្បត្តិ

[24] ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/០០៧,៣១ ឧសភា ២០១១,មាត្រា ២៧។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៦៩ (កថាខណ្ឌទី១)។

[26] ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ០៩ សីហា ២០១៣ ។

រួមសកល និងប្រព័ន្ធទ្រព្យសម្បត្តិផ្សេងទៀតដែរវាស្រ័យទៅតាមប្រទេស និងការកំណត់ការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា។

### ១.១. ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក

ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ឬហៅជាភាសាអង់គ្លេសថា Separate Property System ជាប្រព័ន្ធដែលបែងចែកឲ្យដាច់ស្រលះពីគ្នានូវទ្រព្យសម្បត្តិប្តី និងប្រពន្ធ ទោះបីជាទ្រព្យសម្បត្តិនោះបានមកមុន ឬក្រោយពេលអាពាហ៍ពិពាហ៍ក៏ដោយ។ សហព័ទ្ធម្នាក់ៗនៅតែមានកម្មសិទ្ធ និងសិទ្ធិគ្រប់គ្រងដោយឯករាជ្យលើទ្រព្យសម្បត្តិរៀងខ្លួន ទោះនៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ប្រព័ន្ធនេះគឺសមស្របចំពោះប្តីប្រពន្ធណាដែលមានគំនិតឯករាជ្យ និងមានស្ថានភាពហិរញ្ញវត្ថុខុសប្លែកគ្នា ដែលមិនប្រាថ្នាដាក់រួមគ្នានូវទ្រព្យសម្បត្តិរៀងៗខ្លួនណាមួយ។ ម្យ៉ាងទៀតប្រព័ន្ធនេះ ជាប្រព័ន្ធដែលមានអត្ថប្រយោជន៍ខ្លាំងចំពោះសហព័ទ្ធ ដែលជាពាណិជ្ជករ ឬ អ្នកមានវិជ្ជាជីវៈសេរី ពីព្រោះថាប្រព័ន្ធនេះអាចជួយការពារទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀតបាន។ ចំពោះដែនកម្រិតនៃប្រព័ន្ធនេះ គឺត្រូវតែគោរពករណីយកិច្ចអាហារកាតព្វកិច្ច និងភាគបម្រុង។

ជាធម្មតាទៅហើយ នៅពេលសហព័ទ្ធទាំងពីរនាក់បានរៀបអាពាហ៍ពិពាហ៍រវាងគ្នានិងគ្នាក៏ក្លាយទៅជាសហព័ទ្ធ។ ចំពោះការរួមរស់នៅជាមួយគ្នាកាន់តែយូរៗទៅមុខនឹងអាចកើតមានឡើងនូវបញ្ហាផ្ទៃក្នុងរបស់គ្រួសារគឺ ទ្រព្យសម្បត្តិដែលសហព័ទ្ធមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។ ជាក់ស្តែងនៅពេលដែលរៀបអាពាហ៍ពិពាហ៍ និងក្លាយជាសហព័ទ្ធស្របច្បាប់រួច ប៉ុន្តែជាបញ្ហានៅពេលដែលចំណងអាពាហ៍ពិពាហ៍នោះមិនសមតាមបំណង គឺកើតមាននូវបញ្ហាកើតឡើង។ ការរួមរស់នៅជាមួយគ្នាកាន់តែយូរ ទ្រព្យសម្បត្តិរវាងប្តីប្រពន្ធកាន់តែស្មុគស្មាញ។ បញ្ហានៃទ្រព្យសម្បត្តិដែលលើកមកនេះ គឺសហព័ទ្ធមួយចំនួនខ្លះ នៅតែមិនអាចធ្វើការបែងចែកច្បាស់លាស់បាន ពីព្រោះថាសហព័ទ្ធទាំងពីរតែងតែយល់ច្រឡំថា តើអ្វីជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន អ្វីជាទ្រព្យសម្បត្តិរួម ចំពោះការដែលសហព័ទ្ធទាំងពីរតែងតែច្រឡំ ឬ បែងចែកអត់ច្បាស់នេះអាចបណ្តាលឲ្យក្លាយទៅជាវិវាទកើតឡើងនៅពេលបែងចែកទ្រព្យសម្បត្តិ។

ជាការពិតណាស់ ដើម្បីឲ្យមានការបែងចែកឲ្យច្បាស់លាស់ សហព័ទ្ធគួរតែចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈប្រកាសលេខ ៨១ កយ.ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ដើម្បីឲ្យមានភាពច្បាស់រវាងទ្រព្យដោយឡែក និងទ្រព្យសម្បត្តិរួម។ មួយវិញទៀតទ្រព្យសម្បត្តិដោយឡែក នេះមិនមែនជាគោលបំណងនៃការរាប់បញ្ចូល ពេលដែលភាគីសហព័ទ្ធទាំងពីរបែងចែកទ្រព្យសម្បត្តិ ឡើយទ្រព្យសម្បត្តិដោយឡែកជាទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយសហព័ទ្ធណាម្ខាង ឬជាកម្មសិទ្ធិរបស់ភាគីណាម្ខាងទៀតប្រសិនបើ

មានជម្លោះ ឬមានការលុបចោលនូវអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងទៀតពុំមានសិទ្ធិប្តឹងទាមទារទ្រព្យដោយឡែក ឬទាមទារឲ្យមានការបែងចែកមកខ្លួនបានឡើយ។

### ១.២. ប្រព័ន្ធទ្រព្យសម្បត្តិរួម

ប្រព័ន្ធទ្រព្យសម្បត្តិរួម ឬហៅជាភាសាអង់គ្លេសថា Community Property System ជាប្រព័ន្ធដែលទទួលស្គាល់ថារាល់ទ្រព្យសម្បត្តិដែលប្តីប្រពន្ធរកបាន នៅក្រោយពេលមានចំណងអាពាហ៍ពិពាហ៍មកធ្វើជាទ្រព្យរួម ហើយនៅពេលដែលអាពាហ៍ពិពាហ៍រលាយ នឹងត្រូវធ្វើការបែងចែកស្មើគ្នា។ នៅក្នុងប្រព័ន្ធនេះគេសង្កេតឃើញមានវត្តមាន ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហព័ទ្ធ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ (ទ្រព្យដោយឡែកដែលជាទ្រព្យមានមុនអាពាហ៍ពិពាហ៍ ឬទ្រព្យទទួលបានពីប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍) និងទ្រព្យរួម ដែលរកបានក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបែងចែកគ្នានៅពេលមានការបញ្ចប់អាពាហ៍ពិពាហ៍។

ម៉្យាងវិញទៀតទ្រព្យសម្បត្តិដែលកើតមានឡើងពីការខិតខំប្រឹងប្រែងពីកម្លាំងញើសឈាមរបស់សហព័ទ្ធនៅពេលដែលសហព័ទ្ធទាំងពីរបានក្លាយជាប្តីប្រពន្ធស្របច្បាប់មិនថាទ្រព្យសម្បត្តិនោះកើតចេញពីការខិតខំរកតែសហព័ទ្ធតែម្ខាងទេ ក៏នៅតែជាទ្រព្យសម្បត្តិរួមដដែល ឬ ទ្រព្យទទួលបានពីប្រាក់ខែការងាររបស់សហព័ទ្ធ(ប្រាក់បៀវត្សរបស់សហព័ទ្ធ) និងផលប្រយោជន៍ផ្សេងៗទៀត ប៉ុន្តែលើកលែងតែមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី ដែលចែងអំពីទ្រព្យសម្បត្តិដោយឡែក។

<u>ឧទាហរណ៍៖</u> លោក ដារ៉ា មានតូបដួលមួយកន្លែងនៅក្នុងផ្សារ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់លោក។លោកដារ៉ា បានជួលតូបនោះទៅឲ្យបងប្អូនជីដូនមួយ ក្នុងមួយខែតម្លៃ ២៥០ដុល្លាអាមេរិក លុះដល់ថ្ងៃទី០៥.០៥.២០១៥ លោកដារ៉ា បានរៀបអាពាហ៍ពិពាហ៍ជាមួយ អ្នកនាងលីនដា។ ចំពោះប្រាក់ខែ ២៥០ដុល្លាអាមេរិកក្នុងមួយខែវិញ ដែលទទួលបានចាប់ពីថ្ងៃទី០៥.០៥.២០១៥ រហូតដល់ពេលរំលាយអាពាហ៍ពិពាហ៍ គឺជាផលនៃទ្រព្យសម្បត្តិដោយឡែកដែលក្រមរដ្ឋប្បវេណីចាត់ទុកថាជាទ្រព្យសម្បត្តិរួម។

មួយវិញទៀតប្រសិនបើកើតមាននូវបញ្ហាជម្លោះលែងលះគ្នាកើតមានឡើងសហព័ទ្ធទាំងពីរមិនបានព្រមព្រៀងគ្នានៃការបែងចែកទ្រព្យសម្បត្តិរួមនោះទេ នោះសហព័ទ្ធទាំងពីរមានសិទ្ធិក្នុងការទទួលយកចំណែក ម្នាក់ ១/២ នៃទ្រព្យសម្បត្តិរួមនោះ ប៉ុន្តែបើមានករណីពិសេស គឺតុលាការពិចារណាទៅលើស្ថានភាពជាក់ស្តែង។ ទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ក៏រំលាយទៅវិញក្នុងទំហំនៃការលែងលះ និងការបែងចែកទ្រព្យសម្បត្តិ។

### ១.២.១. គុណសម្បត្តិ

ប្រព័ន្ធទ្រព្យសម្បត្តិរួម ជាប្រព័ន្ធសមស្របបំផុតនឹងគោលបំណងនៃការបង្កើតជាគ្រួសារ ក្នុងការពង្រឹងសាមគ្គីភាពគ្រួសាររវាងសហព័ទ្ធទាំងពីរ គឺភាពតែមួយលើផ្នែកសេដ្ឋកិច្ច និងភាពស្មើគ្នា។ ម៉្យាងទៀត

ដើម្បីការពារសហព័ទ្ធដែលនៅរស់ ប្រព័ន្ធទ្រព្យសម្បត្តិរួមនេះមានលក្ខណៈពិសេសក្នុងការការពារសហព័ទ្ធដែលនៅរស់ គឺប្រគល់ចំណែកនៃសិទ្ធិលើអចលនវត្ថុជាលំនៅដ្ឋានគ្រួសារដល់សហព័ទ្ធដែលនៅរស់ និងបែងចែកឲ្យសហព័ទ្ធដែលនៅរស់ទទួលបានចំណែក ២/៣ ឬទាំងមូល (លើកលែងតែប៉ះពាល់ដល់ភាគបម្រុងជាដើម)។

ក្រៅពីនេះយើងខ្ញុំមានការយល់ឃើញ សូមលើកឡើងនូវគុណសម្បត្តិនៃប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលសហព័ទ្ធទាំងពីរទទួលបានក្រោយពេលចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលគុណសម្បត្តិទាំងនោះរួមមានដូចខាងក្រោម៖

**ក. ភាពចាំបាច់នៃការចុះបញ្ជីកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**

ជាទូទៅការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ គឺដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធនូវករណីយកិច្ច និងទំនាក់ទំនងទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរមានជាក់ស្តែង នឹងរួមជាមួយការបង្ហាញឆន្ទៈព្រៀមព្រៀងគ្នារៀងៗខ្លួន។ កាលណាមានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវមានទម្រង់ជាលិខិតលាយលក្ខណ៍អក្សរដែលជាលិខិតយថាភូត នោះនាំឲ្យការស្នើសុំនោះមានប្រសិទ្ធភាពនៅក្នុងនីតិវិធីលែងលះ វិវាទមរតក និងវិវាទក្នុងករណីទាមទារឲ្យអនុវត្តកាតព្វកិច្ចផងដែរ ជាពិសេសអាចតតាំងជាមួយនិងតតិយជនបានទៀតផង ថែមទាំងរឹតបន្តឹងចំណាងអាពាហ៍ពិពាហ៍ និងកាត់បន្ថយការលែងលះរួមទាំងមានប្រសិទ្ធិភាពចំពោះដំណើរការនីតិវិធីនៃការសម្របសម្រួលយ៉ាងពិសេសដល់តុលាការនៅក្នុងវិវាទលែងលះ វិវាទផ្នែកមរតក និងវិវាទក្នុងការទាមទារអនុវត្តកាតព្វកិច្ច។

**ខ. ការកំណត់អំពីសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ និងករណីកិច្ចរបស់សហព័ទ្ធ**

គឺជាសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនិងទ្រព្យរួម ឬករណីយកិច្ចផ្សេងៗទៀតទាំងនោះរួមមាន ៖

-ការទទួលខុសត្រូវរួមគ្នាចំពោះទ្រព្យរួមរបស់សហព័ទ្ធ៖ [27] សោហ៊ុយអាពាហ៍ពិពាហ៍ ប្តីប្រពន្ធត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ បានន័យថាសហព័ទ្ធមានករណីយកិច្ចជួយសម្រួលលើជីវភាពរួមរបស់គ្រួសារទៅវិញទៅមកទៅតាមស្ថានភាពជាក់ស្តែងរបស់ពួកគេនៅក្នុងគ្រួសារ។ ការចំណាយទៅលើសោហ៊ុយអាពាហ៍ពិពាហ៍មិនមែនរាប់បញ្ចូលតែការទិញសំលៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅនោះទេ ប៉ុន្តែសំដៅដល់ការចំណាយលើការសិក្សា និងការថែទាំកូនផងដែរ។ ចំពោះករណីដែលសហព័ទ្ធម្ខាងមិនគោរពនូវការទទួល

---

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា ៩៧១។

ខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួននៃសោហ៊ុយអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងទៀតមានសិទ្ធិដាក់ពាក្យស្នើសុំទៅតុលាការឲ្យចេញនូវដីកាសម្រេចអំពីសោហ៊ុយអាពាហ៍ពិពាហ៍នេះបាន។

ឧទាហរណ៍៖ ប្តីប្រពន្ធបានទិញហាងមួយកន្លែង ចំពោះការចេញសោហ៊ុយចំណាយទៅហាងនោះជាកាតព្វកិច្ចរបស់សហព័ទ្ធទាំងពីរ ប៉ុន្តែរាល់សោហ៊ុយចំណាយទៅលើហាងនោះដូចជា ការតុបតែង ការថែទាំ ជាដើម សហព័ទ្ធទាំងពីរត្រូវទទួលខុសត្រូវដូចគ្នា ។

-ចំពោះការតតាំងជាមួយនិងតតិយជន និងការសាមគ្គីគ្នា៖ ប្រសិនបើសហព័ទ្ធណាម្នាក់ជាប់បំណុលជាមួយតតិយជន សហព័ទ្ធម្ខាងទៀតក៏អាចតតាំងជាមួយម្ចាស់បំណុលបានដែរ ប៉ុន្តែប្រសិនបើបំណុលនោះបានខ្ចីមកក្នុងស្ថានភាពចាំបាច់នៅក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ជាប្រយោជន៍រួមក៏អាចតតាំងជាមួយតតិយជនបានដូចគ្នា។ ចំពោះសហព័ទ្ធណាម្ខាងពុំមានចំណូលប្រចាំថ្ងៃ ចង់កំណត់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយតតិយជន សម្រាប់ការចាយវាយក្នុងគ្រួសារដូចជា ការទិញម្ហូប បង់ថ្លៃទឹក-ភ្លើង ថ្លៃបង់សាលាកូនគឺអាចប្រើប្រាស់សិទ្ធិនោះបាន ដោយយោងតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលរកបានពីការងារធ្វើនៅក្រៅផ្ទះ[28] ប៉ុន្តែត្រូវមានការព្រមព្រៀងរវាងសហព័ទ្ធទាំងពីរ។ ចំពោះការសាមគ្គីភាពវិញ នៅពេលមានបំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍សហព័ទ្ធទាំងពីរត្រូវចូលរួមដោយសាមគ្គីនិងទទួលខុសត្រូវជាមួយគ្នានូវបំណុលដែលកើតឡើងដើម្បីផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ ប៉ុន្តែបំណុលដោយឡែករបស់សហព័ទ្ធណាម្ខាង ពុំមានករណីយកិច្ចទទួលខុសត្រូវដោយសាមគ្គីភាពឡើយ។

**គ. សិទ្ធិនៃការចាត់ចែង ការគ្រប់គ្រងលើទ្រព្យសម្បត្តិក្នុងកិច្ចសន្យាប្តីប្រពន្ធ**

នៅក្នុងការចាត់ចែង ការគ្រប់គ្រងលើទ្រព្យសម្បត្តិនៃកិច្ចសន្យាទ្រព្យសម្បត្តិនេះបានកំណត់ចំពោះសិទ្ធិរបស់សហព័ទ្ធណាម្ខាង ដើម្បីអាចចាត់ចែងលើទ្រព្យសម្បត្តិណាមួយក៏បាន។ នៅក្នុងខ្លឹមសារនេះទ្រព្យសម្បត្តិរួមពុំអាចចាត់ចែងដោយឡែកបានទេលើកលែងតែភាពចាំបាច់សម្រាប់គ្រួសារ ចំពោះការចាត់ចែងទ្រព្យសម្បត្តិរួមគឺទាល់តែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ ប៉ុន្តែចំពោះការថែរក្សាទ្រព្យសម្បត្តិរួមមិនចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតនោះឡើយ។ ពេលខ្លះទោះបីជាការចាត់ចែងនោះមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតក៏ដោយ ក៏ត្រូវមានការអនុញ្ញាតពីតុលាការដែរ។

ជាការពិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធទោះបីជាការព្រមព្រៀងគ្នាតាមឆន្ទៈក៏ដោយ ភាគីម្ខាងទៀតនៃកិច្ចសន្យាក៏មិនអាចបំពានផលប្រយោជន៍របស់ភាគីម្ខាងទៀតបានឡើយ ហើយក៏មិនអាចប្រាសចាកពីបទបញ្ញត្តិច្បាប់បានដែរ ចំណែកឯទ្រព្យសម្បត្តិដោយឡែកវិញ សហព័ទ្ធគ្រប់គ្រងទ្រព្យសម្បត្តិដែលជាផលប្រយោជន៍រៀងៗខ្លួន។

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាច្រកកម្ពុជា២០១០, មាត្រា៣៦ កថាខណ្ឌ៣។

**ឃ. ករណីសហព័ទ្ធម្ខាងទៀតទទួលមរណភាព**

គឺជាការកំណត់ដែលមិនអាចបំពានបានឡើយលើភាគបម្រុងរបស់សហព័ទ្ធម្ខាងទៀតទោះបីជាទ្រព្យសម្បត្តិនោះក្លាយជារបស់សហព័ទ្ធម្ខាងទៀតនៅមានជីវិតក៏ដោយ បានន័យថាសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច។

**១.២.១. គុណវិបត្តិ**

យើងដឹងរួចហើយថាកាលដែលនាំឲ្យកើតមានគុណសម្បត្តិ គឺតែងតែផ្សារភ្ជាប់មកជាមួយនិងគុណវិបត្តិនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ចំពោះគុណវិបត្តិទាំងនោះរួមមាន៖

**ក.នីតិវិធីយឺតយ៉ាវ និង ស្មុគស្មាញ**

ទោះបីជាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានចែងពីនីតិវិធីនានាក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យ សម្បត្តិក្តីក៏យើងឃើញថាវានៅមានភាពស្មុគស្មាញ និងសាំញ៉ាំដែលសហព័ទ្ធភាគច្រើនមិនចង់ធ្វើ ដោយសារវាត្រូវឆ្លងកាត់នូវការបំពេញសំណុំសំណៅឯកសារជាច្រើន ដោយត្រូវឆ្លងកាត់នូវដំណាក់កាល ដែលចំណាយពេលវេលាយូរដោយសារប្រកាសនេះមិនបានកំណត់រយៈពេលនៃការចុះបញ្ជីឡើយ។

**ខ.ទីកន្លែងមិនទាន់ឆ្លើយតបនឹងតម្រូវការ**

ទីកន្លែងនៃការចុះបញ្ជីទៀតសោតគឺមានតែមួយកន្លែងនៅរាជធានីភ្នំពេញ ដែលមិនអាចឆ្លើយតបឲ្យបានឆាប់រហ័ស ទាន់ចិត្តដល់ប្រជាពលរដ្ឋទូទាំងប្រទេសនៅឡើយហេតុនេះហើយបានជាអ្នកនៅតាមបណ្តាខេត្តមួយចំនួនមិនបានដឹង ឬ មិនចង់ធ្វើកិច្ចសន្យាទ្រព្យសម្បត្តិនេះឡើយ។

**គ.ការផ្សព្វផ្សាយនៅមានកម្រិត**

ស្ថាប័នរដ្ឋហាក់ដូចជាមានកម្រិតនៅឡើយក្នុងការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវការចុះបញ្ជីទ្រព្យសម្បត្តិនេះទៅដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដើម្បីឲ្យពួកគាត់យល់ពីសារៈសំខាន់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមួយនេះ។ ទោះជាកន្លងមកក្រសួងយុត្តិធម៌ បានធ្វើនូវសិក្ខាសាលាណែនាំនានាទៅដល់មន្ត្រី ក៏ដូចជាប្រជាពលរដ្ឋក៏ដោយក៏នៅតែមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ពេលខ្លះការផ្សព្វផ្សាយ គឺនៅតែមានភាពមិនទូលំទូលាយ ដែលមានតែអ្នកដែលមានជំនាញច្បាប់ប៉ុណ្ណោះដែលធ្លាប់បានដឹង បានឮពីកិច្ចសន្យាប្រភទនេះ។

**ឃ.កត្តាទំនុកចិត្ត**

ប្រជាជនខ្មែរនៅតែយល់ថាការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះធ្វើឲ្យពួកគេបាត់បង់ទំនុកចិត្តរវាងគ្នានឹងគ្នា មិនស្មោះត្រង់នឹងគ្នា ហើយថែមទាំងគិតថាសហព័ទ្ធម្ខាងទៀតគិតតែពីទ្រព្យសម្បត្តិនៅពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាដើម។ ទោះបីជាមានសហព័ទ្ធខ្លះបានធ្វើការចុះបញ្ជីកិច្ចសន្យានេះរួចហើយក្តី ក៏

អាចមានគុណវិបត្តិខ្លះៗដូចជា ការខ្វះភាពសាមគ្គីគ្នាក្នុងការទំនុកបម្រុងជីវភាពគ្រួសារ និងជម្លោះនានាក្នុងការប្រើប្រាស់ទ្រព្យដែលជាទ្រព្យរួម ឬទ្រព្យដោយឡែកជាដើម។

## ១.៣. ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល

ប្រព័ន្ធទ្រព្យសម្បត្តិរួមសកល ឬហៅជាភាសាអង់គ្លេសថា Universal Community Property System ជាប្រព័ន្ធដែលទទួលស្គាល់គ្រប់ប្រភេទនៃទ្រព្យសម្បត្តិទាំងអស់ ទោះបីជាសហព័ទ្ធម្នាក់ៗទទួលបាននៅពេលណាក៏ដោយ ត្រូវចាត់ទុកថាទ្រព្យរួមទាំងអស់។ដូចនេះនៅរាល់បំណុលទាំងអស់ ទោះជាកើតមាននៅពេលបច្ចុប្បន្នឬអនាគត រួមទាំងបំណុលដែលកើតមានមុនពេលដែលរៀបអាពាហ៍ពិពាហ៍ ត្រូវចាត់ទុកថាជាបំណុលរួមទាំងអស់ដូចគ្នា។ ចំពោះសិទ្ធិអំណាចរបស់សហព័ទ្ធម្នាក់ៗលើទ្រព្យរួមនេះ គឺដូចគ្នានឹងករណីប្រព័ន្ធទ្រព្យរួមដែលសហព័ទ្ធម្នាក់ៗមានចំពោះទ្រព្យរួមផងដែរ។

ប្រព័ន្ធទ្រព្យសម្បត្តិប្រភេទនេះ គឺជាប្រព័ន្ធទ្រព្យសម្បត្តិមួយដែលច្បាប់អនុញ្ញាតឲ្យភាគីប្តី ឬ ប្រពន្ធដែលមានទ្រព្យមុនអាពាហ៍ពិពាហ៍ (ទ្រព្យសម្បត្តិដោយឡែក) ផ្ទាល់ខ្លួន មិនថាទ្រព្យសម្បត្តិទាំងនោះជាចលនវត្ថុ ឬ អចលនវត្ថុនោះទេ អាចដាក់ចូលជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធបាន។ ប៉ុន្តែវាជាការបង្ហាញឆន្ទៈថាព្រមផងដែរទើបអាចដាក់ចូលជាទ្រព្យសម្បត្តិរួមបាន ក្រោយពេលដាក់បញ្ចូលជាទ្រព្យសម្បត្តិរួមមកនាំឲ្យភាគីម្ខាងទៀតដែលជាប្តី ឬប្រពន្ធក៏មានសិទ្ធិលើទ្រព្យនោះម្នាក់ពាក់កណ្តាលដែរ ម៉្យាងវិញទៀតការបង្ហាញឆន្ទៈយល់ព្រមទៅវិញទៅមក វាជាការបង្ហាញឆន្ទៈដើម្បីប្រយោជន៍រួម នឹងមិនបង្កឲ្យបាត់បង់ប្រយោជន៍របស់ភាគីណាមួយបានឡើយ។

<u>ឧទាហរណ៍៖</u> លោកស្រីណាង មានហាងកាហ្វេមួយកន្លែងមុនរៀបអាពាហ៍ពិពាហ៍ជាមួយនិងលោក នូមកម្ល៉េះ។ ក្រោយរៀបអាពាហ៍ពាហ៍បាន ៥ឆ្នាំ ពួកគាត់រស់នៅជាមួយគ្នាយ៉ាងស្មោះត្រង់ទៅវិញទៅមកហើយលោកស្រី ណាង បានយកហាងកាហ្វេមួយកន្លែងនោះដាក់ជាទ្រព្យសម្បត្តិរួមដែលលោក នូ ក៏មានសិទ្ធិលើហាងមួយនោះដែរ។លោក នូ មានសិទ្ធិប្រើប្រាស់ ចាត់ចែង និងអាស្រ័យផលលើហាងកាហ្វេនោះដូចលោកស្រី ណាដែលជាកម្មសិទ្ធិករដែរ។

ក្រៅពីប្រព័ន្ធទ្រព្យសម្បត្តិធំៗដែលបានរៀបរាប់ទាំងបីខាងលើមក ដូចជាប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកប្រព័ន្ធទ្រព្យសម្បត្តិរួម និងប្រព័ន្ធទ្រព្យសម្បត្តិរួម ក៏នៅអាចមានប្រព័ន្ធទ្រព្យសម្បត្តិផ្សេងទៀតដែរអាស្រ័យទៅតាមប្រទេសនីមួយៗ។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិផ្សេងទៀតនេះ ជាប្រព័ន្ធដែលកំណត់ថាទ្រព្យនៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធម្នាក់ៗមាន ជាទ្រព្យដោយឡែកប៉ុន្តែនៅពេលដែលប្រព័ន្ធទ្រព្យសម្បត្តិនេះរំលាយ (មរណភាព ឬការបាត់ខ្លួនសហព័ទ្ធណាម្ខាង ការលែងលះ ឬការផ្លាស់ប្តូរប្រព័ន្ធទ្រព្យសម្បត្តិ)ត្រូវបែងចែកទ្រព្យដែលបានកើតឡើង នៅក្នុងអំឡុងពេល អាពាហ៍ពិពាហ៍តាមចំណែក

ស្មើៗគ្នា ទៅឲ្យសហព័ទ្ធម្នាក់ៗ។ ម្យ៉ាងទៀតពេលខ្លះប្រព័ន្ធទ្រព្យសម្បត្តិផ្សេងទៀតនេះ ក៏អាចជាប្រព័ន្ធដែលកំណត់យកទ្រព្យធម្មជាតិណាមួយ (ចលនវត្ថុទាំងអស់ ឬអចលនវត្ថុទាំងអស់) មកធ្វើជាទ្រព្យរួម ហើយក្រៅពីនោះជាទ្រព្យដោយឡែក។ល។

## ១.៤. អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

តាមរយៈនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដែលវាជាកត្តាដ៏សំខាន់នៅក្នុងការផ្តល់ឲ្យភាគីទាំងសងខាងនៃកិច្ចសន្យាទទួលបាននូវភាពច្បាស់លាស់ទៅលើទំនាក់ទំនងទ្រព្យទាំងមុនពេលរៀបអាពាហ៍ពិពាហ៍និងក្រោយពេលរៀបអាពាហ៍ពិពាហ៍។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបង្កើតឡើងដោយមានលក្ខណៈពេញលេញនិងគោរពទៅតាមនីតិវិធីច្បាប់ ហើយបង្កើតនូវអានុភាពគតិយុត្តលើផ្នែកសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធទាំងសងខាង។ ទន្ទឹមនឹងការផ្តល់ភាពងាយស្រួល និងអត្ថប្រយោជន៍នៃប្រព័ន្ធទ្រព្យតាមកិច្ចសន្យានេះ វាក៏មានការលេចឡើងននូវភាពអវិជ្ជមាន និងបញ្ហាប្រឈមមួយចំនួនផងដែរ ជាក់ស្តែងដូចជាបញ្ហាទំនុកចិត្តរបស់សហព័ទ្ធជាដើម។ល។

### ១.៤.១. អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាកិច្ចសន្យាមួយដែលជួយសម្រួល និងបង្កើននូវភាពជាក់លាក់ដល់ប្តីប្រពន្ធដែលបានចុះកិច្ចសន្យានោះ ទាក់ទងទៅនឹងបញ្ហាសំខាន់ៗជាច្រើនរួមមានចំណាត់ចែងនូវសិទ្ធិលើទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីកិច្ចដែលតម្រូវឲ្យសហព័ទ្ធគោរព និងអនុវត្តតាមគោលការណ៍ដែលច្បាប់បានកំណត់ ។ គួរបញ្ជាក់ផងដែរថា ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ត្រូវបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគី និងត្រូវបានធ្វើឡើងនៅចំពោះមុខមន្ត្រីក្រសួងយុត្តិធម៌ ហើយគោរពទៅតាមការកំណត់និងចង្អុលបង្ហាញរបស់ច្បាប់ដើម្បីធានាឲ្យមានភាពត្រឹមត្រូវនឹងបង្កើតឲ្យមាននូវអានុភាពគតិយុត្ត។

#### ក. អានុភាពនៃការចុះបញ្ជី

ចំពោះប្តីប្រពន្ធបាន និងបំរុងបង្កើតនូវចំណងអាពាហ៍ពិពាហ៍ ហើយបានទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងគោលបំណងកំណត់ និងបែងចែករវាងទ្រព្យរួម និងទ្រព្យដោយឡែកគឺនាំឲ្យ មានភាពងាយស្រួលចំពោះសហព័ទ្ធនៅក្នុងការប្រើប្រាស់សិទ្ធិលើទ្រព្យដែលខ្លួនមាន លើសពីនេះទៅទៀតនៅពេលដែលសហព័ទ្ធឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ហើយមានជម្លោះដែលទាក់ទងទៅនឹងបញ្ហាទ្រព្យ នោះកិច្ចសន្យាដែលទាក់ទងនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនឹងក្លាយជាកម្មវត្ថុដ៏សំខាន់នៅក្នុងការបែងចែកទ្រព្យ។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជាយើងវិញ នៅមានប្រជាពលរដ្ឋមួយចំនួន ដែលឲ្យតម្លៃទៅលើការរៀបអាពាហ៍ពិពាហ៍ ការប្រារព្ធពិធីតាមបែបទំនៀមទំលាប់ប្រពៃណី ក៏ប៉ុន្តែពួកគាត់បែរជាមិនសូវមានការយកចិត្តទុកដាក់ទៅលើការចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមនីតិវិធី និងការកំណត់របស់ច្បាប់ទៅវិញ។ ទាំងនេះ

បញ្ជាក់ឲ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាមួយចំនួនពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីបញ្ហា ដែលទាក់ទងទៅនឹងបទបញ្ញត្តិច្បាប់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ព្រមទាំងអានុភាពគតិយុត្តក្រោយពីទទួលបានការចុះបញ្ជីទ្រព្យសម្បត្តិ។ អានុភាពកិច្ចសន្យាប្តីប្រពន្ធមានលក្ខណៈទូលាយ និងមានអានុភាពទាំងចំពោះភាគីនៃកិច្ចសន្យាពោលគឺ ប្តី និងប្រពន្ធ ព្រមទាំងមានអានុភាពសម្រាប់តាំងចំពោះតតិយជនផងដែរ។

**ខ. អានុភាពចំពោះភាគី**

ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ អាចធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយអាពាហ៍ពិពាហ៍ ក៏បានគ្រាន់តែការចុះនោះតម្រូវឲ្យគោរពតាមនីតិវិធីច្បាប់ឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវអានុភាពនៃកិច្ចសន្យានោះ និងស្របទៅតាមគោលការណ៍គតិយុត្ត។ ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនេះនឹងបង្កើតនូវអានុភាពចំពោះភាគីនៃកិច្ចសន្យាដែលបានចុះបញ្ជីនោះហើយត្រូវបានកំណត់ដ៏ជាក់លាក់មួយអំពីទំហំ នៃទ្រព្យដែលសហព័ទ្ធទាំងសងខាងមាន ព្រមទាំងបង្កើនឲ្យមានភាពច្បាស់លាស់ចំពោះសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យនិងកាតព្វកិច្ចដែលភាគីនីមួយៗត្រូវបំពេញ ឬការអនុវត្ត។

**គ. អានុភាពចំពោះតតិយជន**

ក្រៅពីការបង្កើតឲ្យមានអានុភាពដល់សហព័ទ្ធដែលជាភាគីនៃកិច្ចសន្យា ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏បង្កើតនូវអានុភាពចំពោះតតិយជនផងដែរ។ ចំពោះតតិយជនដែលមានផលប្រយោជន៍ ឬមានបំណងចង់បញ្ជាក់នូវទំហំទ្រព្យសម្បត្តិរបស់ប្តី ឬប្រពន្ធពោលគឺ មានបំណងចង់ដឹងអំពីការកំណត់នូវទ្រព្យសម្បត្តិរបស់ភាគីណាម្ខាងនៃកិច្ចសន្យា ឲ្យបានច្បាស់លាស់ដើម្បីជាមូលដ្ឋាននៅក្នុងការសម្រេច ធ្វើកិច្ចគតិយុត្តណាមួយជាមួយភាគីប្តី ឬប្រពន្ធជៀសវាងការខូចបង់ទ្រព្យរបស់ខ្លួននោះ តតិយជននោះអាចស្នើសុំចេញនូវលិខបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះបាន។ គួរបញ្ជាក់ផងដែរថា តតិយជនដែលអាចទាមទារឲ្យមានការចេញនូវលិខិតបញ្ជាក់នោះ អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានផលប្រយោជន៍ចំពោះទ្រព្យ ហើយចំពោះការសុំចេញលិខិតបញ្ជាក់នេះត្រូវតែគោរពតាមគោលការណ៍ និងលក្ខខណ្ឌដែលច្បាប់បានកំណត់ជាពិសេសការបញ្ជាក់ពីគោលបំណង ឬកម្មវត្ថុនៃការសុំនោះជាដើម។

## ផ្នែកទី២៖ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅមុនពេលដែលមិនទាន់មានការអនុវត្តក្រមរដ្ឋប្បវេណី ការអនុវត្តច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនៅតែបន្តរហូតដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ទើបមានការអនុវត្តក្រមរដ្ឋប្បវេណីបានពេញលេញទាំងស្រុង។ តាមការជាក់ស្តែង ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តតាំងពីឆ្នាំ ២០០៧ ក៏ប៉ុន្តែការអនុវត្តនៅតែមិនអាចធ្វើទៅបាន ដោយមូលហេតុថាពុំទាន់មានច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៅឡើយ ហេតុនេះហើយត្រូវរង់ចាំឲ្យច្បាប់នេះចូលជាធរមាននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ និងប្រាំមួយខែក្រោយមកទើប ក្រមរដ្ឋប្បវេណីត្រូវ

បានឲ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។ ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធវិញ ក៏ត្រូវមានការអនុវត្តទៅតាមបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ផងដែរ ដើមឡើយមានប្រភពសញ្ញាណនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

មុនពេលក្រមរដ្ឋប្បវេណីប្រកាសឲ្យប្រើយើងមិនដែលបានឮនោះទេ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា តែយើងឃើញមានសញ្ញាណនៃការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធដោយកិច្ចសន្យា ដូចជានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា ៧០ បានកំណត់ថា“ ក្នុងករណីលែងលះគ្នាទ្រព្យត្រូវបែងចែកទៅតាមការព្រមព្រៀងភាគីទាំងសងខាង” នេះយើងអាចសន្និដ្ឋានបានថា ភាគីប្តីប្រពន្ធអាចធ្វើកិច្ចសន្យាកំណត់អំពីទ្រព្យសម្បត្តិតាំងពីមុនក្រមរដ្ឋប្បវេណីមកម្ល៉េះ តែមិនមែនប្រព័ន្ធទ្រព្យនោះទេ។ ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់វិវាទអំពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ នៅក្នុងទំនាក់ទំនងជាក់ស្តែងរបស់ប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ បានផ្តល់លទ្ធភាពឲ្យប្តីប្រពន្ធនូវជំរើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ ដូច្នេះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ។ យ៉ាងណាមិញចំពោះមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់សម្គាល់អំពីលក្ខខណ្ឌចាំបាច់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នេះគឺទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវតែធ្វើឡើងជាលាយ លក្ខណ៍អក្សរ ដោយសារតែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះនាំឲ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និងករណីយកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ។ បញ្ញត្តិក្នុងកថាខណ្ឌ២ នៃមាត្រាដដែលនេះផងដែរ ក៏តម្រូវឲ្យចុះបញ្ជីកិច្ចសន្យានេះ ក្នុងករណីដែលធ្វើខុសពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ដើម្បីជៀសវាងនូវផលប៉ះពាល់អាក្រក់ចំពោះផលប្រយោជន៍របស់តតិយជន។ នៅក្នុងច្បាប់នៃប្រទេសដែលទទួលស្គាល់ការធ្វើកិច្ចសន្យា ទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ការកែប្រែកិច្ចសន្យានៅក្រោយការៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបានទទួលស្គាល់ផងដែរ ក៏ប៉ុន្តែដើម្បីការពារតតិយជន ច្បាប់នៃប្រទេសកាណាដា និងអេស្ប៉ាញជាដើម បានហាមឃាត់ការធ្វើកិច្ចសន្យា និងការកែប្រែណាដែលប៉ះពាល់ដល់សិទ្ធិតតិយជន។

ក្រោយមកក្រមរដ្ឋប្បវេណីថ្មីត្រូវបានអនុម័តនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ លុះមកដល់ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១១ ទើបក្រមនេះត្រូវបានអនុវត្តជាផ្លូវការ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានក្លាយទៅជាមូលដ្ឋានថ្មីមួយនៅក្នុងការដោះស្រាយចំពោះរឿងក្តីរដ្ឋប្បវេណី និងគ្រប់គ្រង់រាល់ទំនាក់ទំនងផ្សេងៗនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដែលក្នុងនោះក៏រួមបញ្ចូលទាំងរឿង អាពាហ៍ពិពាហ៍ តួយ៉ាងដូចជាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធជាដើម។នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គន្ថីទី៧ ជំពូកទី៣ ពោលគឺចាប់ពីមាត្រា ៩៤៨ ដល់មាត្រា ៩៨២ សុទ្ធ

សឹងតែជាបទបញ្ញត្តិដែលទាក់ទងទៅនឹង "អាពាហ៍ពិពាហ៍" ដែលបានចែងអំពី ការបង្កើតអាពាហ៍ពិពាហ៍រហូតដល់ការលែងលះ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលបានអនុវត្តនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១បានបង្កើតឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធតាមកិច្ចសន្យា ដែលមានចែងតែចំនួនពីរមាត្រាតែប៉ុណ្ណោះ ចាប់ពីមាត្រា ៩៦៩ ដល់ មាត្រា ៩៧០ នៅក្នុងផ្នែកទី៣។ មាត្រាពីរនេះមិនអាចកំណត់ឲ្យមានភាពច្បាស់លាស់នៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យាឡើយ។ នៅកាលបរិច្ឆេទនៃការអនុវត្តក្រម ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ត្រូវបានគេចែងបន្ថែមទៀតនៅក្នុងច្បាប់ស្ដីពីការអនុវត្តក្រម ក្នុងជំពូកទី៤ ចាប់ពីមាត្រា ២៦ ដល់មាត្រា៣២។ប៉ុន្តែក៏នៅតែ មិនអាចអនុវត្តបាន ដោយសារតែមិនមានការកំណត់នូវនីតិវិធីនៃការចុះបញ្ជីឲ្យបានច្បាស់លាស់នៅឡើយទេ។ ចុងក្រោយនៅថ្ងៃទី០៩ ខែសីហាឆ្នាំ២០១៣ ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ របស់ក្រសួងយុត្តិធម៌ បានចែងយ៉ាងលម្អិតទាក់ទងនឹងប្រព័ន្ធទ្រព្យនេះ។

ចាប់តាំងពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មកសហព័ទ្ធអាចធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ក្នុងលក្ខខណ្ឌដែលកិច្ចសន្យានេះមិនត្រូវបានប៉ះពាល់ដល់សិទ្ធិក្រៅបេតិកភណ្ឌនោះទេ។កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិនេះ គឺអាចកើតបានតែចំពោះសិទ្ធិបេតិកភណ្ឌតែប៉ុណ្ណោះ អាចជាការកំណត់ទ្រព្យដែលមិនត្រូវជាសហកម្មសិទ្ធិ ឬរាល់ទ្រព្យទាំងអស់ត្រូវធ្លាក់ចូលជាទ្រព្យរួម អាចជាការចងលក្ខខណ្ឌផ្សេងៗក្នុងការគ្រប់គ្រង ការប្រើប្រាស់ ឬការចាត់ចែងទ្រព្យសម្បត្តិជាដើម។

មូលហេតុដែលក្រមរដ្ឋប្បវេណី បានធ្វើការហាមឃាត់ទៅលើសិទ្ធិក្រៅបេតិកភណ្ឌ ព្រោះតែដើម្បីតែការពារផលប្រយោជន៍នៃសហព័ទ្ធទាំងសងខាង ក៏ដូចជាតតិយជន រួមទាំងការពារគោលដៅនៃស្ថាប័នអាពាហ៍ពិពាហ៍។ ប្រភេទកិច្ចសន្យាគ្រប់គ្រងទ្រព្យនេះ ហាក់ពុំទាន់មានលក្ខណៈច្បាស់លាស់សម្រាប់នៅកម្ពុជានាពេលបច្ចុប្បន្នឡើយ ដោយសារតែបទប្បញ្ញត្តិនៅថ្មីសម្រាប់ប្រជាពលរដ្ឋខ្មែរ រួមទាំងវិធានអនុវត្តនៅមានកម្រិត ដែលជាកត្តាធ្វើឲ្យការគ្រប់គ្រងកិច្ចសន្យាទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាពុំទាន់ពេញនិយមសម្រាប់ប្រជាពលរដ្ឋខ្មែរ។

ឆន្ទៈនៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ មិនទាន់គ្រប់គ្រាន់ក្នុងការតតាំងជាមួយតតិយជននៅឡើយទេ លុះត្រាតែសហព័ទ្ធត្រូវបំពេញលក្ខខណ្ឌផ្សេងៗទៀតជាច្រើន ដើម្បីអាចឲ្យសហព័ទ្ធទាំងពីរទទួលបាននូវអត្ថប្រយោជន៍នានាតាមរយៈរបបគ្រប់គ្រងទ្រព្យសម្បត្តិនេះ។ ដូចនេះដើម្បីឲ្យកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យានេះមានសុពលភាព សហព័ទ្ធនីមួយៗត្រូវតែបំពេញលក្ខខណ្ឌធំៗចំនួនពីរគឺលក្ខខណ្ឌគ្រឹះនិងលក្ខខណ្ឌទម្រង់។

## ២.១. លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាប្តីប្រពន្ធ

នៅក្នុងសង្គមខ្មែរជីវិតអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធជារឿងសំខាន់មួយសម្រាប់ដៃគូរដែលរួមរស់នៅជាមួយគ្នា តែនៅពេលដែលអាពាហ៍ពិពាហ៍នោះមិនសមប្រកប គឺតែងតែឃើញមានបញ្ហា រកាំរកូស ទំនាស់មិនចុះសម្រុងនឹងគ្នា អាចឈានរហូតទៅដល់ការលែងលះគ្នា។ ភាពស្មុគស្មាញក៏បានកើតឡើងនៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ គឺទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរវាងសហព័ទ្ធទាំងពីរថាតើសហព័ទ្ធនីមួយៗទទួលបានចំណែកប៉ុណ្ណា។នៅក្នុងអំឡុងពេលមុនមានចំណងអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ បើសហព័ទ្ធទាំងពីរមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិនោះទេត្រូវអនុវត្តនិងបែងចែកតាមប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់។ លក្ខខណ្ឌដើម្បីអាចឲ្យកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមានអានុភាពបាន លុះត្រាតែការព្រមព្រៀងរវាងប្តីប្រពន្ធកើតចេញពីឆន្ទៈពិតប្រាកដដោយគ្មានវិការៈនិងសហព័ទ្ធទាំងពីរត្រូវតែមានសមត្ថភាពតាមផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យា តែបើកិច្ចសន្យានោះធ្វើមុនពេលរៀបការ គូភាគីត្រូវតែគោរពទៅតាមលក្ខខណ្ឌដែលអាចរៀបការបាន ដែលមានបញ្ញត្តិនៅក្នុងច្បាប់ ស្តីពីលក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន។ មិនតែប៉ុណ្ណោះចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះ កម្មវត្ថុត្រូវតែស្របតាមច្បាប់មិនអាចផ្ទុយនឹងការហាមឃាត់របស់ច្បាប់ជាដាច់ខាត ដោយនៅក្នុងខ្លឹមសារនៃកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិត្រូវតែកំណត់ថាទ្រព្យណាជាកម្មសិទ្ធិរបស់អ្នកណា ហើយទ្រព្យណាជាកម្មសិទ្ធិអវិភាគរបស់ប្តីប្រពន្ធ និងចំពោះរាល់ទ្រព្យសម្បត្តិរបស់សហព័ទ្ធជាភាគីទាំងអស់ ទោះខ្លួនរកបានមុន ឬរកបានក្រោយអាពាហ៍ពិពាហ៍ក៏ដោយគឺ សុទ្ធតែអាចជាកម្មវត្ថុនៃការចែងកំណត់ក្នុងកិច្ចសន្យាបាន។ លើកលែងតែពាក់ព័ន្ធនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុង។

### ២.១.១. ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

គោលគំនិតនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា អាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធគឺត្រូវបានបង្កើតចំណងគតិយុត្តមួយដែលអាចកកើតបាននូវ ឥណទេយ្យ និងបំណុលរវាងសហព័ទ្ធ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាគេធ្វើឡើងដោយគោរពតាមឆន្ទៈព្រមព្រៀងរបស់សហព័ទ្ធ ក៏ប៉ុន្តែការព្រមព្រៀងនេះមិនអនុញ្ញាតឲ្យធ្វើផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬផ្ទុយនឹងច្បាប់ដែលបានកំណត់នោះទេ។ តាមរយៈប្រព័ន្ធនេះ គេធ្វើឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឲ្យមានការប្រែប្រួលផ្លូវច្បាប់និងស្ថានភាពជាក់ស្តែង។ កិច្ចសន្យានេះគឺធ្វើឡើងដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្តីប្រពន្ធក្នុងតម្រូវការក្នុងគ្រួសារផងដែរព្រមទាំងបង្ការនូវភាពស្មុគស្មាញក្នុងការបែងចែងទ្រព្យសម្បត្តិពេលដែលសហព័ទ្ធរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍

ផងដែរ។ លើសពីនេះទៅទៀតវាអាចជាកត្តាធ្វើឲ្យទំនាក់ទំនងសហព័ទ្ធមានភាពច្បាស់លាស់តម្លាភាព លើបញ្ហាទ្រព្យ និងចូលរួមពង្រឹងសមភាពយេនឌ័រក្នុងសង្គមផងដែរ។

ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ដូចកិច្ចសន្យាផ្សេងទៀតដែរ គឺត្រូវតែគោរពទៅតាមលក្ខខណ្ឌទូទៅសំខាន់ៗនៃកិច្ចសន្យានីមួយៗ គឺ សមត្ថភាព ការបង្ហាញឆន្ទៈដោយសេរី និងពិតប្រាកដជាដើម។ បន្ថែមពីលើនេះ កិច្ចសន្យាទ្រព្យសម្បត្តិ សហព័ទ្ធត្រូវគោរពទៅតាមទៅតាមលក្ខខណ្ឌដូចជា ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរមិនផ្ទុយនឹងបញ្ញត្តិស្តីពីអាហារកិច្ច មិនផ្ទុយនឹងបញ្ញត្តិស្តីពីភាគបម្រុង និងត្រូវចុះបញ្ជីនៅក្រសួងយុត្តិធម៌។

**២.១.២. ការព្រមព្រៀងក្នុងការបង្ហាញឆន្ទៈ**

នៅក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ការបង្ហាញឆន្ទៈព្រមព្រៀងបង្កើតរវាងសហព័ទ្ធពិតជារឿងសំខាន់ ដោយការព្រមព្រៀងនោះត្រូវតែចេញពីឆន្ទៈពិតប្រាកដ និងគ្មានវិការៈ។ ចំពោះការព្រមព្រៀងដែលត្រូវតែកើតចេញពីឆន្ទៈពិតប្រាកដបានសេចក្តីថា សហព័ទ្ធទាំងសងខាងសុទ្ធតែដឹងនិងយល់ពីខ្លឹមសារនៃកិច្ចសន្យា សុទ្ធតែបានស្គាល់អំពីលទ្ធផលតាមផ្លូវច្បាប់ដែលកើតពីការព្រមព្រៀង។ រីឯការព្រមព្រៀងដែលគ្មានវិការៈវិញគឺត្រូវតែគ្មានការភាន់ច្រឡំ គ្មានការឆបោក គ្មានការបង្ហាញនូវពត៌មានមិនពិត គ្មានការរំលោភលើស្ថានភាពនិងគ្មានការគម្រាមកំហែង។

**២.១.៣. សមត្ថភាពភាគី(សហព័ទ្ធ)**

ប្តីប្រពន្ធគឺជាភាគីនៅក្នុងការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយសហព័ទ្ធទាំងពីរត្រូវតែមានសមត្ថភាពតាមផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យានេះ។ សមត្ថភាពតាមផ្លូវច្បាប់ជាសមត្ថភាពដែលអាចបំពេញកិច្ចការអ្វីមួយស្របតាមច្បាប់ត្រឹមត្រូវ ជារួមជាសមត្ថភាពដែលអាចមានលទ្ធភាពធ្វើសកម្មភាពអ្វីមួយបាន ដោយមានបញ្ញាស្មារតីគ្រប់គ្រាន់ ដឹងខុសដឹងត្រូវ ហើយមិនខុសច្បាប់។ សមត្ថភាពនេះយើងអាចសង្កេតមើលលើបញ្ហាអាយុ និងបញ្ហាវិបត្តិស្មារតីរបស់សហព័ទ្ធ។ ចំពោះបញ្ហាអាយុ សហព័ទ្ធទាំងពីរត្រូវតែមានសមត្ថភាពខាងឆន្ទៈ(យោងតាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណី ចែងថា សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន) បានសេចក្តីថាភាគី ឬសហព័ទ្ធទាំងពីរត្រូវតែជាបុគ្គលដែលមានសមត្ថភាពពេញលេញ មិនអាចជាអនីតិជន ឬក៏ជានីតិជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ឬស្ថិតនៅក្រោមរបបហិតូបត្ថម្ភនោះទេ។ ពាក្យថា អនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។ រីឯបញ្ហាវិបត្តិស្មារតីនៃសហព័ទ្ធវិញ ចង់សំដៅទៅលើជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ឬស្ថិតនៅក្រោមរបបហិតូបត្ថម្ភ ។ ជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ជាជនដែលមិនអាចយល់ដឹងឬវិនិច្ឆ័យពីស្ថានភាពនៃការធ្វើសកម្មភាពរបស់ខ្លួន អំពីលទ្ធផលតាមផ្លូវច្បាប់ដោយសារវិបត្តិស្មារតី ហើយជានិរន្ត៍

ហើយរាល់សកម្មភាពរបស់បុគ្គលប្រភេទនេះត្រូវបានលុបចោល បើគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ។ ឯជនដែលស្ថិតនៅក្រោមរបបហិតូបត្ថម្ភវិញជាជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង ឬក៏វិនិច្ឆ័យពីស្ថានភាពនៃការធ្វើសកម្មភាពរបស់ខ្លួនបាន អំពីលទ្ធផលតាមផ្លូវច្បាប់ដោយសារតែមានវិបត្តិស្មារតី តែមិនជានិរន្តរ៍នោះទេ រាល់សកម្មភាពរបស់បុគ្គលប្រភេទនេះត្រូវបានលុបចោល បើគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ប៉ុន្តែមានសកម្មភាពមួយចំនួនដែលច្បាប់អនុញ្ញាតិដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈនោះទេសកម្មភាពទាំងនោះមានចែងនៅមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ។

## ២.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាប្ដីប្រពន្ធ

កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្រោមទម្រង់ជាលិខិតយថាភូត។ កិច្ចសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់រវាងសហព័ទ្ធពុំមានអានុភាពឡើយ ដែលនេះជាមូលហេតុនាំឲ្យរបបគ្រប់គ្រងទ្រព្យតាមច្បាប់ នឹងចូលខ្លួនអន្តរាគមន៍ដោះស្រាយបញ្ហាជុំវិញការគ្រប់គ្រងទ្រព្យសម្បត្តិ។ តាមរយៈមាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី បាននិយាយថា នៅពេលដែលសំណើរនិងស្វីការត្រូវគ្នា ត្រូវបានចាត់ទុកថាកិច្ចសន្យានោះមានអានុភាព លើកលែងតែមានបទបញ្ញត្តិពិសេសដែលតម្រូវឲ្យមានលក្ខខណ្ឌពិសេស។ លើសពីនេះបើសង្កេតមើលមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីវិញ បានរាយរាប់ថានៅក្នុងបទបញ្ញត្តិពិសេសនៃកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ គឺតម្រូវឲ្យកិច្ចសន្យានោះធ្វើជាលាយលក្ខណ៍អក្សរ ជាងនេះទៅទៀត អាចធ្វើក្រោមទម្រង់ជាលិខិតយថាភូត ឬលិខិតឯកជន។

ម៉្យាងវិញទៀត កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនេះ នឹងមានអានុភាពអាចធ្វើការតតាំងជាមួយតតិយជនបាន លុះត្រាតែមានការចុះបញ្ជី ដោយសារតែការធ្វើកិច្ចសន្យារវាងសហព័ទ្ធពុំទាន់គ្រប់គ្រាន់ឡើយ ព្រោះសហព័ទ្ធអាចធ្វើការបន្លំទៅតតិយជន ដែលជាម្ចាស់បំណុល។ ហេតុដូចនេះហើយក្រៅពីលក្ខខណ្ឌដែលតម្រូវឲ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ សហព័ទ្ធទាំងពីរត្រូវតែបំពេញនូវលក្ខខណ្ឌតតាំងជាមួយតតិយជនទៀត គឺត្រូវតែទៅធ្វើការចុះបញ្ជីទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌។

តាមរយៈសេចក្តីប្រកាសរបស់ក្រសួងយុត្តិធម៌ ស្តីពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ដែលការចុះបញ្ជីកិច្ចសន្យានេះ អាចធ្វើឡើងនៅមុនពេលដែលធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍ (ភាគីទាំងពីរកំពុងស្ថិត នៅក្នុងនីតិវិធីនៃការស្នើសុំចុះសំបុត្រអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុ កូលដ្ឋាន) ឬម៉្យាងទៀតសហព័ទ្ធអាចធ្វើការចុះបញ្ជីនៅពេលណាក៏បានក្នុងលក្ខខណ្ឌតែមួយគត់ គឺអាពាហ៍ពិពាហ៍នោះមិនទាន់បានរលាយ។ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរក៏អាចធ្វើការស្នើសុំកែប្រែកិច្ចសន្យាដែលបានចុះបញ្ជីរួចហើយ ឬធ្វើការលុបចោលនូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះបានដែរ ។

ក្រៅពីលក្ខខណ្ឌតតាំងខាងលើ នូវមានលក្ខខណ្ឌដាច់ខាតដែលកាន់តែចាំបាច់បំផុតនោះ គឺសំបុត្រអាពាហ៍ពិពាហ៍។ បើទោះបីជាអនាគតសហព័ទ្ធទាំងពីរមិនទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយបានទៅចុះបញ្ជីកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ការចុះបញ្ជីកិច្ចសន្យានោះពុំទាន់មានអានុភាពនោះទេ លុះត្រាតែភាគីទាំងពីរទទួលបានសំបុត្រអាពាហ៍ពិពាហ៍។ លក្ខខណ្ឌនេះវាទាក់ទងនឹងទ្រឹស្តី "បន្ទាប់បន្សំត្រូវទៅតាមគោល" បានន័យថា បើអាពាហ៍ពិពាហ៍មិនអាចប្រព្រឹត្តទៅបាន ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិនោះពុំមានអានុភាពនិងសុពលភាពនោះឡើយ។ ម្យ៉ាងទៀតបើអាពាហ៍ពិពាហ៍ ត្រូវបានលុបចោល ឬក៏មោឃភាព នាំឲ្យការលុបចោល ឬមោឃភាពនូវអាពាហ៍ពិពាហ៍នោះ ជះឥទ្ធិពលដល់កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិផងដែរ ដែលធ្វើឲ្យកិច្ចសន្យាពុំមានសុពលភាព។

### ២.២.១. ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ជាទូទៅនៅក្នុងសង្គមខ្មែរយើងគេសង្កេតឃើញថា ក្រោយការលែងលះភាគីទាំងសងខាងពិបាកក្នុងការបែងចែកទ្រព្យសម្បត្តិបានឱ្យស្មើគ្នា ជាពិសេសលើបញ្ហាដីធ្លី និងផ្ទះសំបែង។បញ្ហាទាំងនេះកើតមានដោយសារតែប្តីប្រពន្ធមិនបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិឲ្យបានត្រឹមត្រឹមត្រូវ។ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាកិច្ចសន្យាដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងប្តី និងប្រពន្ធមុនពេលរៀបអាពាហ៍ពិពាហ៍ដោយបានបញ្ជាក់យ៉ាងច្បាស់អំពីទ្រព្យសម្បត្តិទាំងអស់របស់ភាគីទាំង២ មុនពេលរៀបនិងសិទ្ធិលើទ្រព្យសម្បត្តិនោះក្រោយរៀបអាពាហ៍ពិពាហ៍។ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ធ្វើឡើងក្នុងគោលបំណងអនុញ្ញាតឲ្យប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះអាចកំណត់យ៉ាងច្បាស់ពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយការរៀបអាពាហ៍ពិពាហ៍។លើសពីនេះ ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនឹងបង្កភាពងាយស្រួលក្នុងការលក់ដូរឬបែងចែកទ្រព្យនៅពេលមានការលែងលះកើតឡើង ឬភាគីណាមួយបានទទួលមរណភាព។ទ្រព្យសម្បត្តិដែលលើកឡើងខាងលើអាចមានជាច្រើនទម្រង់ ប៉ុន្តែទ្រព្យសម្បត្តិដែលអចលនទ្រព្យ ដូចជាដីធ្លី និងផ្ទះជាដើម គឺមានភាពស្មុគស្មាញខ្លាំងក្នុងការបែកចែក ដោយសារតែអចលនទ្រព្យភាគច្រើនតែងតែឡើងថ្លៃជានិច្ច។ ដូចនេះ ការចុះបញ្ជីបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវធ្វើជាចាំបាច់ ដើម្បីជៀសវាងជម្លោះបែងចែកមិនដាច់ស្រេចរវាងគ្នា។មួយវិញទៀតកាតព្វកិច្ចសងបំណុលរបស់ភាគីប្តី ឬប្រពន្ធដែលមានលើទ្រព្យនោះក៏ចាំបាច់ណាស់ដែរ។ ឧទាហរណ៍ដូចជាបំណុលបង់រំលស់ផ្ទះរួមគ្នាជាដើម ក្រោយលែងលះ អ្នកណាជាអ្នកទទួលខុសត្រូវ ហើយទទួលខុសត្រូវប៉ុន្មានភាគរយដែរ? ដូច្នេះ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងជួយកំណត់ឲ្យច្បាស់ពីទ្រព្យរួម ឬ ទ្រព្យដោយឡែកដែលភាគីណាមួយមានកាតព្វកិច្ចត្រូវចេញសង។

គួរបញ្ជាក់ផងដែរថា ការចុះបញ្ជីនេះត្រូវបានធ្វើឡើងនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។ នាយកដ្ឋាននេះ ទទួលផ្លាស់ប្តូរ និងការលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធផងដែរ។ បើយោង

តាមប្រកាសលេខ៨១ កយ/ប្រក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ស្តីពីឯកសារចាំបាច់ដែលត្រូវភ្ជាប់មកទូទៅពេលចុះបញ្ជីរួមមានៈ

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ)

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ។ ដោយសារតែមានភាពផ្ទុយគ្នានឹងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ហេតុនេះត្រូវមានការបង្ហាញជាសាធារណៈ។ ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយតតិយជនបានឡើយ។ នេះជាចំណុចសំខាន់ក្នុងការតតាំងជាមួយតតិយជនអំពីទ្រព្យសម្បត្តិរបស់យើងបាន។

<u>ឧទាហរណ៍</u> ៖ បញ្ញា ជាប្តីមានចំណូលក្នុង ១ខែ ៥០០$ ចំណែកឯ រចនា ជាប្រពន្ធមានចំណូលក្នុង១ខែ ១០០០$ដែលចំណូលរបស់អ្នកទាំងពីរនឹងក្លាយជាទ្រព្យរួម បើមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប៉ុន្តែ បញ្ញា និងរចនា បានព្រមព្រៀងគ្នាថាដាក់ជាទ្រព្យដោយឡែករៀងៗខ្លួន។ មានពេលមួយប្តីបានជំពាក់បំណុលគេដែលបំណុលនេះកើតឡើងមិនមែនដើម្បីជីវភាពគ្រួសារឡើយ ហើយម្ចាស់បំណុលរបស់ប្តីដោយឃើញប្រពន្ធមានចំណូលខ្ពស់ ចង់រឹបអូសចំណូលរបស់ប្រពន្ធពាក់កណ្តាល ដោយអះអាងថាជាទ្រព្យរួម។ នៅក្នុងករណីនេះបើប្រពន្ធមិនបានយកកិច្ចសន្យាព្រមព្រៀងអំពីទ្រព្យសម្បត្តិប្តីប្រពន្ធទៅចុះបញ្ជីនោះទេ មិនអាចអះអាងថាចំណូល ១០០០$នោះជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ជាមួយតតិយជនបាននោះឡើយ។

- **ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

**ក. គោលការណ៍ទូទៅនៃពាក្យសុំ**

ដើម្បីអាចសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ កិច្ចសន្យានោះត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរដោយមានសរសេរនូវបាវចនាជាតិ ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (ប្រការ ១៦-១)។ ចំពោះពាក្យសុំច្បាប់ដើមត្រូវមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ និងភ្ជាប់ជាមួយនឹងច្បាប់ចម្លង(ប្រការ ១៥-១)។ រីឯបុគ្គល ឬអ្នកតំណាង ត្រូវ

យកពាក្យសុំមកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌(ប្រការ ១៥-៤)។ មិនតែប៉ុណ្ណោះ អ្នកដាក់ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនិងឯកសារចាំបាច់មួយចំនួនទៀត បើសិនជាគេត្រូវការក្នុងការដាក់ពាក្យសុំនោះ។

**ខ. ប្រភេទទម្រង់នៃពាក្យសុំ និងឯកសារភ្ជាប់**

❖ **ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** [29]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគី

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទនៃការចុះបញ្ជី

-ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ប្រសិនបើបានរៀបអាពាហ៍ពិពាហ៍

\+ **ចំពោះឯកសារភ្ជាប់**

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ប្រសិនបើពាក់ព័ន្ធនឹងបញ្ហាដីធ្លី

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**[30]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគី

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទនៃការចុះបញ្ជី

-ចំណុចដែលត្រូវផ្លាស់ប្តូរ ( ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី និងឈ្មោះ ឬអាសយដ្ឋា ន ថ្មី)

\+ **ចំពោះឯកសារភ្ជាប់**

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី

-សាលក្រម ឬដីកាសម្រេចផ្លាស់ប្តូរ

[29] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ១៩។

[30] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២០។

-វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ប្រសិនបើពាក់ព័ន្ធនឹងបញ្ហាដីធ្លី

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**[31]

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទនៃការចុះបញ្ជី

-ចំណុចដែលត្រូវកែតម្រូវ (មានឈ្មោះ អាសយដ្ឋានថ្មី ថ្ងៃខែឆ្នាំកំណើត កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ និងខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

+ **ចំពោះឯកសារភ្ជាប់**

-កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី ប្រសិនបើពាក់ព័ន្ធនឹងបញ្ហាដីធ្លី

-លិខិតបញ្ជាក់អាសយដ្ឋាន

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីអំពីការលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុរំលាយអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ** [32]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទរំលាយអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ)

+ **ចំពោះឯកសារភ្ជាប់**

-សេចក្ដីសម្រេច ដែលរំលាយចំណងអាពាហ៍ពិពាហ៍

-លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសេចក្ដីសម្រេច

-កិច្ចព្រមព្រៀង ឬការជូនដំណឹងអំពីការរំលាយកំជាប់ពាក្យ

[31] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២១។

[32] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២២។

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីអំពីការលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុមោឃភាព ការលុបចោល ឬរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** [33]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព ការលុបចោល ឬរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

+ **ចំពោះឯកសារភ្ជាប់**

-សេចក្តីសម្រេច មោឃៈ លុបចោល ឬរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសេចក្តីសម្រេច

-កិច្ចព្រមព្រៀង ឬការជូនដំណឹងដែលបញ្ជាក់អំពីការលុបចោល ឬរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីអំពីការលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់** [34]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

+ **ចំពោះឯកសារភ្ជាប់**

-សំបុត្រមរណភាព

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

❖ **ពាក្យសុំចុះបញ្ជីអំពីការលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើសេចក្តីសម្រេចស្ថាពររំលាយអាពាហ៍ពិពាហ៍ និងបែងចែកទ្រព្យសម្បត្តិ** [35]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

---

[33] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២៣។

[34] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២៤។

[35] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២៥។

-គោលបំណងនៃការចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្ដីសម្រេច)

+ **ចំពោះឯកសារភ្ជាប់**

-សេចក្ដីសម្រេចរំលាយអាពាហ៍ពិពាហ៍ និងបែងចែកទ្រព្យសម្បត្តិដែលស្ថាពរ

-លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសេចក្ដីសម្រេច

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

❖ **ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍** [36]

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

-គោលបំណងនៃការចុះបញ្ជី

-កាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍

+ **ចំពោះឯកសារភ្ជាប់**

-សំបុត្រអាពាហ៍ពិពាហ៍

-លិខិតប្រគល់សិទ្ធិតំណាង ប្រសិនបើមាន

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

**គ. ការទទួលពាក្យសុំ**

នៅពេលដែលមានការទទួលពាក្យសុំ មន្ត្រីចុះបញ្ជីត្រូវចុះលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទនិងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងចុះហត្ថលេខាបំពេញ និងឈ្មោះមន្ត្រីចុះបញ្ជី។ បន្ទាប់មកមន្ត្រីចុះបញ្ជីត្រូវសរសេរក្នុងសន្លឹកក្រដាសទទួលពាក្យសុំ [37] ដូចខាងក្រោម៖

-លេខរៀងទទួល

-កាលបរិច្ឆេទនៃការទទួល

-ប្រភេទនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ

-ជាប្ដីប្រពន្ធ ឬបុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍

-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (បើមាន)

-ផ្សេងៗ ។ល។

[36] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ២៨។

[37] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ៣៧។

**ឃ. ការចុះបញ្ជីក្នុងក្រូណូ**

ក្រោយពីពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវសរសេរក្នុងសន្លឹកចុះបញ្ជីដូចខាងក្រោម [38] ៖

-ត្រូវមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគី

-ខ្លឹមសារនៃកិច្ចសន្យា

-កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

-គោលបំណងនៃថ្ងៃចុះបញ្ជី

-មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យា)

**ខ. ការចាប់ផ្ដើមអានុភាពនៃការចុះបញ្ជី**

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[39]

**២.២.២. នីតិវិធីនៃការចេញលិខិតបញ្ជាក់**

**ក. ពាក្យសុំឲ្យចេញលិខិតបញ្ជាក់**

ពាក្យសុំលិខិតបញ្ជាក់ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ដោយសរសេរជាលាយលក្ខណ៍អក្សរនូវចំណុចដូចខាងក្រោម៖ [40]

-គោលបំណងនៃពាក្យសុំ ៖ការសុំឲ្យចេញលិខិតបញ្ជាក់

-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់

-ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំជានីតិបុគ្គល

-ចំណុចដែលត្រូវធ្វើការបញ្ជាក់

-ចំនួនលិខិតបញ្ជាក់

-កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬស្នាមមេដៃ

**ខ. ការចេញលិខិតបញ្ជាក់**

មន្ត្រីចុះបញ្ជី ត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធទៅឲ្យអ្នកដាក់ពាក្យសុំដោយសរសេរនៅលើឯកសារថតចម្លងនោះថា៖ [41]

-បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

[38] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ៣៨។

[39] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ៣៦។

[40] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ៤៨។

[41] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ,លេខ៨១កយ/ប្រក/១៣,ប្រការ ៤៩។

-កាលបរិច្ឆេទ (ថ្ងៃទី..........ខែ...............ឆ្នាំ.................)

-ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ក្នុងអំឡុងពេល៣ថ្ងៃ

## ២.៣. ការបញ្ចប់របបគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា

មានមូលហេតុជាច្រើនដែលធ្វើឲ្យរបបមួយនេះ ត្រូវបានបញ្ចប់ ជាគោលការណ៍គឺវាផ្សាភ្ជាប់ជាមួយនឹងជីវិតអាពាហ៍ពិពាហ៍ បានសេចក្ដីថា ករណីដែលអាពាហ៍ពិពាហ៍ត្រូវបានរកឃើញថា មានបញ្ហាពាក់ព័ន្ធនឹងលក្ខខណ្ឌសុពល ដូចជា ការលុបចោល ឬមោឃភាព វានាំឲ្យរបបគ្រប់គ្រងទ្រព្យសម្បត្តិមួយនេះត្រូវបានបញ្ចប់។ នៅក្នុងករណីមួយទៀត គឺការលែងលះ ក៏ធ្វើឲ្យរបបនេះត្រូវបានបញ្ចប់ដែរ។ មិនតែប៉ុណ្ណោះចំពោះមរណៈភាព ឬការបាត់ខ្លួនរបស់សហព័ទ្ធណាម្ខាង ក៏វាបណ្ដាលឲ្យរបបមួយនេះបញ្ចប់ផងដែរ។ ប៉ុន្តែបើសហព័ទ្ធទាំងសងខាងមានឆន្ទៈរួមគ្នា ក្នុងការលុបចោលនូវការចុះបញ្ជីកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធ ទៅជាការគ្រងទ្រព្យសម្បត្តិតាមច្បាប់វិញ គឺវាបានបណ្ដាលឲ្យរបបគ្រប់គ្រងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាត្រូវបានបញ្ចប់ដូចគ្នា។

អានុភាពនៃការបញ្ចប់របបខាងលើដូចជានៅក្នុងករណីការលែងលះ ឬទទួលមរណៈភាព គឺវានាំឲ្យសហព័ទ្ធទាំងសងខាង បញ្ចប់ទាំងសិទ្ធិ និងករណីយកិច្ច រួមទាំងការលុបចោលពីបញ្ជីដែលបានចុះកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិ។

## ២.៤. ផលប្រយោជន៍ និងផលវិបាកនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

### ២.៤.១. ផលប្រយោជន៍

#### ក. កាត់បន្ថយចំណុចវិវាទអំពីទ្រព្យ

ការកំណត់នូវទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធតាមកិច្ចសន្យា គឺជាកត្តាមួយដែលជួយឲ្យសហព័ទ្ធមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិឲ្យបានត្រឹមត្រូវ និងមានសមភាពក្រោយពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ជាក់ស្ដែងនៅក្នុងករណីដែលសហព័ទ្ធកំណត់ថា ទ្រព្យណាមួយជាទ្រព្យរួមនោះនៅពេលដែលភាគីណាមួយទទួលមរណភាព ទ្រព្យនោះនឹងក្លាយជាទ្រព្យរបស់ភាគីជាសហព័ទ្ធម្ខាងទៀត ក៏ប៉ុន្តែមិនអាចបំពានលើភាគបំរុងបានទេ។ សហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តិជនជានិច្ច។

#### ខ. កំណត់ពីទំនាក់ទំនងភាតព្វកិច្ច និងសិទ្ធិលើចំណូល

ជាគោលការណ៍ចំពោះប្ដី ឬប្រពន្ធ មានកាតព្វកិច្ចទំនុកបំរុងក្នុងជីវភាពប្រចាំថ្ងៃ ចំណូលដែលរកបាន ឬប្រាក់បៀវត្សដែលរកបានត្រូវចាត់ទុកជាទ្រព្យរួម ដែលទំនាក់ទំនងទ្រព្យនេះត្រូវបានកំណត់នៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពីពាហ៍របស់សហព័ទ្ធតាមរយៈកិច្ចសន្យា។ ដោយឡែកក្នុងកំឡុងពេលនៃ

អាពាហ៍ពិពាហ៍ដែលប្តី ប្រពន្ធបានព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលវាជាការទទួលខុសត្រូវរួមដោយសាមគ្គី។ នៅត្រង់ចំណុចទាមទារឲ្យមានលក្ខខណ្ឌចាំបាច់នៃលិខិតជាលាយលក្ខណ៍អក្សរ និងការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ។ ទោះជាយ៉ាងណាក៏ដោយជាគោលការណ៍បន្ទុកនៃកាតព្វកិច្ចត្រូវជាទ្រព្យសម្បត្តិរួម ដូច្នេះហើយសិទ្ធិចំពោះទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធម្ខាងទៀត មិនត្រូវបានការពារទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលសុចរិតហើយគ្មានកំហុស លើកលែងតែករណីដែលបានធ្វើការចាត់វិធានការរក្សាការពារចំពោះទ្រព្យសកម្ម។

**គ. កំណត់ពីសិទ្ធិគ្រប់គ្រង និងបែងចែកទ្រព្យសម្បត្តិ**

ជាទូទៅកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់យ៉ាងជាក់លាក់អំពីទ្រព្យសម្បត្តិដែលសហព័ទ្ធមាន។ ការបែងចែកឲ្យដាច់ពីគ្នារវាងទ្រព្យរបស់សហព័ទ្ធ ពោលគឺទ្រព្យណាដែលជាទ្រព្យរបស់ប្តី ទ្រព្យណាជារបស់ប្រពន្ធ ហើយទ្រព្យណាជាទ្រព្យរួមដែលសហព័ទ្ធទាំងពីររកបាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នឹងជាកត្តាមួយយ៉ាងសំខាន់នៅក្នុងការកំណត់អំពីម្ចាស់កម្មសិទ្ធិនៃទ្រព្យ ហើយតាមរយៈការកំណត់កម្មសិទ្ធិនេះអាចធ្វើឲ្យប្តីប្រពន្ធអាចបែងចែកគ្នាដាច់ចំពោះសិទ្ធិក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យដែលអាចបង្ការ ឬធ្វើឲ្យសហព័ទ្ធជៀសផុតបញ្ហាជម្លោះដែលកើតមានឡើងតាមរយៈការប្រើប្រាស់ទ្រព្យ។ ម៉្យាងវិញទៀតសហព័ទ្ធទាំងសងខាងមានសិទ្ធិយ៉ាងពេញលេញក្នុងការប្រើប្រាស់ និងគ្រប់គ្រងលើទ្រព្យទាំងឡាយណាដែលជាទ្រព្យដោយឡែក និងមានសិទ្ធិគ្រប់គ្រងទៅលើទ្រព្យរួមផងដែរ ក៏ប៉ុន្តែក្នុងការចាត់ចែងទ្រព្យរួមគេតម្រូវឲ្យមានការសហការគ្នារវាងសហព័ទ្ធទាំងពីរ លើកលែងតែក្នុងករណីចាំបាច់មួយដែលមានប ញ្ញត្តិនៅក្នុងច្បាប់។

**ឃ. សម្រួលនីតិវិធីដោះស្រាយដល់តុលាការ**

ជាការពិតណាស់ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ដែលបង្កើតឡើងឲ្យមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ មានគោលបំណងអនុញ្ញាតឲ្យសហព័ទ្ធអាចចុះនូវកិច្ចសន្យាដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យប្តីប្រពន្ធ។ដូច្នេះដោយសារតែកិច្ចសន្យានេះមានទម្រង់ ជាលិខិតលាយលក្ខណ៍អក្សរ ថែមទាំងអាចស្នើសុំចុះបញ្ជីដើម្បីក្លាយជាលិខិតយថាភូតទៀតនោះ ដែលនាំឲ្យប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះមានភាពអំណោយផលក៏ដូចជាអនុគ្រោះយ៉ាងមានប្រសិទ្ធភាពចំពោះដំណើរការនីតិវិធី ព្រមទាំងជាវត្ថុតាងដល់តុលាការចំពោះការវិនិច្ឆ័យដែលក្នុងនោះការសម្រួលជាពិសេសដល់តុលាការនៅក្នុងវិវាទលែងលះ វិវាទផ្ទេរកម្មសិទ្ធិ និងវិវាទក្នុងករណីទាមទារឲ្យអនុវត្តកាតព្វកិច្ច។

**២.៤.២. ផលវិបាក**

ជាធម្មតាជីវិតអាពាហ៍ពិពាហ៍រឿងដែលសំខាន់គឺការយល់ចិត្តគ្នា យកចិត្តទុកដាក់និងការទុកចិត្តគ្នាទៅវិញទៅមក ទើបធ្វើឲ្យសម្ព័ន្ធភាពគ្រួសារទៅដោយរលូន មិនងាយរង្គោះរង្គើរឡើយ។ នៅពេលដែលប្តីប្រពន្ធមានបំណងចង់បង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិ ដើម្បីការពារនៅពេលដែលមានជម្លោះកើតឡើងវាជាហេតុធ្វើឲ្យទំនាក់ទំនងរវាងប្តីប្រពន្ធគឺបង្កើនភាពមិនទុកចិត្តគ្នាកើតឡើង ដោយសហព័ទ្ធនីមួយៗអាចមានគំនិតគិតថាប្តីឬប្រពន្ធមានបំណងចង់លែងលះគ្នាហើយ ទើបបានជាបង្កើតនូវកិច្ចសន្យានោះកើតឡើង។ មិនតែប៉ុណ្ណោះ វាធ្វើឲ្យមនោសញ្ចេតនារវាងប្តីប្រពន្ធងាយនឹងបែកបាក់ ផុយស្រួយ ហើយមិនអាចជួយស្រង់ឲ្យដូចដើមបាននោះទេ ។

# សេចក្តីសន្និដ្ឋាន

៙៙៙🕮៧៧៧

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវប្រធានបទខាងលើមក យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ក្នុងការលើកយកមកសិក្សាបកស្រាយដើម្បីអាចឲ្យប្រជាពលរដ្ឋទូទៅឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីភាពចាំបាច់ គោលបំណង និងផលប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ព្រោះវាជាកិច្ចចម្បងមួយដែលពួកគេគប្បីយល់ដឹង និងយល់ពេលពួកគេរៀបអាពាហ៍ពិពាហ៍។ ព្រមទាំងជួយបង្កា ទប់ស្កាត់នូវជម្លោះរវាងប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍និងគ្នា។ ជាធម្មតាទេដែលប្តីប្រពន្ធរួមរស់នៅជាមួយគ្នាយូរៗទៅកាន់តែមានបញ្ហា ប៉ុន្តែក៏មិនមែនសុទ្ធតែជីវិតអាពាហ៍ពិពាហ៍ប្តីប្រពន្ធជួបបញ្ហាបែបនេះដែរ គូខ្លះរស់នៅជាមួយគ្នាយ៉ាងសុខសាន្ត យ៉ាងមានក្តីសុខ ។ តែនៅពេលដែលជីវិតអាពាហ៍ពិពាហ៍នោះមិនសមតាមបំណងប្រាថ្នាចង់បានរវាងដៃគូ ប្តីប្រពន្ធតែងតែមានបញ្ហាទំនាស់ជារឿយៗហើយអាចឈានទៅរកនូវការលែងលះគ្នា។ ដំណាក់កាលនេះ ជាដំណាក់កាលពិបាកស្មុគស្មាញរបស់ជីវិតប្តីប្រពន្ធ ព្រោះថាការរួមរស់នៅជាមួយគ្នាកាន់តែយូរទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរមាន មិនថាមានមុន ឬក្រោយអាពាហ៍ពិពាហ៍នោះទេ គឺមានភាពច្របូកច្របូលចូលគ្នា និងពិបាកប្រាប់ថាទ្រព្យណាជាទ្រព្យរបស់សហព័ទ្ធម្ខាងណា។ ហេតុនេះហើយទើបគេឃើញនៅក្នុងក្រមរដ្ឋប្បវេណី ក៏ដូចគ្នានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់ប្រភេទនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធបានយ៉ាងច្បាស់លាស់ ដោយទ្រព្យសម្បត្តិនោះបានបែងចែកជាពីរ គឺទ្រព្យដោយឡែកនិងទ្រព្យសម្បត្តិរួម។ គេបានកំណត់ថាទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរមានមុនពេលរៀបអាពាហ៍ពិពាហ៍និងទ្រព្យដែលសហព័ទ្ធទទួលបានពីប្រទានកម្ម សន្តតិកម្មឬក៏អច្ច័យទាននៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ព្រមទាំងទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលកើតចេញពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួនរបស់សហព័ទ្ធ។ រីឯទ្រព្យសម្បត្តិរួមវិញ ជាទ្រព្យសម្បត្តិទាំងឡាយដែលសហព័ទ្ធទាំងពីរឬក៏តែម្ខាងរកបាន និងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យដែលមានកំណត់នៅក្នុងទ្រព្យដោយឡែក។ ទាំងនេះហើយដែលជាការកំណត់ឲ្យបានជាក់លាក់ច្បាស់លាស់នៃទ្រព្យសម្បត្តិរវាងសហព័ទ្ធឲ្យមានភាពត្រឹមត្រូវ និងគ្មានការឈ្លោះទាស់ទែងគ្នា នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយផងដែរ។

លើសពីនេះទៅទៀត នៅពេលដែលមាននូវការកំណត់ប្រភេទនៃទ្រព្យសម្បត្តិរួចហើយ នៅពេលចំណងអាពាហ៍ពិពាហ៍សហព័ទ្ធទាំងពីរនឹងមានការទាមទារឲ្យមាននូវការបែងចែកទ្រព្យសម្បត្តិនោះ។ ជាក់ស្តែងយើងខ្ញុំសង្កេតឃើញថា ប្តីប្រពន្ធមានផលវិបាកនៅក្នុងការបែងចែកទ្រព្យសម្បត្តិនោះឲ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌។ ដូចនេះនៅក្នុងក្រមរដ្ឋប្បវេណីក៏បានកំណត់ពីការចាត់ចែង ឬបែងចែកទ្រព្យនោះដូចគ្នាដោយបាន

ធ្វើការកំណត់ច្បាស់លាស់ថា ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធអាចធ្វើការបែងចែកតាមការកំណត់របស់ច្បាប់ ឬ តាមកិច្ចសន្យាប្តីប្រពន្ធ។ ក្នុងនេះផងដែរសហព័ទ្ធ មានសិទ្ធិសេរីភាពនៅក្នុងការកំណត់យកនូវទ្រព្យសម្បត្តិរបស់ពួកគេតាមការព្រមព្រៀងលើកិច្ចសន្យាទ្រព្យសម្បត្តិ ឬតាមការកំណត់របស់ច្បាប់។ ភាពខុសប្លែកនោះត្រង់ថាបើពួកគេយល់ព្រមធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះពួកគេតម្រូវឲ្យមាននូវការព្រមព្រៀងបង្កើតកិច្ចសន្យានោះ និងត្រូវមានការចុះបញ្ជីយ៉ាងត្រឹមត្រូវស្របទៅតាមនីតិវិធីនៃក្រសួងយុត្តិធម៌ តែបើភាគីទាំងសងខាងយល់ថា កិច្ចសន្យាទ្រព្យសម្បត្តិនេះមិនចាំបាច់បង្កើតសម្រាប់ពួកគេនោះទេ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមការកំណត់របស់ច្បាប់ នឹងចូលខ្លួនមកអនុវត្ត។ សម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា មានគោលបំណងក្នុងការកំណត់យកអំពីសេរីភាពនិងឆន្ទៈរបស់បុគ្គលឯកជនក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេ នៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ក្នុងនាមជាប្តីប្រពន្ធ។ មិនតែប៉ុណ្ណោះ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះអាចធ្វើការកែប្រែ ផ្លាស់ប្តូរ និងលុបចោលបានទៅតាមការព្រមព្រៀងគ្នារវាងសហព័ទ្ធទាំងពីរ ដោយអនុវត្តទៅតាមនីតិវិធីដែលមានចែងនៅក្នុងប្រកាសនៃក្រសួងយុត្តិធម៌។កិច្ចសន្យាទ្រព្យសម្បត្តិនេះអាចឲ្យសហព័ទ្ធមានសិទ្ធិក្នុងការអះអាងជាមួយនិងតតិយជនបាន នៅក្នុងកម្រិតទំហំនៃទ្រព្យសម្បត្តិដែលពួកគេមាន និងជួយសម្រួលទៅដល់តតិយជនផ្សេងទៀតឲ្យដឹងពីទំហំនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធនីមួយៗ នៅមុនពេលដែលពួកគេសម្រេចធ្វើជំនួញឬពាណិជ្ជកម្មជាមួយប្តី ឬប្រពន្ធនោះ។ ចំពោះសារៈសំខាន់ផ្សេងទៀតនៃកិច្ចសន្យាទ្រព្យសម្បត្តិនេះ គឺនៅពេលដែលសហព័ទ្ធធ្វើការលែងលះគ្នា ព្រោះនៅពេលដែលប្តីប្រពន្ធបានប្រកាន់យកប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ពួកគេបានព្រមព្រៀងក្នុងការកំណត់បែងចែកយ៉ាងច្បាស់ទាក់ទងនឹងទ្រព្យដោយឡែក និងទ្រព្យរួម ជាមួយនិងកាតព្វកិច្ចណាមួយដែលជាកាតព្វកិច្ចរួម ឬកាតព្វកិច្ចផ្សេងទៀតជាកាតព្វកិច្ចដោយឡែក។ ក្នុងន័យនេះ ក៏វាបានជួយសម្រួលនីតិវិធីរបស់តុលាការ ព្រោះថាតុលាការសម្រេចទៅតាមអ្វីដែលកំណត់នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិនោះតែប៉ុណ្ណោះ ក៏ប៉ុន្តែតុលាការនិងពិចារណាមើលតទៅទៀតដែរថា តើទ្រព្យសម្បត្តិដែលមានកំណត់នៅក្នុងខ្លឹមសារនៃកិច្ចសន្យាទាំងនោះ មានផ្ទុយពីសណ្តាប់ធ្នាប់ជាសាធារណៈ ឬបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងដែរឬទេ។ ចំណែកឯប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់វិញ គឺច្បាប់មានគោលបំណងចង់រក្សានូវចំណងអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋឲ្យកាន់តែមានភាពរឹងមាំ តាមរយៈការចេះជួយសង្គ្រោះគ្នាទៅវិញទៅមក ការសហការគ្នាក្នុងការរស់នៅ និងការសាមគ្គីភាពគ្នារវាងប្តីប្រពន្ធនៅក្នុងការដោះស្រាយបំណុលរួមដែលកើតមានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារផងដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមការកំណត់របស់ច្បាប់ មានអត្ថប្រយោជន៍នៅពេលដែលប្តីប្រពន្ធណាម្ខាង ធ្វេសប្រហែសក្នុងការដើរតួជាប្តីឬប្រពន្ធ និងជាម្តាយ ឬឪពុកសម្រាប់កូនៗ នោះច្បាប់តម្រូវ ឲ្យពួកគេ មានការជួយសហការគ្នាទៅវិញទៅមក ដែលមាន

បញ្ញត្តិនៅក្នុងច្បាប់ជាសំអាង។ នៅពេលសហព័ទ្ធទាំងពីរធ្វើការលែងលះ ប្រព័ន្ធទ្រព្យសម្បត្តិប្តីដែលកំណត់តាមច្បាប់និងចូលខ្លួនក្នុងការចាត់ចែងរបស់តុលាការដោយតុលាការសម្រេចសេចក្តីទៅតាមការព្រមព្រៀង និងភស្តុតាងនានា ដែលបញ្ជាក់នូវទ្រព្យសម្បត្តិរបស់ពួកគេទាំងពីរ ដែលខុសពីអ្វីដែលសហព័ទ្ធបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយតុលាការសម្រេចតែទៅតាមអ្វីដែលមានកំណត់នៅក្នុងខ្លឹមសារនៃកិច្ចសន្យានោះតែប៉ុណ្ណោះ។

សរុបសេចក្តីមក នៅក្នុងពេលរៀបអាពាហ៍ពិពាហ៍ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលរួមមានប្រព័ន្ធទ្រព្យសម្បត្តិរួម និងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប៉ុន្តែប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានកំណត់និងធ្វើការចាត់ចែងប្រើប្រាស់ និងគ្រប់គ្រងនៅក្នុងកម្រិតនៃការសាមគ្គីភាព ការសហការគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមក និងក្រោយពេលលែងលះ មានការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរួម តាមច្បាប់ ឬតាមកិច្ចសន្យា ទៅឲ្យសហព័ទ្ធទាំងសងខាងទៅតាមសមាមាត្រនៃចំណែករបស់ខ្លួននៅក្នុងកិច្ចសន្យា ឬតាមច្បាប់រៀងខ្លួន។

# អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹងការសរសេរសារណា និងការសិក្សាស្រាវជ្រាវយ៉ាងហ្មត់ចត់កន្លងមកយើងខ្ញុំសង្កេតឃើញថា យោងតាមខ្លឹមសារនៃសារណាទាំងមូលទាមទារឲ្យសហព័ទ្ធគោរពឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ដែលបានបញ្ញត្តិរួចជាស្រេចទៅតាមក្រមរដ្ឋប្បវេណី ដើម្បីឲ្យទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធមានភាពត្រឹមត្រូវ។ ផ្ទុយមកវិញដើម្បីគោរពទៅតាមលក្ខខណ្ឌឲ្យបានត្រឹមត្រូវនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធក៏ត្រូវមានអាពាហ៍ពិពាហ៍ស្របតាមច្បាប់ដែរ ប្រសិនបើមិនគោរពតាមលក្ខខណ្ឌ ឬ ទៅតាមគោលការណ៍ច្បាប់នោះទេ ទៅថ្ងៃក្រោយនាំឲ្យមានភាពស្មុគស្មាញនិងឈានដល់មានវិវាទជាក់ជាមិនខាន។

បន្ទាប់ពីបានសិក្សាឲ្យកាន់តែស៊ីជម្រៅហើយមក យើងខ្ញុំមើលឃើញនូវកង្វះខាតមួយចំនួន ដែលមាននៅក្នុងការគ្រប់គ្រង និងបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធនូវពុំទាន់មានវិសាលភាពធំទូលាយនៅឡើយ។ ជាក់ស្តែងតម្រូវឲ្យមានអង្គភាពរៀបចំគ្រប់គ្រងលើប្រព័ន្ធទ្រព្យសម្បត្តិដែលរួមមាន ការចុះបញ្ជីឲ្យបានត្រឹមត្រូវគ្រប់លក្ខខណ្ឌ ការរៀបចំលិខិតបទដ្ឋានគតិយុត្តិដើម្បីធានាដល់ការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិនេះ ជៀសវាងឲ្យមានវិវាទកើតឡើងមិនឈប់ឈរដោយសារតែប្រជាពលរដ្ឋនៅពុំទាន់យល់ដឹង និងប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះនៅឡើយ។ដោយឡែកការបែងចែកធ្វើឡើងក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងដែលជាគតិយុត្តិ ឬ ដោយការចុះបញ្ជី ត្រង់ចំណុចនេះភាគីម្ខាងពុំទាន់ពេញចិត្តនូវសេចក្តីសម្រេចនៃការបែងចែក ទើបកើតមាននូវការប្តឹងទាស់លើសេចក្តីសម្រេចដែលជាបញ្ហានៃវិវាទ។ សម្រាប់ការលើកឡើងរបស់យើងខ្ញុំទាំងពីរ យល់ឃើញថាគួរតែជម្រុញលើប្រព័ន្ធគ្រប់គ្រង និងបែងចែកឲ្យស្របតាមស្មារតីច្បាប់ដែលបានកំណត់និងព្រមព្រៀងដោយស្មើភាពគ្នាទៅលើប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធគម្បីកាត់បន្ថយនូវភាពស្មុគស្មាញក្នុងសង្គម។

ជាការពិតណាស់យើងខ្ញុំសូមលើកទឹកចិត្តចំពោះគូ ស្វាមី ភរិយា ដែលទើបនិងរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ទាំងអស់ គួរតែចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងគួរតែគិតពីផលអវិជ្ជមានទៅថ្ងៃខាងមុខដែលអាចកើតមានក្នុងជីវិតអាពាហ៍ពិពាហ៍ ព្រមទាំងបានធ្វើឲ្យទំនុកចិត្តប្តីប្រពន្ធគឺមិនប៉ះពាល់ចំពោះទំនាក់ទំនងល្អរបស់ប្តី និងប្រពន្ធឡើយ។ តាមការសង្កេតឃើញជាក់ស្តែងប្តីប្រពន្ធមួយភាគធំ បានធ្វេសប្រហែសក្នុងការអើពើនូវការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធពីព្រោះសហព័ទ្ធទាំងនោះគិតថាពួកគេបានរស់នៅជាមួយគ្នាមានភាពសុខដុមរមនាហើយ ដោយមិនបានគិតថាអាចកើតមានវិវាទកើតឡើងនៅពេលសហព័ទ្ធម្ខាងបំពានសិទ្ធិ។ ដូច្នេះហើយ យើងខ្ញុំសុំលើកយកនូវសំណូមពរដល់រាជរដ្ឋាភិបាលនូវចំណុចដូចខាងក្រោម៖

- នាយកដ្ឋានចុះបញ្ជីនិងតម្កល់ នៃអគ្គនាយកដ្ឋានរដ្ឋប្បវេណីនៅក្រសួងយុត្តិធម៌ គប្បីមានយន្តការនៃការផ្សព្វផ្សាយឲ្យមានភាពទូលំទូលាយដូចជា ការផលិតស្ពតអប់រំ ការផ្សព្វផ្សាយតាមបណ្តាញទំនាក់

ទំនងសង្គម និងផ្សព្វផ្សាយតាមសាធារណៈដើម្បីអាចឲ្យប្រជាពលរដ្ឋបានឃើញ បានយល់ដឹងពីភាពចាំបាច់នៃប្រព័ន្ធទ្រព្យសម្បត្តិនេះ។

- ដាក់ស្តែងតម្រូវឲ្យមានអង្គភាពរៀបចំគ្រប់គ្រងលើប្រព័ន្ធទ្រព្យសម្បត្តិដែលរួមមាន ការចុះបញ្ជីឲ្យបានត្រឹមត្រូវ ឆាប់រហ័ស មិនយឺតយ៉ាវ ។ការរៀបចំលិខិតបទដ្ឋានផ្សេងៗដើម្បីធានាដល់ការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិនេះ ជៀសវាងឲ្យមានវិវាទកើតឡើងមិនឈប់ឈរដោយសារតែប្រជាពលរដ្ឋនៅពុំទាន់ប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះនៅឡើយ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ដែលជានិស្សិតជំនាញផ្នែកនីតិសាស្ត្រ យើងខ្ញុំសូមសន្យាថានឹងចែករំលែកនូវចំណេះដឹង ព្រមទាំងផ្តល់ជាប្រឹក្សា ឬ ផ្តល់ជាគំនិត ជូនពួកគាត់ដែលពុំទាន់យល់ដឹងអំពីព័ត៌មាននេះ និងអ្នកដែលពុំយល់ដឹងច្បាស់ពីបញ្ហាទាំងនេះ ដើម្បីឲ្យពួកគាត់កាន់តែយល់ច្បាស់ និងដោះស្រាយជាមួយដៃគូរបស់ពួកគាត់ប្រកបទៅដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់ ឥតលម្អៀង។

# ឯកសារយោង

# ឯកសារយោង

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

៣. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១

៤. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩

៥. ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធប្រកាសក្រសួងលេខ ៨១កយ/ប្រក/១៣ចុះថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០១៣

៦. ប្រកាសអន្តរក្រសួងលេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

៧. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០១០

៨. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការប្រចាំក្រសួងយុត្តិធម៌ ជំនាញការផ្នែកច្បាប់៖ អ៊ីសូអ៊ីមីហា

៩. កម្រងមេរៀនដែលស្តីពីការបកស្រាយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ របស់លោកសាស្ត្រាចារ្យច្បាប់ជប៉ុន Masayuki Tanamura

១០. សៀវភៅមេរៀនរដ្ឋប្បវេណី ដែលរៀបរៀងដោយសាស្ត្រាចារ្យ ប៊ួយ ធីតា

១១. ការបកស្រាយប្រព័ន្ធទ្រព្យរួមប្តីប្រពន្ធ ដោយសាស្ត្រាចារ្យហ៊ីង គីមឡេង និងឆឹង ស៊ីនៀង កាលបរិច្ឆេទថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៦

១២. កម្រងមេរៀនដែលស្តីពីការបកស្រាយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់ និងតាមកិច្ចសន្យា របស់លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ្ត

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

-ឧបសម្ព័ន្ធទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

-ឧបសម្ព័ន្ធទី២ ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

-ឧបសម្ព័ន្ធទី៣ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១

-ឧបសម្ព័ន្ធទី៤ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩

-ឧបសម្ព័ន្ធទី៥ ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រកាសក្រសួងលេខ ៨១កយ/ប្រក/១៣ ចុះថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០១៣

-ឧបសម្ព័ន្ធទី៦ ប្រកាសអន្តរក្រសួងលេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

-ឧបសម្ព័ន្ធទី៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០១០

-ឧបសម្ព័ន្ធទី៨ ឯកសារផ្សេងៗដែលទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

# ឧបសម្ព័ន្ធទី១

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# ឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៧

- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីក្រសួងយុត្តិធម៌ ឆ្នាំ ២០១០

# សេក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

ផ្ទុយទៅវិញ ក្នុងករណីដែលច្បាប់ពិសេសត្រូវបានតាក់តែង ឧទាហរណ៍ ច្បាប់ពិសេសអំពីកិច្ចការជំនួញណាមួយរបស់ពាណិជ្ជករដែលមានគោលបំណងយកចំណេញ ត្រូវបានតាក់តែងឡើង ដោយចែងខុសពីបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដោយសារមានមូលហេតុសមហេតុសមផលតាមសេដ្ឋកិច្ច ទោះបីជាមានបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏បញ្ញត្តិនៃច្បាប់ពិសេសនោះ ត្រូវយកមកអនុវត្តចំពោះកិច្ចការជំនួញនោះ (ច្បាប់ពិសេសមានអាទិភាពលើច្បាប់ទូទៅ) ។

## មាត្រា ២.- គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

(កំណត់)

មាត្រានេះបញ្ជាក់ថា ក្រមរដ្ឋប្បវេណីមានគោលបំណងសម្រេចឱ្យបាននូវសិទ្ធិឯកជនរបស់បុគ្គលនីមួយៗ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

## មាត្រា ៣.- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

(កំណត់)

សង្គមស៊ីវិល ផ្អែកលើសេដ្ឋកិច្ចទីផ្សារដែលប្រកបដោយការជួញដូរទំនិញ ។ ដើម្បីជួញដូរទំនិញឱ្យបានរលូន ប្រធាននៃការជួញដូរនីមួយៗនោះ គួរតែអាចធ្វើការជួញដូរបាន ដោយផ្អែកលើឆន្ទៈសេរីរបស់ខ្លួន ។ នៅក្នុងសង្គមស៊ីវិល បុគ្គលគ្រប់រូប មានសេរីភាព និង សមភាព ហេតុដូច្នេះ បុគ្គលម្នាក់មិនត្រូវបានចងដោយឆន្ទៈរបស់បុគ្គលដទៃទេ លើកលែងតែខ្លួនព្រមព្រៀងក្នុងការជួញដូរ (កិច្ចសន្យា) ជាមួយបុគ្គលដទៃនោះ ដោយឆន្ទៈរបស់ខ្លួន ។ ការណ៍នេះត្រូវបានចែងជាគោលការណ៍មូលដ្ឋាននៅក្នុងក្រមរដ្ឋប្បវេណី ដូចជាសេរីភាពនៃលក្ខណៈបុគ្គលតាមច្បាប់ សេរីភាពក្នុងការប្រើប្រាស់អាស្រ័យផល និង ចាត់ចែងទ្រព្យ (កម្មសិទ្ធិ) និង សេរីភាពក្នុងការធ្វើកិច្ចសន្យា ។ នៅក្នុងទំនាក់ទំនងនៃការជួញដូរ នីតិបុគ្គលសាធារណៈ ក៏ត្រូវធ្វើកិច្ចសន្យា (ការជួញដូរ) ក្នុងឋានៈស្មើគ្នាជាមួយភាគីម្ខាងទៀត ។

## មាត្រា ៤.- ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបាន

## ជំពូកទី ៤
## ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

### មាត្រា ២៦.-សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១-កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌។

(កំណត់)

ដូចគ្នាទៅនឹងសេចក្តីពន្យល់ក្នុងកំណត់នៃមាត្រា ១៨។ បញ្ញត្តិនេះទំនងជាមិនមានបញ្ហាអ្វីទេ ប្រសិនបើក្រសួងយុត្តិធម៌ទទួលបន្ទុកចាត់ចែងកិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងអំឡុងពេលសមរម្យណាមួយ ពីព្រោះថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទំនងជាមិនត្រូវបានសុំចុះបញ្ជីញឹកញាប់ទេ។

### មាត្រា ២៧.-បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

ដូចគ្នាទៅនឹងសេចក្តីពន្យល់ក្នុងកំណត់នៃមាត្រា ១៩ ។

បញ្ញត្តិនេះត្រូវបានរៀបចំឡើងដោយយកបុរេល័ក្ខខ័ណ្ឌថា ក្នុងករណីដែលមានអចលនវត្ថុក្នុងចំណោមកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ភាគីនៃកិច្ចសន្យាមិនអាចតតាំងខ្លឹមសារនៃកិច្ចសន្យានោះចំពោះតតិយជនបានទេ ប្រសិនបើមិនបានចុះបញ្ជីចំពោះអចលនវត្ថុនីមួយៗ។

### មាត្រា ២៨.-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយលក្ខណ៍អក្សរដោយប្តីប្រពន្ធ ឬ ដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍។

រលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយសារលទ្ធផលនៃការលែងលះគ្នា និង ដោយសារការប្រកាសអំពីការបាត់ខ្លួន គឺការរលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយសារការបាត់ខ្លួន ពុំមានការបាត់បង់សិទ្ធិសន្តតិកម្មទេ ។

ចំណុចដែលត្រូវប្រយ័ត្ន គឺការចាត់ទុកថាបានទទួលមរណភាព គឺពាក់ព័ន្ធតែនឹងទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលបាត់ខ្លួនប៉ុណ្ណោះ រីឯសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលដែលបាត់ខ្លួន តាមធម្មតា មិនបាត់បង់ ដោយសារការប្រកាសនេះទេ ។ ហេតុនេះហើយ ក្នុងករណីដែលអ្នកបាត់ខ្លួននៅរស់ ហើយមានទំនាក់ទំនងគតិយុត្តនៅកន្លែងផ្សេងទៀត គេអាចធ្វើលទ្ធកម្មនូវសិទ្ធិ និង កាតព្វកិច្ច ដោយផ្អែកលើទំនាក់ទំនងគតិយុត្តនោះបាន ។

ពេលដែលសាមីខ្លួនបានត្រឡប់មកលំនៅឋានដើមវិញ ហើយមានទំនាក់ទំនងគតិយុត្តក្រោយពីនោះ នឹងមានអានុភាព ទោះជាមិនបានលុបចោលនូវការប្រកាសអំពីការបាត់ខ្លួនក៏ដោយ ។ ដើម្បីឱ្យបានច្បាស់លាស់ថែមទៀតអំពីបញ្ហានេះ ក្នុងមាត្រានេះ មានចែងថា ត្រូវចាត់ទុកថាបានទទួលមរណភាព "ចំពោះតែទំនាក់ទំនងគតិយុត្ត...រហូតដល់ពេលនោះ" (៥ ឆ្នាំ ឬ ពេលគ្រោះថ្នាក់បានកន្លងផុត) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៩៨ (ក្រឹត្យច្បាប់លេខ ១៩៦ នស ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៥៧)

**មាត្រា ៤៤.– ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ**

១-ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថា ទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ ។

២-បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ។ ប៉ុន្តែ បុគ្គលដែលមិនបានដឹងថា ការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ។

៣-អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់

ខ្លួនឡើយ ។

៤-ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ ។

(កំណត់)

ក្រោយការប្រកាសអំពីការបាត់ខ្លួន ប្រសិនបើបញ្ជាក់ច្បាស់លាស់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ បុគ្គលនោះបានទទួលមរណភាពនៅពេលផ្សេងពីពេលដែលបានចាត់ទុកថាបានទទួលមរណភាពក្នុងការប្រកាសអំពីការបាត់ខ្លួននោះ តុលាការត្រូវលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ តាមការទាមទាររបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

ប្រសិនបើបានលុបចោលការប្រកាសនោះហើយ ជាគោលការណ៍ ត្រូវចាត់ទុកថា ពុំមានការប្រកាសអំពីការបាត់ខ្លួនតាំងពីដំបូងមក ។ ដូច្នេះ សន្តតិកម្មដែលបានចាប់ផ្តើមហើយនោះ ក៏មិនត្រូវចាប់ផ្តើមដែរ ឬ ប្រសិនបើបានទទួលប្រាក់ធានារ៉ាប់រងជីវិតរួចហើយ ក៏ត្រូវសងប្រាក់នោះទៅក្រុមហ៊ុនធានារ៉ាប់រងវិញដែរ (វាក្យខណ្ឌទី ១ កថាខណ្ឌទី ២ នៃមាត្រានេះ) ។

ក៏ប៉ុន្តែ ធ្វើដូច្នោះទៅ បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយអនុប្បទានពីសន្តតិជន ដោយផ្អែកលើការប្រកាសអំពីការបាត់ខ្លួននោះ ត្រូវសាមីខ្លួនយកទ្រព្យសម្បត្តិវិញ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ពេលក្រោយនោះ បុគ្គលនោះអាចរងនូវការខូចខាតបាន ។ ម្យ៉ាងទៀត ចំពោះបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការប្រកាសអំពីការបាត់ខ្លួននោះ ក្រោយពីបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកដោយសន្តតិកម្មនោះ ប្រសិនបើទាមទារឱ្យបុគ្គលនោះសងទាំងភាគដែលខ្លួនបានប្រើប្រាស់អស់ទៅហើយនោះ គឺអាចមានបញ្ហាធ្ងន់ធ្ងរបានចំពោះបុគ្គលនោះ ។ ដូច្នេះហើយ បានជានៅក្នុងមាត្រានេះ ពីកថាខណ្ឌទី ២ ទៅ មានបញ្ញត្តិសម្រាប់សម្របសម្រួលផលប្រយោជន៍ក្នុងករណីទាំងនេះ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់សង្គ្រោះបុគ្គលដែលបានធ្វើលទ្ធកម្មផ្ទាល់ដោយសុចរិត ដោយចែងថា ក្នុងករណីដែលបុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយផ្ទាល់ពីបុគ្គលដែលបាត់ខ្លួន ដោយអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ដូចជាសន្តតិជន អ្នកដែលទទួលប្រាក់ធានារ៉ាប់រងជីវិត ជាអាទិ៍ មិនបានដឹងថា ការប្រកាសអំពីការបាត់ខ្លួននោះ ខុសពីការពិត នៅពេលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិ បុគ្គលនោះគ្រាន់តែសងត្រឹមតែទ្រព្យសម្បត្តិដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ជាការគ្រប់គ្រាន់ ។ ការសង "ត្រឹមតែទ្រព្យសម្បត្តិដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ" មានន័យថា ក្នុងករណីដែលទ្រព្យសម្បត្តិដែលបានទទួលនោះនៅសល់ ត្រូវសងត្រឹមតែភាគដែលសល់នោះបានហើយ តែក្នុងករណីដែលបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានទទួលនោះអស់ហើយ ត្រូវសងត្រឹមតែ

ភាគដែលបានប្រើសម្រាប់ជីវភាព ដោយគិតថា ភាគដែលខ្លួនបានជៀសវាងចំណាយទ្រព្យរបស់ខ្លួន ដោយសារយកទ្រព្យសម្បត្តិដែលខ្លួនបានទទួលមកចំណាយជំនួស ជាភាគដែលខ្លួននៅតែទទួលផលប្រយោជន៍ ។ ក៏ប៉ុន្តែ សិទ្ធិទាមទារឱ្យសងនៃករណីនេះ មានលក្ខណៈជាការទាមទារឱ្យសងនូវទ្រព្យដែលបានមកពីសេចក្ដីចម្រើនដោយឥតហេតុ ដូច្នេះហើយ ក្នុងករណីដែលបុគ្គលដែលបាត់ខ្លួននោះ ត្រូវទទួលបន្ទុកផ្ដល់អាហារកាតព្វកិច្ច ឬ ទទួលបន្ទុកនូវចំណាយសម្រាប់ជីវភាពរស់នៅ ចំពោះបុគ្គលដែលបានទទួលទ្រព្យសម្បត្តិនោះ មិនអាចចាត់ទុកថា បុគ្គលនោះបានទទួលដោយពុំមាន "មូលហេតុលើផ្លូវច្បាប់" ទេ (មាត្រា ៧៣៦ កថាខណ្ឌទី ១) ដូច្នេះ ប្រសិនបើបានចំណាយសម្រាប់ជីវភាពរស់នៅ មិនចាំបាច់សងវិញទេ ។

យោងតាមកថាខណ្ឌទី ៣ ក្រោយពេលប្រកាសអំពីការបាត់ខ្លួន ហើយមុនពេលប្រកាសលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ប្រសិនបើបុគ្គលដែលបានទិញដីធ្លីពីសន្តតិជន ដោយសុចរិត (មិនបានដឹងថា ការប្រកាសអំពីការបាត់ខ្លួននោះ ខុសនឹងការពិត) អ្នកទិញមិនចាំបាច់សងដីនោះទៅបុគ្គលដែលបាត់ខ្លួននោះវិញទេ ។

បញ្ហារបស់តតិយជនដែលមានវត្តមានក្រោយពេលលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន តែមុនពេលលុបចោលនូវការចុះបញ្ជី គឺជាបញ្ហាដែលមានក្រៅកម្មវត្ថុនៃមាត្រា ៤៤ កថាខណ្ឌទី ៣ នេះ ដូច្នេះហើយ ត្រូវដោះស្រាយតាមលក្ខណៈទូទៅ ចំពោះករណីដែលបុគ្គលដែលបានធ្វើកិច្ចការជំនួញនឹងបុគ្គលដែលបានចុះបញ្ជីកម្មសិទ្ធិដោយគ្មានសិទ្ធិ ។

កថាខណ្ឌទី ៤ មានចែងថា ក្នុងករណីដែលបានលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ក្រោយអាពាហ៍ពិពាហ៍ម្ដងទៀតរបស់សហព័ទ្ធ មានតែអាពាហ៍ពិពាហ៍ក្រោយនេះទេ ដែលមានសុពលភាព (ទោះជាភាគីសុចរិតក៏ដោយទុច្ចរិតក៏ដោយ) ហើយមិនទទួលស្គាល់អាពាហ៍ពិពាហ៍មុនវិញទេ ។ ទោះជាអាពាហ៍ពិពាហ៍ក្រោយ ត្រូវបានធ្វើឡើងដោយឆន្ទៈទុច្ចរិតរបស់ភាគីទាំងសងខាង ឬ ដោយភាគីណាម្ខាងក៏ដោយ ក្រោយមកទៀត ទោះជាបុគ្គលដែលបាត់ខ្លួននោះ ត្រឡប់មកវិញក៏ដោយ បើភាគីដែលរៀបអាពាហ៍ពិពាហ៍ក្រោយ មានបំណងចង់បន្តអាពាហ៍ពិពាហ៍នោះ ត្រូវគោរពឆន្ទៈរបស់ភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍នោះ ហេតុនេះហើយ ដោយផ្អែកលើគំនិតនេះ ត្រូវតែទទួលស្គាល់អាពាហ៍ពិពាហ៍នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣២

## ផ្នែកទី ៧ ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

**មាត្រា ៤៥.–** ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាព

## មាត្រា ២០២.– និយមន័យនៃកម្មសិទ្ធិអវិភាគ

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ។

(កំណត់)

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិព្រមគ្នាលើវត្ថុតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ហើយផ្នែកនេះចែងអំពីកម្មសិទ្ធិអវិភាគនេះ ។ បុគ្គលទាំងអស់ដែលមានកម្មសិទ្ធិអវិភាគត្រូវមានកម្មសិទ្ធិមួយចំពោះវត្ថុនោះ ដោយមានការកម្រិតនូវភាគចំណែកដែលកំណត់ទៅតាមចំនួន ។ ក្នុងករណីដែលមានការធ្វើសន្តតិកម្មដីធ្លីដែលជាកម្មសិទ្ធិរបស់មតកជនទៅសហព័ទ្ធ និង កូន នោះសហព័ទ្ធ និង កូនទាំងនោះនឹងក្លាយជាអ្នកមានកម្មសិទ្ធិអវិភាគលើដីនោះ ។ រីឯស្តីពីកិច្ចសន្យាក្រុមហ៊ុនវិញ (ពីមាត្រា ៦៩៩ ទៅ) សមាជិកក្រុមហ៊ុន មានកម្មសិទ្ធិអវិភាគលើទ្រព្យសម្បត្តិក្រុមហ៊ុននោះ (មាត្រា ៧០១ កថាខណ្ឌទី ១) ហើយសមាជិកក្រុមហ៊ុនមិនអាចទាមទារឱ្យបែងចែកកម្មសិទ្ធិអវិភាគនេះបានឡើយ នៅពេលដែលក្រុមហ៊ុននោះនៅមានអត្ថិភាព (មាត្រា ៧០១ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត សមាជិកក្រុមហ៊ុន មិនអាចធ្វើអនុប្បទានភាគរបស់ខ្លួនទៅឱ្យអ្នកដទៃបានឡើយ (មាត្រា ៧០១ កថាខណ្ឌទី ៤) ។ តាមទ្រឹស្តីនីតិសាស្ត្រ គេបកស្រាយថា នេះជាកម្មសិទ្ធិអវិភាគដែលមិនអាចចាត់ចែងភាគចំណែកបាន ហើយដែលមានលក្ខណៈខុសពីកម្មសិទ្ធិអវិភាគដែលមានចែងក្នុងផ្នែកនេះ (សូមមើលមាត្រា ២១១ និង មាត្រា ២០៤) ។ ម្យ៉ាងទៀត ករណីដែលមានជនច្រើននាក់មានកម្មសិទ្ធិទៅលើវត្ថុតែមួយ ប៉ុន្តែ តាមការជាក់ស្តែង ការគ្រប់គ្រង ព្រមទាំងសិទ្ធិចាត់ចែងវត្ថុនោះ ត្រូវបានប្រគល់ទៅលើអង្គភាពដែលត្រូវបានបង្កើតដោយម្ចាស់កម្មសិទ្ធិអវិភាគនោះទៅវិញ ហើយបដិសេធនូវចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគ ឬ ក៏ចំណែកទាំងនោះ គឺជាកម្មសិទ្ធិអវិភាគសក្តានុពល ក៏ខុសគ្នានឹងកម្មសិទ្ធិអវិភាគដែលមានចែងក្នុងផ្នែកនេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤១ និង មាត្រា ១០០៨

## មាត្រា ២០៣.– សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ

ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថា ស្មើគ្នា ។

(កំណត់)

នេះគឺជាបញ្ញត្តិសន្មត ក្នុងករណីដែលពុំមានការកំណត់លំអិតអំពីចំណែកនៃកម្មសិទ្ធិអវិភាគ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៦, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៩ វាក្យខណ្ឌទី ១, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥០, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤២

**មាត្រា ៥១៩.–** លំដាប់នៃឧបាទេសកម្ម

១-អ្នកធានាមិនអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាវត្ថុប្រាតិភោគបានឡើយ ប្រសិនបើខ្លួនមិនបានចុះបញ្ជីក្រោយពីបានសង ឬ ចេញចំណាយផ្សេងទៀត ។

២-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងដោយឧបាទេសកម្មដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។

(កំណត់)

ចំពោះសិទ្ធិប្រាតិភោគប្រឆាំងលើអចលនវត្ថុ ចាំបាច់ចុះបញ្ជីអំពីឧបាទេសកម្ម (កថាខណ្ឌទី ១) ។ ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មមុនពេលសង ជាអាទិ៍ អ្នកធានាអាចធ្វើឧបាទេសកម្មដោយមិនបានចុះបញ្ជីបាន ក៏ប៉ុន្តែ ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មក្រោយការសង ជាអាទិ៍ អ្នកធានាមិនអាចធ្វើឧបាទេសកម្មបានទេ ប្រសិនបើមិនបានចុះបញ្ជីអំពីឧបាទេសកម្មនោះ មុនពេលតតិយជននេះធ្វើលទ្ធកម្ម ។

ទំនាក់ទំនងនៃឧបាទេសកម្មរវាងអ្នកធានា និង អ្នកធានាដោយវត្ថុ គឺស្មើភាពគ្នា (កថាខណ្ឌទី ២) ។ ក្នុងករណីដែលអ្នកធានា ក៏ជាអ្នកធានាដោយវត្ថុដែរ របៀបរាប់អ្នកនោះជាបញ្ហាមួយ ។ ក៏ប៉ុន្តែ ដើម្បីឱ្យស្រួលចាត់ចែង និង ដើម្បីឱ្យមានសមភាព គួររាប់តែម្នាក់ជាការល្អ ។ ចំណុចនេះ សូមភាគីកម្ពុជាបកស្រាយ ។

**មាត្រា ៥២០.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីឧបាទេសកម្មដោយការសង

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ឧបាទេសកម្ម) នេះ បញ្ញត្តិនៃកថាភាគទី ៤ (ឧបាទេសកម្មដោយការសង) ផ្នែកទី ១ ជំពូកទី ៧ នៃគន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្មដោយការសង ឬ ចេញចំណាយផ្សេងទៀតរបស់អ្នកធានា ។

(កំណត់)

ឧបាទេសកម្មរបស់អ្នកធានា គឺជាឧបាទេសកម្មដោយការសងមួយប្រភេទដែរ ហេតុដូច្នេះ មាត្រានេះបញ្ជាក់ឱ្យបានច្បាស់លាស់ថា ក្រៅពីបញ្ញត្តិនៃផ្នែកនេះ បញ្ញត្តិទូទៅស្តីពីឧបាទេសកម្មដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ជំពូកទី ៨ កាតព្វកិច្ចដោយសាមគ្គីភាព

### ផ្នែកទី ១ ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

**មាត្រា ៥២១.–** អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

១-ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឱ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចទាំងអស់ ឬ កូនបំណុលណាម្នាក់ ត្រូវបានប្រកាសក្ស័យធន ម្ចាស់បំណុលអាចចូលរួម ក្នុងការចែកចំណែកនៅក្នុងនីតិវិធីក្ស័យធនរបស់កូនបំណុលនីមួយៗ ចំពោះចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន ។

(កំណត់)

ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព កូនបំណុលម្នាក់ៗត្រូវទទួលបន្ទុកកាតព្វកិច្ចទាំងស្រុង ហើយវិធីទទួលបន្ទុក ក៏គ្មានភាពចម្បង ឬ បន្ទាប់បន្សំទេ (កថាខណ្ឌទី ១) ។

ម្យ៉ាងទៀត ចំពោះករណីក្ស័យធន ចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីចំណុចនេះ (កថាខណ្ឌទី ២) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៣២ និង មាត្រា ៤៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥២២.- ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព**

១-ក្រៅពីករណីដែលមានបញ្ញត្តិនៅក្នុងច្បាប់ កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ដោយជាក់លាក់ ឬ ដោយតុល្យភាព រវាងម្ចាស់បំណុល និង កូនបំណុលច្រើននាក់ដែលធានាសាមគ្គីភាពរួមគ្នាទៅវិញទៅមក ត្រូវបានទទួលស្គាល់ ។

២-ការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើឡើងរវាងម្ចាស់បំណុល និង កូនបំណុលនីមួយៗ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

៣-ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយបាន ។[៥]

៤-ក្រោយពេលលើកលែងសាមគ្គីភាព កូនបំណុលដែលបានទទួលការលើកលែង ត្រូវទទួលបន្ទុកនូវកាតព្វកិច្ច ត្រឹមតែចំនួនប្រាក់ដែលស្មើនឹងបន្ទុកដែលខ្លួនធ្លាប់មានមុនពេលលើកលែង ។

---

[៥] កថាខណ្ឌទី ៣ នៃមាត្រា ៥២២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ជាឧទាហរណ៍ ការរៀបអាពាហ៍ពិពាហ៍បែបនេះ នឹងបង្កឱ្យមានការរង្គោះរង្គើខាងផ្លូវភេទ ក្នុងចំណោមញាតិផ្ទាល់ជិតទាំងនោះ ហើយពីទិដ្ឋភាពនៃការចូលរួមក្នុងសង្គម និង បរិយាកាសនៃការចិញ្ចឹមបីបាច់កូន ក៏មិនមែនជាការគួរឱ្យប្រាថ្នា ហើយក៏នឹងបណ្ដាលឱ្យមានផលប៉ះពាល់ដល់ភាពសុខសាន្តក្នុងគ្រួសារដែរ ។ ជាការពិតណាស់ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម និង កូនសុំក៏ត្រូវបានហាមឃាត់ផងដែរ ។

ទោះបីជាទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្ដាយបង្កើតត្រូវបានកាត់ផ្ដាច់ដោយសារការបង្កើតសុំកូនពេញលេញក៏ដោយ ក៏ទំនាក់ទំនងលោហិតតាមធម្មជាតិមិនរលត់ដែរ ហេតុនេះបានជាការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិផ្ទាល់ជិតនៅតែមានដដែល ។ ដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះបានបញ្ញត្តថា អាពាហ៍ពិពាហ៍រវាងបុគ្គលដែលធ្លាប់មានទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ឬ សាខាញាតិលោហិតក្នុងថ្នាក់ទី ៣ នៅមុនពេលបង្កើតសុំកូនពេញលេញ និង កូនសុំ ត្រូវបានហាមឃាត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៥២.- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

១-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយបញ្ញត្តិមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬ មាត្រា ១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមនេះ ។

២-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ តាមបញ្ញត្តិនៃមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ខាងលើនេះ ។ ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់បាន ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ និង រវាងជនដែលធ្លាប់ជាញាតិពន្ធនៃខ្សែផ្ទាល់ ។ ដោយសារញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធមានទំនាក់ទំនងប្រហាក់ប្រហែលនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្ដាយ និង កូន ដូច្នេះ តាមសីលធម៌សង្គម

ក៏អាពាហ៍ពិពាហ៍បែបនេះមិនមែនជាការគួរដែរ ។

ម្យ៉ាងវិញទៀត កថាខណ្ឌទី ២ ចែងថា ទោះបីជាសាខាញាតិពន្ធក្នុង ៣ ថ្នាក់ ដោយរាប់ទាំងថ្នាក់ទីបីផងក៏ដោយ ក៏អាពាហ៍ពិពាហ៍រវាងបុគ្គលទាំងនោះត្រូវបានហាមឃាត់ដែរ ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនេះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិតស្និទ្ធស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និង សាខាញាតិលោហិតដែរ ។ ក៏ប៉ុន្តែ ដោយសារតែតាមទំនៀមទម្លាប់ក្នុងប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍ជាមួយបងប្អូនថ្លៃ ដូចជាករណីដែលប្ដីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែលនៅលីវរបស់សពប្ដី ឬ ករណីដែលប្រពន្ធបានទទួលមរណភាព ហើយប្អូនស្រី ឬ បងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី ដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពនោះ ជាដើម ហើយម្យ៉ាងវិញទៀត ការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនបង្កើតរបស់ប្ដី និង បងប្អូនបង្កើតរបស់ប្រពន្ធ ក៏ឃើញមានផងដែរនោះ ទើបវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ត្រូវបានបញ្ញត្តឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៦១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៧៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៥៣.- ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

១-ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បើអ្នកដែលមានអំណាចមេបាណាម្នាក់មិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់ហើយ ។

៣-ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន ។

(កំណត់)

សិទ្ធិផ្ដល់ការយល់ព្រមរបស់ឪពុកម្ដាយចំពោះកូនដែលជាអនីតិជន គឺជាការយល់ព្រមដែលមានលក្ខណៈជាការគ្រប់គ្រងថែរក្សា ដើម្បីបង្គ្រប់ភាពខ្វះខាតខាងការវិនិច្ឆ័យរបស់អនីតិជននោះ ។ ដោយសារគោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបារួម ចាំបាច់មានការយល់ព្រមពីឪពុកម្ដាយទាំងពីរ ។ ក៏ប៉ុន្តែ ប្រសិនបើឪពុក ឬ ម្ដាយណាម្នាក់

អាពាហ៍ពិពាហ៍ រួមមានផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ ដូចជាលំនៅ ថ្លៃចំណាយលើម្ហូបអាហារ និង ការកំសាន្ត ជាដើម ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២០១ និង មាត្រា ២០២ នៃក្រមរដ្ឋប្បវេណីបារាំង ។

## ផ្នែកទី ២ អានុភាពនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៦៥.-** នាមត្រកូលរបស់ប្តី ប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ។

( កំណត់)

មាត្រានេះចែងថា ប្តីប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្តី ឬ ប្រពន្ធក៏បាន ឬ នាមត្រកូលរៀងៗខ្លួនដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន ។ មាត្រានេះគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និង សិទ្ធិបុគ្គល និង ធានារបបដែលប្តីប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលខុសគ្នា ។ ជាគោលការណ៍ ប្តីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យតំណខ្សែឈាមហិត និង ឫសគល់នៃឪពុកម្តាយ និង ដូនតា ហើយដោយសារតែវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូបជាមួយនឹងនាមខ្លួន ទើបយើងសម្រេចយកយន្តការដែលជនគ្រប់រូបអាចជ្រើសរើសដោយសេរីនូវនាមត្រកូល បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ។ នៅប្រទេសកម្ពុជា កូនកើតមក តាមទំនៀមទម្លាប់ គឺដាក់ឈ្មោះតាមឪពុក ជីតា ឬ បុព្វជនដែលចាស់ជាងនេះទៀត ក៏ប៉ុន្តែ ការអនុវត្តយកនាមត្រកូលគ្រួសារពុំច្បាស់លាស់ទេ ។ ប៉ុន្តែ រាជវង្ស និង ជនដែលមានតំណែងខ្ពង់ខ្ពស់ក្នុងសង្គមមានត្រកូល ហើយលក្ខណៈ និង និយមន័យនៃនាមត្រកូល មានភាពស្មុគស្មាញគួរសម ។ ទោះជាដូច្នេះក្តី ផ្នែកដំបូងនៃឈ្មោះហាក់ដូចជាត្រូវបានចាត់ទុកថាជានាមត្រកូល ឬ ត្រកូល ហើយនៅពេលចុះបញ្ជី ក៏ចាំបាច់ត្រូវធ្វើការបែងចែកនាមត្រកូល និង នាមខ្លួន ហើយដោយផ្អែកលើលទ្ធផលនៃការស្ទង់មតិយោបល់ដែលថា ការទទួលស្គាល់ការជ្រើសរើសឈ្មោះរបស់ប្តីប្រពន្ធជាការសមរម្យ ទើបយើងសម្រេចថា ការប្រើនាមត្រកូលរួម ឬ នាមត្រកូលដោយឡែកក៏មិនមានបញ្ហាអ្វីដែរ ។

( មាត្រាពាក់ព័ន្ធ)

គម្រោងវិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៦៦.-** ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក ។

(កំណត់)

អាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ និង សេដ្ឋកិច្ច នៃប្តីប្រពន្ធ ដូច្នេះ មាត្រានេះប្រកាសថា ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយសហការ និង សង្គ្រោះគ្នាទៅវិញទៅមក ។ មាត្រា ២៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាគាំទ្រថា ប្តីប្រពន្ធត្រូវមានភាពស្មើភាពគ្នាលើគ្រប់ទស្សនៈ ហើយមាត្រា ៣០ ចែងថា ប្តីប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយ មានសាមគ្គីភាព និង ប្រកបដោយសុភមង្គល ។ មាត្រានេះកំណត់យ៉ាងច្បាស់ថា ប្តីប្រពន្ធដែលជាបុគ្គលឯករាជ្យ និង ស្មើភាពគ្នា ត្រូវមានករណីយកិច្ចសហការគ្នា ដើម្បីថែរក្សាជីវភាពអាពាហ៍ពិពាហ៍រួម ហើយទន្ទឹមគ្នានេះ ដើម្បីឆ្លើយតបទៅនឹងករណីយកិច្ចនេះ គឺពួកគេមានសិទ្ធិស្មើៗគ្នា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៧៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៩០ នៃក្រមរដ្ឋប្បវេណីទូទៅរបស់ប្រទេសអូទ្រីស

**មាត្រា ៩៦៧.- សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម**

ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន ។

(កំណត់)

ដើម្បីសម្រេចឱ្យបានជាក់ស្តែងនូវភាពស្មើគ្នា មាត្រា ៣១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា ទទួលស្គាល់ឱ្យប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។ មាត្រានេះក៏ទទួលយកបន្តនូវស្មារតីនោះ ដោយគោរពនូវសិទ្ធិបុគ្គលចំពោះសេរីភាពក្នុងការជ្រើសរើសការចូលរួមក្នុងវិជ្ជាជីវៈក្នុងនាមជាដៃគូជាមួយភាគីម្ខាងទៀត សិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៩១ នៃក្រមរដ្ឋប្បវេណីទូទៅរបស់ប្រទេសអូទ្រីស

**មាត្រា ៩៦៨.- ការចាត់ទុកជានីតិជន ដោយអាពាហ៍ពិពាហ៍**

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថា បាន

ដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ ។

(កំណត់)

មាត្រានេះចែងថា អនីតិជនត្រូវបានចាត់ទុកថាបានដល់នីតិភាព នៅពេលដែលបានរៀបអាពាហ៍ពិពាហ៍ ។ មាត្រា ១៦ ឡើងទៅ នៃផ្នែកទី ៤ នៃគន្ថីស្តីពីបុគ្គលនៃក្រមរដ្ឋប្បវេណីនេះ ចែងអំពីបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងសមត្ថភាពក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ឯកជន ក៏ប៉ុន្តែ មាត្រានេះបញ្ជាក់ច្បាស់ថា អនីតិជនដែលចាត់ទុកថាជានីតិជន អាចមិនត្រឹមតែទទួលបានសមត្ថភាពក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ទាក់ទងនឹងទ្រព្យសម្បត្តិនោះទេ តែថែមទាំងអាចធ្វើសកម្មភាពឋានៈបុគ្គល ក៏ដូចជាសកម្មភាពក្នុងជីវភាពអាពាហ៍ពិពាហ៍ផ្សេងទៀត ដោយឯករាជ្យ ដោយមិនចាំបាច់មានអន្តរាគមន៍ពីឪពុកម្តាយ ជាដើម ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៤៧៦ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ២ មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសស្វីស

## ផ្នែកទី ៣ ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

## កថាភាគទី ១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**មាត្រា ៩៦៩.-** កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ ។

២-បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

(កំណត់)

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរបស់ប្តីប្រពន្ធ ។ ទំនាក់ទំនងជាក់ស្តែងរវាងប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយបញ្ញត្តិនេះផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាម

ភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់ ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ ។ ក្រមរដ្ឋប្បវេណីជប៉ុនក៏មានបញ្ញត្តិអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាប់ពីមាត្រា ៧៥៥ ដល់មាត្រា ៧៥៩ ផងដែរ ។

មានបញ្ហាថា តើគួរទទួលស្គាល់នូវសេរីភាពក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រឹមកម្រិតណា ។ មានន័យថា ផ្តើមចេញពីការពិចារណាលើភាពខុសគ្នានៃសមត្ថភាពចរចា និង ទំនាក់ទំនងអំណាចរវាងប្តីប្រពន្ធ តើត្រូវធានាភាពយុត្តិធម៌ក្នុងខ្លឹមសារនៃកិច្ចសន្យាយ៉ាងដូចម្តេច ហើយថា តើត្រូវទទួលស្គាល់អានុភាពនៃកិច្ចសន្យានោះត្រឹមកម្រិតណា ចំពោះទំនាក់ទំនងនៃសុវត្ថិភាពនៃការជួញដូរ និង ទំនាក់ទំនងជាមួយតតិយជន ។ នៅប្រទេសជប៉ុនជាគោលការណ៍ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដោយសេរី លុះត្រាតែកិច្ចសន្យានោះមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ឬ បញ្ញត្តិដែលត្រូវអនុវត្តដាច់ខាត ។ នៅប្រទេសបារាំង ខណៈដែលគូភាគីមានសិទ្ធិកំណត់ដោយសេរីនូវខ្លឹមសារនៃកិច្ចសន្យាស្តីពីប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ក៏ប៉ុន្តែ ដើម្បីភាពងាយស្រួលរបស់ភាគី ទម្រង់កិច្ចសន្យាគំរូដែលភាគីអាចជ្រើសរើសប្រើបានត្រូវបានកំណត់ឡើង ដូចជាទម្រង់កិច្ចសន្យាគំរូចំពោះប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធបញ្ចូលប្រាក់ចំណូលទៅក្នុងទ្រព្យសម្បត្តិរួម និង ប្រព័ន្ធកម្មសិទ្ធិរួមដែលកំណត់ដោយច្បាប់ដែលមានការកែប្រែខ្លះៗ ជាអាទិ៍ ។ ប្រទេសស្វ៊ីស អាល្លឺម៉ង់ និង អ៊ីតាលី ធ្វើការកម្រិតចំពោះទម្រង់កិច្ចសន្យាគំរូដែលអាចជ្រើសរើសបានក្នុងចំណោមប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធទ្រព្យសម្បត្តិរួម និង ប្រព័ន្ធដែលកែសម្រួលចំណុចខ្លះនៃប្រព័ន្ធទ្រព្យសម្បត្តិរួម ។

ចំពោះខ្លឹមសារវិញ ច្បាប់ប្រទេសបារាំង និង រដ្ឋល្វីស៊ីយ៉ាណា (Louisiana) របស់សហរដ្ឋអាមេរិក ចែងថាកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ និង ករណីយកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍ អំណាចមេបា អាណាព្យាបាល និង ការហាមឃាត់ការផ្លាស់ប្តូរលំដាប់នៃសន្តតិកម្មដែលកំណត់ដោយច្បាប់ឡើយ រីឯប្រទេសស្វ៊ីស ក៏ធ្វើការហាមឃាត់ការពាក់តែងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបំពានលើបញ្ញត្តិដែលពាក់ព័ន្ធនឹងការការពារម្ចាស់បំណុល និង ភាគបម្រុងដែរ ។ ប្រទេសជាច្រើនមិនទទួលស្គាល់កិច្ចសន្យាណាដែលលះបង់ ឬ កម្រិតសិទ្ធិជាមូលដ្ឋាន ដូចជាការថែរក្សាជីវភាពគ្រួសារ ភាពស្មើគ្នា និង ឯករាជ្យភាពរបស់ប្តីប្រពន្ធ ជាដើម ។ ដូច្នេះ មាត្រានេះក៏ទទួលស្គាល់សេរីភាពរបស់ប្តីប្រពន្ធ ក្នុងការធ្វើកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ប៉ុន្តែ ទន្ទឹមគ្នានេះ ដាក់កម្រិតមួយចំនួនលើសេរីភាពក្នុងការធ្វើកិច្ចសន្យា ដូចជាការលះបង់សិទ្ធិលើអាហារកាតព្វកិច្ច សិទ្ធិលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ និង ការលះបង់សិទ្ធិពាក់ព័ន្ធនឹងសន្តតិកម្មដូចជាភាគបម្រុងដែលកំណត់ដោយច្បាប់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៨៧ ដល់មាត្រា ១៣៩៤ ជាអាទិ៍ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៨ ដល់មាត្រា ១៨១ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសស្វ៊ីស, មាត្រា ៧៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៧១.- ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

(កំណត់)

មាត្រានេះចែងអំពីបន្ទុកនៃសោហ៊ុយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្ដីប្រពន្ធចែករំលែកសោហ៊ុយទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និង មុខរបរ ជាដើម របស់ប្ដីប្រពន្ធ ។ សោហ៊ុយអាពាហ៍ពិពាហ៍ទាំងនោះ មិនសំដៅលើត្រឹមតែសោហ៊ុយចាំបាច់ដែលចំណាយលើការស្លៀកពាក់ ម្ហូបអាហារ និង ការស្នាក់នៅប៉ុណ្ណោះទេ តែរាប់បញ្ចូលទាំងសោហ៊ុយលើថ្លៃព្យាបាល ការសិក្សា និង ថែទាំកូនផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៦០ មាត្រា ១៣៦០a មាត្រា ១៣៦០b និង មាត្រា ១៣៦១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់. មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៧២.- ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

(កំណត់)

មាត្រានេះកំណត់អំពីវិសាលភាពនៃទ្រព្យសម្បត្តិដោយឡែក ។ ទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត និងត្រូវរាប់ជាទ្រព្យសម្បត្តិដោយឡែក ។ នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា តើជាទ្រព្យដោយឡែក (ទ្រព្យសម្បត្តិ

ផ្ទាល់ខ្លួនបុគ្គល) ឬ ជាទ្រព្យរួម ហើយក៏ក្លាយទៅជាវិវាទ ។ ដូច្នេះ វាជាការល្អក្នុងការធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ដើម្បីបញ្ជាក់ឱ្យច្បាស់ជាមុនថា តើទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិរួម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៧៣.- ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាង ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុង ចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

(កំណត់)

នៅប្រទេសកម្ពុជា ប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានអនុម័តជាគោលការណ៍ ហើយមាត្រានេះបញ្ញត្តអំពីនិយមន័យនៃទ្រព្យសម្បត្តិរួម ។ ទ្រព្យសម្បត្តិរួម គឺទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែក ។ មាត្រា ១៤០២ នៃក្រមរដ្ឋប្បវេណីបារាំងចែងថា ទ្រព្យទាំងអស់ដែលជាចលនវត្ថុ ឬ អចលនវត្ថុត្រូវចាត់ទុកជាទ្រព្យដែលទទួលបានក្រោយអាពាហ៍ពិពាហ៍ដែលត្រូវស្ថិតនៅក្នុងចំណោមទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ ហើយសហព័ទ្ធដែលអះអាងថាជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ ។ មាត្រា ៨០៣ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ាចែងថា ទ្រព្យសម្បត្តិត្រូវសន្មតជាទ្រព្យសម្បត្តិរួម ឬ ទ្រព្យសម្បត្តិដោយឡែក អាស្រ័យលើឈ្មោះរបស់ម្ចាស់កម្មសិទ្ធិនៅពេលដែលធ្វើលទ្ធកម្មនូវទ្រព្យនោះ ហើយបុគ្គលដែលតវ៉ាត្រូវធ្វើការបញ្ជាក់ផ្ទុយពីនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា. មាត្រា ១៤០២ នៃក្រមរដ្ឋប្បវេណីបារាំង. មាត្រា ៧៦០ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា

## មាត្រា ៩៧៤.- ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្ដីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

(កំណត់)

ដោយយោងតាមករណីប្រទេសបារាំង អេស្ប៉ាញ និង រដ្ឋចំនួន ៩ របស់សហរដ្ឋអាមេរិកដែលអនុម័តប្រព័ន្ធទ្រព្យសម្បត្តិរួម និង ស្របតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់កម្ពុជា មាត្រានេះចែងអំពីបញ្ញត្តិពិសេសទាក់ទងនឹងការគ្រប់គ្រង និង ប្រើប្រាស់នូវទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក ក្រៅពីបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ ក្នុងផ្នែកទី ៥ "កម្មសិទ្ធិអវិភាគ" ជំពូកទី ២ "កម្មសិទ្ធិ" គន្ថីទី ៣ "សិទ្ធិប្រត្យក្ស" ។ មានន័យថា កថាខណ្ឌទី ២ នៃមាត្រានេះបញ្ញត្តថា ប្តីប្រពន្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម ក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព (ចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ) ។ ម្យ៉ាងទៀត កថាខណ្ឌទី ៣ អនុម័តយកគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា ដោយតម្រូវឱ្យប្តីប្រពន្ធគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា និង ចែងថា សហព័ទ្ធម្ខាងមានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀតធ្វើចំណាត់ការដែលចាំបាច់សម្រាប់ថែរក្សាទ្រព្យសម្បត្តិរួម ។ ជាឧទាហរណ៍ ក្នុងករណីដែលអចលនវត្ថុដែលជាទ្រព្យសម្បត្តិរួម ត្រូវបានចុះបញ្ជីក្រោមឈ្មោះសហព័ទ្ធម្ខាង សហព័ទ្ធម្ខាងទៀតអាចទាមទារសហព័ទ្ធនោះដែលត្រូវបានចុះបញ្ជីថាជាម្ចាស់កម្មសិទ្ធិ ឱ្យសហការចុះបញ្ជីអចលនវត្ថុនោះជាកម្មសិទ្ធិអវិភាគបាន ។ កថាខណ្ឌទី ៤ ចែងថា ប្រសិនបើប្តីប្រពន្ធ មិនអាចព្រមព្រៀងយោបល់គ្នាអំពីការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួម ភាគីម្ខាងណាមួយអាចទាមទារទៅតុលាការ 'ឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ដើម្បីដោះស្រាយវិវាទលើការគ្រប់គ្រងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ ។

ជាព័ត៌មាន កថាខណ្ឌទី ១ មាត្រា ១៤២១ នៃក្រមរដ្ឋប្បវេណីបារាំង អនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមជាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ក៏ប៉ុន្តែ ទោះបីជាទ្រព្យសម្បត្តិរួមក៏ដោយ ជាគោលការណ៍ ប្តីប្រពន្ធនីមួយៗមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងមូលដោយឯករាជ្យ ដោយមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតទេ ។ ប៉ុន្តែចំពោះទីស្នាក់នៅសម្រាប់គ្រួសារ (គេហដ្ឋានគ្រួសារ) ក្រមរដ្ឋប្បវេណីបារាំងតម្រូវឱ្យមានការគ្រប់គ្រងរួមគ្នា ដោយផ្អែកលើការព្រមព្រៀងទៅវិញទៅមករបស់ប្តីប្រពន្ធ ដើម្បីការពារផលប្រយោជន៍រួមរបស់គ្រួសារ ។ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានធ្វើកិច្ចសន្យាខ្ចី ឬ ធានា ប្រសិនបើមិនមានការយល់ព្រមជាក់លាក់ពីសហព័ទ្ធម្ខាងទៀតទេ ទំហំនៃទ្រព្យសម្បត្តិទទួលខុសត្រូវ គឺកម្រិតត្រឹមតែទ្រព្យសម្បត្តិដោយឡែក និង ប្រាក់ចំណូលរបស់ប្តី ឬ ប្រពន្ធដែលបានធ្វើសកម្មភាព

នោះបុំណ្ណោះ ហើយការរឹបអូសរបស់ម្ចាស់បំណុលមិនអាចលាតសន្ធឹងរហូតដល់គេហដ្ឋានគ្រួសារបានទេ (មាត្រា ១៤១៥ នៃក្រមរដ្ឋប្បវេណីបារាំង) ប្រសិនបើគេហដ្ឋានគ្រួសារដែលជាទ្រព្យសម្បត្តិរួម ត្រូវបានចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ការចាត់ចែងនោះត្រូវចាត់ទុកជាមោឃៈ ហើយភាគីដែលមិនបានផ្ដល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ២ ឆ្នាំក្រោយពេលដែលបានដឹងអំពីសកម្មភាពនោះ (មាត្រា ១៤២៧) ។ លើសពីនេះទៀត ដោយមិនគិតអំពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលប្ដីប្រពន្ធបានជ្រើសរើស សហព័ទ្ធម្ខាងមិនអាចចាត់ចែងគេហដ្ឋានគ្រួសារ ឬ គ្រឿងសង្ហារិមតុបតែងភ្ជាប់ជាមួយគេហដ្ឋាននោះ (meubles meublants) បាន ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ (កថាខណ្ឌទី ៣ នៃមាត្រា ២១៥) ។ ការចាត់ចែងទាំងឡាយណាដែលមិនបានទទួលការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ត្រូវចាត់ទុកជាមោឃៈ ហើយសហព័ទ្ធដែលមិនបានផ្ដល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពេលដែលបានដឹងអំពីសកម្មភាពចាត់ចែងនោះ ។ ម្យ៉ាងវិញទៀត មានបទប្បញ្ញត្តិដែលចែងថា ក្នុងករណីដែលការបដិសេធរបស់សហព័ទ្ធម្ខាងមិនមានភាពត្រឹមត្រូវចំពោះ "ផលប្រយោជន៍របស់គ្រួសារ" ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យផ្ដល់ការអនុញ្ញាត ជំនួសការយល់ព្រមរបស់សហព័ទ្ធនោះបាន (កថាខណ្ឌទី ១ នៃមាត្រា ២១៧) ។ លើសពីនេះទៀត សិទ្ធិជួលដើម្បីអាស្រ័យនៅរបស់ប្ដីប្រពន្ធ គឺជាសិទ្ធិរួមរបស់សហព័ទ្ធទាំងសងខាង (មាត្រា ១៧៥១) ហើយក្នុងករណីដែលសហព័ទ្ធម្ខាងបានចាត់ចែងសិទ្ធិជួលនោះដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ក៏សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យតុលាការធ្វើឱ្យមោឃៈការចាត់ចែងនោះបាន ក្នុងអំឡុពេល ៥ ឆ្នាំ ដែរ (មាត្រា ១៣០៤) ។ ដូចបានរៀបរាប់ខាងលើ នៅប្រទេសបារាំង ក៏តម្រូវឱ្យមានការគ្រប់គ្រងរួមគ្នា និង កម្រិតចំពោះការចាត់ចែងដែលគ្មានការយល់ព្រមពីភាគីម្ខាងទៀត ចំពោះអចលនវត្ថុសម្រាប់អាស្រ័យនៅ ដោយធានាការអាស្រ័យនៅរបស់គ្រួសារ ។ ប៉ុន្តែ ចំពោះទ្រព្យសម្បត្តិដទៃទៀតក្រៅពីនេះ ការការពារម្ចាស់បំណុល ឬ តតិយជន ត្រូវបានធានា ដោយផ្អែកលើការពិនិត្យមើលលើភាពមាន ឬ គ្មាននូវការជូនដំណឹងជាសាធារណៈ ដើម្បីធានាតុល្យភាពនៃភាគីទាំងសងខាង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២ និង មាត្រា ៣៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៧៥.- ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្ដីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ- កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដីប្រពន្ធទាំងសងខាងបាន

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៤១៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៩៧៦.-** ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ន្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ន្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង ។[៤]

(កំណត់)

ដូចមាត្រា ៣៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែរ កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីភាពមិនអាចចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ។ មាត្រានេះបញ្ជាក់ច្បាស់ថា គ្មានទ្រព្យរួមណាមួយអាចត្រូវផ្លាស់ប្តូរ ឬ ចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ន្ធទាំងសងខាងបានទេ ហើយថា គ្មានសហព័ន្ធម្ខាងណាអាចចាត់ចែងចំណែកនៃទ្រព្យរួមរបស់សហព័ន្ធនោះ ដោយគ្មានការយល់ព្រមពីសហព័ន្ធម្ខាងទៀតនោះបានទេ ។ កថាខណ្ឌទី ១ ដាក់បញ្ចូលនូវចំណុចទាំងពីរនេះ ។ ការនាំឆ្ពោះទៅរំលស់ការចាត់ចែងបែបនេះជារឿងធម្មតា ដោយសារតែរបបទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

---

[៤] កថាខណ្ឌទី ៣ នៃមាត្រា ៩៧៦ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**មាត្រា ៩៧៧.-** ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះ ទទួលស្គាល់នូវសិទ្ធិអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាង ដោយសហព័ទ្ធម្ខាងទៀត ក្នុងករណីដែលទ្រព្យសម្បត្តិដោយឡែកនោះត្រូវបានប្រើប្រាស់ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់ប្តីប្រពន្ធ ។ ដើម្បីកុំឱ្យមានការភាន់ច្រឡំជាមួយនឹងសិទ្ធិអាស្រ័យនៅរបស់គ្រួសារដែលបានចែងក្នុងគន្ថីស្តីពី "សិទ្ធិប្រត្យក្ស" មាត្រានេះត្រូវបានរៀបចំឡើងជាបញ្ញត្តិពិសេសនៅក្នុងបញ្ញត្តិស្តីពីរបបទ្រព្យសម្បត្តិប្តីប្រពន្ធ ។ ដូចគ្នាដែរ នៅចក្រភពអង់គ្លេស មាត្រា ១ នៃច្បាប់ស្តីពីលំនៅឋានប្តីប្រពន្ធ ឆ្នាំ ១៩៦៧ (Matrimonial Homes Act) ទទួលស្គាល់នូវសិទ្ធិដែលសហព័ទ្ធម្ខាងអាចអាស្រ័យនៅលើទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀតបាន (the right of occupation) ហើយមាត្រា ២ កំណត់ថា សិទ្ធិអាស្រ័យនៅត្រង់នេះគឺជាសិទ្ធិអាទិភាពដែលអាចអះអាងអំពីការបន្តការអាស្រ័យនៅចំពោះតតិយជនបាន ។ មាត្រានេះក៏បញ្ជាក់ផងដែរថា ប្តី ឬ ប្រពន្ធមានសិទ្ធិពិសេសលើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដើម្បីធានាការអាស្រ័យនៅ ។

ជាព័ត៌មាន កថាខណ្ឌទី ៣ នៃមាត្រា ២១៥ នៃក្រមរដ្ឋប្បវេណីបារាំង ចែងថា ការចាត់ចែងនូវលំនៅឋានគ្រួសារ និងសម្ភារៈផ្សេងៗទៀតនៅក្នុងផ្ទះ ចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ហើយប្រសិនបើគ្មានការយល់ព្រមទេ ការចាត់ចែងនោះត្រូវចាត់ទុកជាមោឃៈ ។ តាមមាត្រា ១៣៦៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ រាល់ការចាត់ចែងរបស់របរសម្រាប់ប្រើក្នុងផ្ទះទាំងឡាយ ចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ។ តាមមាត្រា ៧៥៣ និង មាត្រា ៧៥៤ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា សហព័ទ្ធនីមួយៗមិនអាចទាមទារឱ្យសហព័ទ្ធម្ខាងទៀតចាកចេញពីលំនៅឋានរបស់ខ្លួនបានទេ ហើយមិនអាចចាត់ចែងអចលនវត្ថុទាំងឡាយដែលកំពុងជាប់ក្នុងបណ្តឹងសុំលែងលះ ឬ បណ្តឹងសុំបែកលំនៅសង្វាស ជាដើម បានទេ លើកលែងតែមានការអនុញ្ញាតពីតុលាការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤២៨ និង កថាខណ្ឌទី៣ នៃមាត្រា ២១៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១ និង មាត្រា ២ នៃច្បាប់ស្តីពីលំនៅឋានប្តីប្រពន្ធរបស់ចក្រភពអង់គ្លេស, មាត្រា ១៣៦៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## ផ្នែកទី ៤ ការលែងលះគ្នា

នោះប៉ុណ្ណោះ ហើយការរឹបអូសរបស់ម្ចាស់បំណុលមិនអាចលាតសន្ធឹងរហូតដល់គេហដ្ឋានគ្រួសារបានទេ (មាត្រា ១៤១៥ នៃក្រមរដ្ឋប្បវេណីបារាំង) ប្រសិនបើគេហដ្ឋានគ្រួសារដែលជាទ្រព្យសម្បត្តិរួម ត្រូវបានចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ការចាត់ចែងនោះត្រូវចាត់ទុកជាមោឃៈ ហើយភាគីដែលមិនបានផ្តល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ២ ឆ្នាំក្រោយពេលដែលបានដឹងអំពីសកម្មភាពនោះ (មាត្រា ១៤២៧) ។ លើសពីនេះទៀត ដោយមិនគិតអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលប្តីប្រពន្ធបានជ្រើសរើស សហព័ទ្ធម្ខាងមិនអាចចាត់ចែងគេហដ្ឋានគ្រួសារ ឬ គ្រឿងសង្ហារិមតុបតែងភ្ជាប់ជាមួយគេហដ្ឋាននោះ (meubles meublants) បាន ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ (កថាខណ្ឌទី ៣ នៃមាត្រា ២១៥) ។ ការចាត់ចែងទាំងឡាយណាដែលមិនបានទទួលការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ត្រូវចាត់ទុកជាមោឃៈ ហើយសហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពេលដែលបានដឹងអំពីសកម្មភាពចាត់ចែងនោះ ។ ម្យ៉ាងវិញទៀត មានបទប្បញ្ញត្តិដែលចែងថា ក្នុងករណីដែលការបដិសេធរបស់សហព័ទ្ធម្ខាងមិនមានភាពត្រឹមត្រូវចំពោះ "ផលប្រយោជន៍របស់គ្រួសារ" ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យផ្តល់ការអនុញ្ញាត ជំនួសការយល់ព្រមរបស់សហព័ទ្ធនោះបាន (កថាខណ្ឌទី ១ នៃមាត្រា ២១៧) ។ លើសពីនេះទៀត សិទ្ធិជួលដើម្បីអាស្រ័យនៅរបស់ប្តីប្រពន្ធ គឺជាសិទ្ធិរួមរបស់សហព័ទ្ធទាំងសងខាង (មាត្រា ១៧៥១) ហើយក្នុងករណីដែលសហព័ទ្ធម្ខាងបានចាត់ចែងសិទ្ធិជួលនោះដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ក៏សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការធ្វើឱ្យមោឃៈការចាត់ចែងនោះបាន ក្នុងអំឡុពេល ៥ ឆ្នាំ ដែរ (មាត្រា ១៣០៤) ។ ដូចបានរៀបរាប់ខាងលើ នៅប្រទេសបារាំង ក៏តម្រូវឱ្យមានការគ្រប់គ្រងរួមគ្នា និង កម្រិតចំពោះការចាត់ចែងដែលគ្មានការយល់ព្រមពីភាគីម្ខាងទៀត ចំពោះអចលនវត្ថុសម្រាប់អាស្រ័យនៅ ដោយធានាការអាស្រ័យនៅរបស់គ្រួសារ ។ ប៉ុន្តែ ចំពោះទ្រព្យសម្បត្តិដទៃទៀតក្រៅពីនេះ ការការពារម្ចាស់បំណុល ឬ តតិយជន ត្រូវបានធានា ដោយផ្អែកលើការពិនិត្យមើលលើភាពមាន ឬ គ្មាននូវការជូនដំណឹងជាសាធារណៈ ដើម្បីធានាតុល្យភាពនៃភាគីទាំងសងខាង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២ និង មាត្រា ៣៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៧៥.- ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ- កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធទាំងសងខាងបាន

ព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ច ផ្សេងៗទៀត ដែលប្តីប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។[៣]

គ- សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលថា ទោះបីជាកម្មជាអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធក៏ដោយ ក៏ពុំមានភាពសមរម្យក្នុងការដាក់បន្ទុកឱ្យប្តីប្រពន្ធនីមួយៗនូវកាតព្វកិច្ចដ៏ធ្ងន់ធ្ងរដែរ ហើយមានភាពសមរម្យឱ្យទទួលខុសត្រូវចំពោះកាតព្វកិច្ចរួមគ្នាក្នុងទំហំសមរម្យមួយ ដែលទោះបីជាមើលពីខាងតតិយជនទៅ ក៏ឃើញថា សមរម្យដែរ ។ ចំណុច ខ នៃមាត្រានេះទាមទារជាពិសេសឱ្យមានល័ក្ខខ័ណ្ឌចាំបាច់នៃលិខិតជាលាយល័ក្ខណ៍អក្សរ និង ការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ ។

ប៉ុន្តែ ក្នុងករណីដែលអនុវត្តនូវប្រព័ន្ធទ្រព្យសម្បត្តិរួម ទោះបីជាសហព័ទ្ធម្ខាង ឬ ទាំងសងខាងទទួលបន្ទុកនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ជាគោលការណ៍ បន្ទុកនៃកាតព្វកិច្ចត្រូវជារបស់ទ្រព្យសម្បត្តិរួមដែរ ហើយកាតព្វកិច្ចនោះនឹងក្លាយទៅជាកាតព្វកិច្ចរួមរបស់សហព័ទ្ធទាំងពីរ (មាត្រា ៩១១ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា) ។ ហេតុដូច្នេះ សិទ្ធិចំពោះទ្រព្យសម្បត្តិរួម (សិទ្ធិលើចំណែកនៃវត្ថុ ឬ សិទ្ធិអភិភាគ) របស់សហព័ទ្ធម្ខាងទៀត មិនត្រូវបានការពារទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលសុចរិត ហើយ គ្មានកំហុស លើកលែងតែករណីដែលបានធ្វើការចាត់វិធានការរក្សាការពារចំពោះទ្រព្យសកម្ម ឬ ការកែតម្រូវការចុះបញ្ជីអំពីកម្មសិទ្ធិករ ជាអាទិ៍ ។ ក៏ប៉ុន្តែ ការទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលជាទ្រព្យអកម្ម ក៏ត្រូវបានកម្រិតដែរៈ ហេតុដូច្នេះ មានភាពស៊ីសង្វាក់គ្នា ។ ប្រសិនបើអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមសុទ្ធសាធតែម្តង កាតព្វកិច្ចទាំងឡាយក៏នឹងក្លាយជាកាតព្វកិច្ចរួម និង ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពដែរ ។ ប្រសិនបើទ្រព្យសកម្មទាំងអស់ត្រូវបានចាត់ទុកថាជាទ្រព្យរួម ទោះបីជាចុះបញ្ជីក្នុងនាមរបស់សហព័ទ្ធទាំងពីរ ឬ ម្ខាងក៏ដោយ ចំណែកឯទ្រព្យអកម្មត្រូវបានចាត់ទុកដោយឡែក នោះគ្មានភាពសមហេតុសមផលទេឡើយ ។

ក្រមរដ្ឋប្បវេណីបារាំង ក៏ចែងដែរថា ម្ចាស់បំណុល ជាគោលការណ៍ គ្មានសិទ្ធិប្រមូលបំណុលពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធរបស់កូនបំណុលទេ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធតែម្ខាងទទួលនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើកាតព្វកិច្ចនោះពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ កាតព្វកិច្ចនោះជាបន្ទុករបស់ទ្រព្យសម្បត្តិរួម ហើយប្រសិនបើកាតព្វកិច្ចនោះជាផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាងទេ សហព័ទ្ធនោះត្រូវទទួលបន្ទុកតែម្នាក់ឯង ។

---

[៣] ចំណុច ខ នៃមាត្រា ៩៧៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

# សទ្ទានុក្រមរដ្ឋប្បវេណី

## ខ្មែរ_ខ្មែរ

Www.KhmerFamous.Com

# ឧបសម្ព័ន្ធទី៣

- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ច្បាប់
# ស្តីពី
# ការអនុវត្តក្រមរដ្ឋប្បវេណី

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១១

# ឧបសម្ព័ន្ធទី៤

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ឯកពន្ធភាព

# ឧបសម្ព័ន្ធទី៥

- ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រកាសក្រសួងលេខ ៨១កយ/ប្រក/១៣ ចុះថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០១៣

# ចំណាប់អារម្មណ៍

# របស់

# ឯកឧត្តម

# អង្គ វង្សវឌ្ឍនា

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ចំណាប់អារម្មណ៍របស់
### ឯកឧត្តម អង្គ វង្សវឌ្ឍនា
### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងមោទនភាពខ្ពស់ដោយក្រសួងយុត្តិធម៌ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់រួមមាន: បញ្ញត្តិមូលដ្ឋាន បញ្ញត្តិបន្ទាប់បន្សំ និងបញ្ញត្តិពិសេស ដែលបទប្បញ្ញត្តិទាំងនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងការរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរវាង បុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ជាអចលនវត្ថុក្តី គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម ? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ?

ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឲ្យភាគីអាចកំណត់ឲ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឲ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ។

ទស្សនៈនៃគោលគំនិត ក្នុងការកំណត់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិនេះ ក៏ត្រូវបានយកមកបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយបានអនុវត្តកាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមកនេះ ។

នៅក្នុងមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ឲ្យតែមិនផ្ទុយនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុង ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេស ចំពោះទ្រព្យសម្បត្តិនោះទេ នោះត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។

រីឯមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំកំណត់អំពី បែបបទ និងទម្រង់ នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារមួយ ដោយសហការ ជាមួយជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ដើម្បីរៀបចំ បែបបទ និងទម្រង់ នៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយប្រើប្រព័ន្ធចុះបញ្ជីដែលរៀបចំឡើងដោយប្រើក្រដាសដាក់ក្នុងក្រឡា ។

ជាមួយនឹងការអបអរសាទរនៃភាពជោគជ័យ របស់ក្រុមការងារក្នុងការរៀបចំប្រកាសនេះ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ កោតសរសើរ និងសូមថ្លែងអំណរគុណ ដោយស្មោះអស់ពីចិត្ត ចំពោះស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងការខិតខំប្រឹងប្រែង ការព្យាយាម យកអស់ពីកំលាំងកាយ និងបញ្ញាស្មារតី របស់ក្រុមការងារ និងជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ។ ជាពិសេស ក្រុមការងារសាស្ត្រាចារ្យជប៉ុន ដែលបានចូលរួម ប្រឹក្សាយោបល់ នៅក្នុងការរៀបចំ បទប្បញ្ញត្តិគតិយុត្តដ៏មានសារៈសំខាន់នេះ ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍន៍វិស័យច្បាប់ ស្របតាមគោលនយោបាយ ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជំហានបន្ទាប់ ក្រសួងយុត្តិធម៌ក៏បានកំណត់ទិសដៅឲ្យ ក្រុមការងារដែលបានរៀបចំប្រកាសនេះ ត្រូវធ្វើការបណ្តុះបណ្តាល និង ផ្សព្វផ្សាយប្រកាសនេះ ឲ្យបានទូលំទូលាយទៅដល់មន្ត្រីអនុវត្តច្បាប់និងប្រជាពលរដ្ឋទូទៅ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ប្រកាសនេះនឹងក្លាយជាឧបករណ៍គតិយុត្តដ៏សំខាន់ ដែលផ្តល់សិទ្ធិ និងបើកឱកាស ឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមានបំណងចង់ធ្វើការចុះបញ្ជី អាចធ្វើការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ហើយឈានទៅដល់ការបង្កើតទំនាក់ទំនងរវាង បុរស និងស្ត្រី ឲ្យមានភាពច្បាស់លាស់ និងតម្លាភាព ពាក់ព័ន្ធនឹងបញ្ហាទ្រព្យសម្បត្តិ និងចូលរួមចំណែកក្នុងការពង្រឹងគោលការណ៍សមភាពយេនឌ័រនៅក្នុងសង្គម ។/

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

# ប្រកាស
# ស្តីពី
# នីតិវិធី
# នៃការចុះបញ្ជី
# ទ្រព្យសម្បត្តិប្តីប្រពន្ធ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤ ក.យ.ប្រក/១៣

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

# ឧបសម្ព័ន្ធទី៦

- ប្រកាសអន្តរក្រសួងលេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.moj.gov.kh
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ៨១ កយ.ប្រក/១៣ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- បានឃើញប្រកាសលេខ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .- ការប្រមូលចំណូល**

ត្រូវបានអនុញ្ញាតឱ្យក្រសួងយុត្តិធម៌ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .- កម្រងសេវាសាធារណៈ**

សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានខ្លឹមសារលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចខាងក្រោម ÷

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | ៣០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ការចុះបញ្ជីផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | ការចុះបញ្ជីកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៤ | ការចុះបញ្ជីអំពីការលុបកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥ | ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | ការចេញលិខិតបញ្ជាក់ | ៤០.០០០ | ៣ថ្ងៃ | ៦ខែ |

**ប្រការ៣ _ ការបិទផ្សាយព័ត៌មាន**

ក្រសួងយុត្តិធម៌ត្រូវបិទផ្សាយជាសាធារណៈនូវព័ត៌មានមួយចំនួនដូចខាងក្រោម÷

- ទម្រង់ឯកសារនៃពាក្យសុំទៅតាមប្រភេទនីមួយៗ
- តារាងតម្លៃសេវាសាធារណៈ ដូចមានចែងនៅក្នុងប្រការ២ (កម្រងសេវាសាធារណៈ) នៃប្រកាសអន្តរក្រសួងនេះ
- នីតិវិធីនៃការផ្តល់សេវា។

**ប្រការ៤ _ ការទទួលមតិរិះគន់**

នៅកន្លែងផ្តល់សេវាសាធារណៈ ក្រសួងយុត្តិធម៌ត្រូវរៀបចំឱ្យមានកន្លែងទទួលមតិរិះគន់ ចំពោះការចាត់ចែងរបស់មន្ត្រីចុះបញ្ជី ដែលបានអនុវត្តផ្ទុយពីខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះ ដូចជា ការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវ ហួសរយៈពេលអតិបរមាដែលបានកំណត់ ជាអាទិ៍។

មតិរិះគន់នេះ អ្នកទទួលសេវាអាចធ្វើតាមរយៈសារអេឡិចត្រូនិក ឬដាក់លិខិតរិះគន់នៅប្រអប់សំបុត្ររបស់ក្រសួងយុត្តិធម៌ ឬដាក់នៅប្រអប់សំបុត្ររបស់អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៥ _ យន្តការនៃការផ្តល់សេវាសាធារណៈ**

ក្រសួងយុត្តិធម៌ គប្បីរៀបចំយន្តការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅក្រសួងយុត្តិធម៌ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ៦ _ ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ដែលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧ _ ការរៀបចំគម្រោង និងការអនុវត្តចំណូល**

ក្រសួងយុត្តិធម៌ ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅពេលអនុវត្តចំណូល ក្រសួងយុត្តិធម៌ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ ._ ការរៀបចំរបាយការណ៍**

ក្រសួងយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ស្ដីពីការអនុវត្តចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៩ ._ ការកែសម្រួលកម្រៃសេវាសាធារណៈ**

កម្រៃសេវាសាធារណៈដែលចែងក្នុងប្រការ២ (កម្រៃសេវាសាធារណៈ) នៃប្រកាសអន្តរក្រសួងនេះ អាចធ្វើការកែប្រែបាន តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រសិនបើមានការចាំបាច់។

**ប្រការ១០ ._ ការទទួលបន្ទុកនៃការអនុវត្តប្រកាសអន្តរក្រសួង**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ តទៅ។

ថ្ងៃច័ន្ទ ៥ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៨

- ឯកសារផ្សេងៗដែលទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ..........

ចុះថ្ងៃទី ខែ ឆ្នាំ

**សាលក្រមលេខ:**

ចុះថ្ងៃទី ខែ ឆ្នាំ

*តាងនាមប្រជារាស្ត្រខ្មែរ*

**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

នៅថ្ងៃទី ខែ ឆ្នាំ

ដោយមានសមាសភាព:

-លោក **ជួន វណ្ណះ** ចៅក្រម

-លោក **ឃី អៀង** ក្រឡាបញ្ជី

-ដើមចោទឈ្មោះ .................................... ភេទ ........ កើតនៅឆ្នាំ .......... ជនជាតិខ្មែរ មុខរបរកស៊ីបុគ្គលិកក្រុមហ៊ុន អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-មានលោក ............ ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ ............ ភេទ .... កីតនៅឆ្នាំ ........ ជនជាតិខ្មែរ មុខរប មេផ្ទះ អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-*<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>*

១-សុំលែងលះពីប្រពន្ធឈ្មោះ .......... ។

២-សុំសិទ្ធិគ្រប់គ្រងកូន៖

២.១.ឈ្មោះ ...................... ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

២.២.ឈ្មោះ ............................ ភេទ .... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-បែងចែកទ្រព្យសម្បត្តិរួមមាន:ដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............... ឃុំ ............... ស្រុក ............... ខេត្ត ............... ជាពីរចំណែកស្មើគ្នា។

៤-*<u>ការពន្យល់ត្រួសៗអំពីរឿងក្តី:</u>*

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ....... ចុះថ្ងៃទី ....... ខែ ....... ឆ្នាំ ......... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ .................. ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីររស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ មានឈ្មោះ ...................... ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ........................ ភេទ ........ កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

ប៉ុន្តែក្រោយពេលដែល មានកូន ០២ នាក់ អ្នកទាំងពីរតែងតែមានភាពរកាំរកូសជាមួយគ្នាជាញឹកញាប់ ការរស់នៅមិនចុះសម្រុងគ្នា និងបានបែកលំនៅសង្វាសអស់មួយរយៈមកហើយ ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តី ប្រពន្ធតទៅមុខទៀត។ ហើយក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការ ។

៣-*ការអះអាងរបស់ភាគី*:

-ដើមចោទឈ្មោះ ........................ បានអះអាងថា: ខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រម ដូចការទាមទារខាងលើ ដោយហេតុថា ខ្លួនបានរៀបការជាមួយឈ្មោះ ............ កាលពីថ្ងៃទី ខែ ឆ្នាំ និងបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។ ការរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២ នាក់ គឺឈ្មោះ .............. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៤។ ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ដែលមានលិខិតលក់ទិញចុះថ្ងៃទី ០៩.០២.២០១២ និងបានឃើញនិងបញ្ជាក់លេខ:០១៤/១២ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេឃុំអូរបាក់រទេះ និងផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...... ........................ ចុះថ្ងៃទី .... ខែ ...... ឆ្នាំ ...... ដែលកំពុងបង់រំលោះនៅធនាគារបានចំនួន ១០ខែ ស្មើទឹកប្រាក់ចំនួន ................................ ដុល្លាអាមេរិក និងមានគ្រឿងអលង្កាសរុបស្មើទឹកប្រាក់ចំនួន ........................ ដុល្លាអាមេរិក សូមបញ្ជាក់ថា ពួកខ្លួនពុំមានជំពាក់បំណុលគេទេ ហើយដីខាងលើក៏ពុំមានជាប់ពាក់ព័ន្ធនឹងការធានាបំណុលគេដែរ ។

-ចុងចម្លើយឈ្មោះ .......... បានចូលមកធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនឯកភាពក្នុងការលែងលះ សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ សុំប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីតនាក់ក្នុងមួយខែចំនួន ៣០០$(បីរយ) ក្នុងករណីកូនទាំងពីរនាក់រស់នៅជាមួយខ្លួន និងទទួលស្គាល់ថាមានទ្រព្យសម្បត្តិរួមដូចការលើកឡើងរបស់ដើមចោទប្រាកដមែន។

ក្រោយការផ្សះផ្សាសម្រុះសម្រួលរួចមកគូរភាគីបានឯកភាពគ្នាដូចខាងក្រមះ

-ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ .......... ឃុំអូរ .......... ស្រុក ............ ខេត្ត .............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ...................... និងបានឃើញនិងបញ្ជាក់លេខ: ........ ចុះថ្ងៃទី .... ខែ ... ឆ្នាំ ...... របស់មេឃុំ ............ នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ...... ចុះថ្ងៃទី ... ខែ .... ឆ្នាំ .... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់រាហារកិច្ចចិញ្ចឹមកូន។

-កូនទីមួយឈ្មោះ ........................ ភេទប្រុស និងកូនទីពីរឈ្មោះ ........................ ភេទប្រុស ទុកសិទ្ធិឲ្យកូនគាត់ស្រេចចិត្តដោយខ្លួនគាត់។

-មេធាវីការពារសិទ្ធិដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-មេធាវីការពារសិទ្ធិចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-*ចំណុចវិវាទ:* ការលែងលះ និងសិទ្ធិគ្រប់គ្រងកូន។

៥-*ចំណុចគ្មានវិវាទ*: ឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម។

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីថ្ងៃទី ... ខែ ....... ឆ្នាំ ....... និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ....... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ .............. ។ ដូច្នេះឃើញថា ដើមចោទ និងចុងចម្លើយ បានបំពេញករណីយកិច្ចជាប្តីប្រពន្ធស្របច្បាប់ ចំពោះការទាមទារសុំលែងលះនេះតុលាការអាចពិចារណាសម្រេចបាន។ តុលាការបានសាកល្បងធ្វើការផ្សះផ្សាគូភាគីរួចហើយ ប៉ុន្តែគូភាគីនៅតែទាមទារលែងលះគ្នា ដោយសារអស់មនោសញ្ចេតនា អាណិតស្រលាញ់គ្នាជាប្តីប្រពន្ធទៀតហើយ ។

២-នៅក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន ០២នាក់មាន ៖

.ឈ្មោះ .............. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

.ឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-ទ្រព្យសម្បត្តិរួមមាន៖

-ទ្រព្យសម្បត្តិរួមចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........... ឃុំ ........... ស្រុក ........... ខេត្ត ........... ដែលមានលិខិតលក់ទិញចុះថ្ងៃទី .......................... និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី ..... ខែ ... ឆ្នាំ របស់មេឃុំ .......................... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ....... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ..... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់អាហារកិច្ចចិញ្ចឹមកូន។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-កូនទីមួយឈ្មោះ .................. ភេទប្រុស បានសុំរស់នៅជាមួយម្តាយ និងកូនទីពីរឈ្មោះ ..... ........... ភេទប្រុស បានសុំរស់នៅជាមួយឪពុក គប្បីតុលាការសម្រេចតាមការណ៍ស្នើសុំ។

យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នាមានសិទ្ធិ

ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន" ។

៥-ចំពោះប្រាក់ប្រដាប់ក្ដីតុលាការគប្បីឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ពាក់កណ្ដាល (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

## សេចក្ដីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ ........................ លែងលះពីចុងចម្លើយឈ្មោះ ............ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅ៖

២.១.ដើមចោទឈ្មោះ .................... លើកូនឈ្មោះ .................... ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

២.២.ចុងចម្លើយឈ្មោះ .......... លើកូនឈ្មោះ .................... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

ទុកសិទ្ធិឲ្យភាគីដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ទ្រព្យសម្បត្តិរួមមាន៖

៣.១-ដីទំហំ .......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ .............. ឃុំ .................. ស្រុក .................. ខេត្ត .............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ......................... និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី .... ខែ ឆ្នាំ ....... របស់មេឃុំ ............ ប្រគល់ឲ្យកូនទាំងពីរនាក់គ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូរភាគីគ្រប់គ្រងដីនោះជាបណ្ដោះអាសន្ន។

៣.២-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

៣.៣-ផ្ទះមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............................ ....... ចុះថ្ងៃទី .. ខែ .... ឆ្នាំ .... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា **ជួន ចណ្ណា:**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្ដាល,ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
លេខ: ...... /២០២០

## លិខិតបញ្ជាក់សាលក្រមស្ថាពរ

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលដំបូងខេត្តកណ្ដាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញ សាលក្រមលេខ: ........ ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ........ ខែ ...... ឆ្នាំ ........ របស់មេធាវីឈ្មោះ .................... ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ........ ចុះថ្ងៃទី ... ខែ ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ........ តទៅហើយដោយភាគីពុំបានប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឲ្យដាក់រូបមន្តអនុវត្តលើសាលក្រមនេះ សម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣
ខេត្តកណ្ដាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**

ឃី . អៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------------សញ្ជាតិ---------- កើតថ្ងៃទី------ ខែ-------ឆ្នាំ-------- មុខរបរបច្ចុប្បន្ន---------------------------------------------ស្ថានភាពផ្ទាល់ខ្លួន---------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម---------- ភូមិ------------ ឃុំ សង្កាត់ ---------------- ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ------------------។ ឪពុកឈ្មោះ---------------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ-----------------------អាយុ-------ឆ្នាំ (រស់ ស្លាប់)។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់......................................**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ----------------------ភេទ------ សញ្ជាតិ-----------កើតថ្ងៃទី------ ខែ-------ឆ្នាំ--------------------------------មុខរបរ------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ--------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------- រាជធានី ខេត្ត ------------------ប្រទេស ------------------។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------------------------------- មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅ--------------ថ្ងៃទី------- ខែ----------- ឆ្នាំ--------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃស្តាំសាមីខ្លួន**

- ------------------------------
- ------------------------------
- ------------------------------

ឈ្មោះ-----------

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំបញ្ជាក់**

**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ-----------ទី------ ខែ-------ឆ្នាំ-------- នៅភូមិ------------------- ឃុំ សង្កាត់---------------------ក្រុង ស្រុក ខណ្ឌ-------------- រាជធានី ខេត្ត---------------------- មុខរបរបច្ចុប្បន្ន-----------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ-------- ក្រុម------ ភូមិ----------- ឃុំ សង្កាត់------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត --------------- ។

**គោរពជូន**

**មេឃុំ ចៅសង្កាត់**------------------------

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលិខិតបញ្ជាក់ភាព------------------------------ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន----------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ-------------- ភេទ--------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ------------------------ ឃុំ សង្កាត់---------------------- ក្រុង ស្រុក ខណ្ឌ------------------------- រាជធានី ខេត្ត ---------------------ប្រទេស-------------- ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្តិតស្នាមមេដៃស្តាំ ទុកជាភស្តុតាង ។

ធ្វើនៅ ------------ថ្ងៃទី-------- ខែ-------- ឆ្នាំ---------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

- --------------------------
- --------------------------
- --------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

4x6

រាជធានី ខេត្ត ----------------
ក្រុង ស្រុក ខណ្ឌ ----------------
ឃុំ សង្កាត់ ----------------
លេខ ----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ------

**លិខិតបញ្ជាក់**

**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

យោងពាក្យសុំបញ្ជាក់ភាព-------------- ចុះថ្ងៃទី------ ខែ---------- ឆ្នាំ------- របស់------------------------។

**យើងមេឃុំ ចៅសង្កាត់**-----------------------

សូមបញ្ជាក់ថា ឈ្មោះ----------------------- ភេទ------- កើតនៅថ្ងៃ------ ទី------- ខែ----------ឆ្នាំ--------- នៅភូមិ------------ ឃុំ សង្កាត់--------------- ក្រុង ស្រុក ខណ្ឌ-----------------រាជធានី ខេត្ត------------------ ប្រទេស--------------មុខរបរបច្ចុប្បន្ន---------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ-------- ក្រុម------- ភូមិ--------------ឃុំ សង្កាត់-----------------ក្រុង ស្រុក ខណ្ឌ-------------------- រាជធានី ខេត្ត-----------------ប្រទេស--------------មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា------------------- ប្រាកដមែន។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ..........................

ស្រុក ខណ្ឌ ..........................

ឃុំ សង្កាត់ ..........................

លេខ ..................................

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្ដឹងជំទាស់ | | |
| នាមត្រកូល និង នាមខ្លួនឪពុក | | |
| ថ្ងៃ ខែឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និង នាមខ្លួនម្ដាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

ធ្វើនៅ..............................ថ្ងៃទី........ខែ...........ឆ្នាំ.............

មន្ត្រីអត្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ..............................
ក្រុង ស្រុក ខណ្ឌ ..............................
ឃុំ សង្កាត់ ..............................

លេខ______________________________
សៀវភៅអាពាហ៍ពិពាហ៍លេខ______________
ឆ្នាំ______________________________

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |

| អំពីឪពុក ម្តាយ | ខាងប្តី | ខាងប្រពន្ធ |
|---|---|---|
| នាមត្រកូល និង នាមខ្លួនឪពុក | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| នាមត្រកូល និង នាមខ្លួនម្តាយ | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |

ធ្វើនៅ.................... ថ្ងៃទី......ខែ.......ឆ្នាំ..........

មន្ត្រីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ១<br>ប្រការ ១៩ |
|---|

# ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះ........................ភេទ ស្រី អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:....................(ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)...... ។
- មូលហេតុ:.....................(កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)......... ។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ:.......(សរសេរខ្លឹមសារកិច្ចសន្យាទាំងអស់)......... ........................................................................................................ ........................................................................................................ ........................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្ដមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**